**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royal de Droit et des Sciences Economiques**

**Royal University of Law and Economics**

# សារណាបញ្ចប់ការសិក្សា

# នីតិវិធីនៃការចុះបញ្ជីប្រកាសនីយបត្រ តក្កកម្មជាតិ និង អន្តរជាតិ

ស្រាវជ្រាវពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ ៖ **ក. វ៉ែត សុលាត**

**ក. អៀង តត្រា**

សាស្ត្រាចារ្យណែនាំ ៖

**បណ្ឌិត ឃឹម គិរី**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២១

ឆ្នាំចូលសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

## **អំណះអំណាង**

នាងខ្ញុំឈ្មោះ **រ៉េត សុលាភ** និង **អៀង តង្រា** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ជំនាន់ទី ២១ ឆ្នាំសិក្សា ២០១៧-២០២១ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមធ្វើការអះអាងចំពោះខ្លឹមសារសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ នេះពិតជាកើតចេញពីគំនិតផ្ទាល់ខ្លួនរបស់នាងខ្ញុំ និងដោយបានការជួយជ្រោមជ្រែងពីលោកសាស្ត្រាចារ្យ **ឃឹម គិរី** ទាំងឯកសារស្មារតី និងការជួយពន្យល់បង្ហាត់បង្ហាញ ដែលធ្វើឱ្យនាងខ្ញុំមាន ទុននៅក្នុងការសរសេរសារណានេះឡើង ដោយមិនមានការថតចម្លងសារណា ឬរបាយការណ៍ ឬ និក្ខេបបទ របស់អ្នកផ្សេងឡើយ។

រាជធានីភ្នំពេញ, ថ្ងៃពុធ ១០កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២១

**ហត្ថលេខា** **ហត្ថលេខា**

# មូលវិចារណ៍

ខ្ញុំសុំកោតសរសើរចំពោះនិស្សិត វ៉េត សុលាភ និង អៀង ភត្រា ស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ជំនាន់ទី ២១ ដែលកំពុងសិក្សាសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលបានខិតខំព្យាយាមយកចិត្តទុកដាក់សិក្សាស្រាវជ្រាវ និងសរសេរសារណាបញ្ចប់ការសិក្សាលើប្រធានបទ "**នីតិវិធីនៃការចុះបញ្ជីប្រកាសនីយបត្រតក្កកម្ម និង អន្តរជាតិ**"។

មតិវិភាគទាំងឡាយក្នុងសារណា គឺជាស្នាដៃ និង ជាគំនិតផ្ទាល់ខ្លួន ដែលបានមកពីការសិក្សាស្រាវជ្រាវកន្លងមក ក្នុងស្មារតីស្វែងយល់ពីទ្រឹស្តី យន្តការ ដំណើរការនៃនីតិវិធី និង ភាពដូច ភាពខុសគ្នារវាងនីតិវិធីប្រកាសនីយបត្រតក្កកម្មជាតិ និង អន្តរជាតិ ដែលមានលក្ខណៈពិសេសរៀងៗខ្លួនសម្រាប់អនុវត្តជាក់ស្តែងក្នុងវិស័យកម្មសិទ្ធិបញ្ញា នាពេលបច្ចុប្បន្ននេះ។

ជាចុងបញ្ចប់នេះ ក្នុងនាមជាសាស្ត្រាចារ្យណែនាំក្នុងការសរសេរសារណានេះ យល់ឃើញថាសារណានេះ នឹងក្លាយជាឯកសារជំនួយស្មារតីដ៏មានតម្លៃ និង មានសារៈប្រយោជន៍ដល់និស្សិត និង អ្នកស្រាវជ្រាវដទៃទៀតដើម្បីធ្វើទុកជាទុនសម្រាប់ការស្រាវជ្រាវ បន្ថែមទៀតបាននាពេលអនាគត។

រាជធានីភ្នំពេញ, ថ្ងៃពុធ ១០កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២១

**ហត្ថលេខា**

**សាស្ត្រាចារ្យ ឃឹម គិរី**

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **វ៉េត សុលាភ** និង **អៀង តត្រា** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ជំនាន់ទី ២១ ឆ្នាំសិក្សា ២០១៧ - ២០២១ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។

ជាបឋម នាងខ្ញុំសូមលំឱនកាយគោរពដឹងគុណយ៉ាងជ្រាលជ្រៅ និង ខ្ពង់ខ្ពស់ជាទីបំផុតចំពោះអ្នកមានគុណទាំងពីរ ដែលលោកបានបង្កើត ចិញ្ចឹមបីចាច់ មើលថែរក្សា អប់រំ ណែនាំ ប្រៀបប្រដៅ លះបង់គ្រប់យ៉ាង និង ជួយទំនុក បំរុង ដើម្បីឱ្យនាងខ្ញុំមានឱកាសបានសិក្សារៀនសូត្ររហូតដល់ថ្នាក់បញ្ចប់បរិញ្ញាបត្រ។

នាងខ្ញុំសូមថ្លែងអំណរគុណចំពោះឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង អស់លោក លោកស្រី ជាសាស្ត្រាចារ្យនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានចំណាយពេលវេលាខិតខំបង្ហាត់បង្រៀន និង ចែករំលែកនូវចំណេះដឹងព្រមទាំងបទពិសោធន៍ល្អៗចំពោះនាងខ្ញុំតាំងពីដើមរហូតមកដល់ពេលនេះ ។

ជាពិសេស នាងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅក្រៃលែង ចំពោះលោកសាស្ត្រាចារ្យ **ឃឹម គិរី** ជាសាស្ត្រាចារ្យដឹកនាំក្នុងការសរសេរសារណានេះឡើង ដោយលោកបានខិតខំចំណាយពេលវេលាដ៏មានតម្លៃ ធ្វើការណែនាំពន្យល់ចំណុចសំខាន់ ផ្តល់មតិយោបល់ល្អៗអំពីរបៀបសរសេរ ឯកសារពាក់ព័ន្ធនឹងប្រធានបទស្រាវជ្រាវ ព្រមទាំងជួយត្រួតពិនិត្យ កែតម្រូវ យ៉ាងហ្មត់ចត់ចំពោះចំណុចខ្វះខាតទាំងឡាយ នឹង ជួយលើកទឹកចិត្ត ដើម្បីជួយ ជម្រុញឱ្យសារណារបស់ក្រុមនាងខ្ញុំមានលទ្ធផលល្អ រហូតដល់សារណារបស់ក្រុមនាងខ្ញុំសរសេរបានចប់ជាស្ថាពរ ។

ជាទីបញ្ចប់ នាងខ្ញុំទាំងពីរនាក់សូមបួងសួងដល់វត្ថុសាកសិទ្ធិ សូមប្រសិទ្ធិពរជ័យសិរីមង្គលដល់ ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង អស់លោក លោកស្រី និង លោកសាស្ត្រាចារ្យ **ឃឹម គិរី** ទទួលបាននូវសុខភាពល្អ និង ទទួលបាននូវជោគជ័យគ្រប់ភារៈកិច្ចទាំងអស់គ្រប់ប្រការ ។

# **អារម្ភកថា**

យើងខ្ញុំ សូមគោរពចំពោះ ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង អស់លោក លោកស្រី ជាសាស្ត្រាចារ្យនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច មិត្តភ័ក្ត និងនិស្សិតគ្រប់រូបដោយសេចក្តីគោរព និង សេចក្តីស្រលាញ់រាប់អាន។

យើងខ្ញុំទាំងពីរនាក់ជានិស្សិតថ្នាក់ L៣A៤ ឆ្នាំទី៤ ផ្នែកបរិញ្ញាបត្រនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា២០២០-២០២១ ដែលប្រធានការិយាល័យស្រាវជ្រាវ បានអនុញ្ញាតឱ្យក្រុមនាងខ្ញុំសិក្សាស្រាវជ្រាវ និង សរសេរសារណាបញ្ចប់ការសិក្សាលើប្រធានបទ "**នីតិវិធីនៃការចុះបញ្ជីប្រកាសនីយបត្រតក្កកម្មជាតិ និងអន្តរជាតិ**" យើងខ្ញុំទាំងពីរនាក់ពិតជាមានសេចក្តីសោមនស្សរីករាយក្រៃលែង និងចំណាយកម្លាំងចិត្ត ក្នុងការធ្វើកិច្ចការនេះឱ្យបានលេចចេញជារូបរាងឡើងព្រោះកិច្ចការនេះបានធ្វើឱ្យក្រុមនាងខ្ញុំ ចេះស្រាវជ្រាវ ផ្តល់ចំណេះដឹង បណ្តុះគំនិតប្រាជ្ញាឱ្យកាន់តែច្បាស់លាស់អំពីប្រធានបទមួយនេះ។

យើងខ្ញុំសង្ឃឹម និង រំពឹងទុកជាមុនថាកិច្ចការស្រាវជ្រាវនេះជាមូលដ្ឋានមួយដែលមានប្រយោជន៍សម្រាប់សិស្ស និស្សិត និងអ្នកអានជំនាន់ក្រោយ ចូលរួមចំណែកដើម្បីបង្កើតពុទ្ធិ ចំណេះដឹង និងជាមូលដ្ឋានមួយសម្រាប់ស្រាវជ្រាវដល់អ្នករាល់គ្នា។

ចំពោះយើងខ្ញុំ ដោយសារចំណេះ និងជំនាញនៅមានកម្រិត ជាហេតុដែលនាំឱ្យមានការកខ្វះខាតនូវឯកសារសម្រាប់ស្រាវជ្រាវ ក្រុមយើងខ្ញុំជឿជាក់ថាកំហុសខុសឆ្គងនៅតែកើតមានឡើងដោយអចេតនា ទាំងខ្លឹមសារពាក្យពេចន៍ ឃ្លា អក្ខរាវិរុទ្ធ និងបច្ចេកទេសក្នុងការចងក្រងនៅមានកម្រិតផងដែរ។

អាស្រ័យហេតុនេះ ក្រុមយើងខ្ញុំសូមការអភ័យទោសចំពោះកំហុសខុសឆ្គង ព្រមទាំងទទួលការរិះគន់ដើម្បីស្ថាបនានៅពេលធ្វើការស្រាវជ្រាវលើកក្រោយ ក្រុមនាងខ្ញុំនឹងកែតម្រូវឱ្យកាន់តែប្រសើរឡើង។

# មាតិកា

## សេចក្តីផ្តើម

**ទំព័រ**

**១. លំនាំបញ្ហា**......១
**២. ចំណោទបញ្ហា**......១
**៣. គោលបំណងនៃការស្រាវជ្រាវ**......២
**៤. ដែនកំណត់នៃការស្រាវជ្រាវ**......២
**៥. សារៈសំខាន់នៃការស្រាវជ្រាវ**......២
**៦. វិធីសាស្ត្រនៃការស្រាវជ្រាវ**......៣
**៦.១ ការប្រមូលទិន្នន័យ**......៣
**៦.២ ការបកស្រាយ និង វិភាគទិន្នន័យ**......៣
**៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ**......៣

## ជំពូកទី១

## សញ្ញាណទូទៅប្រកាសនីយបត្រតក្កកម្មជាតិ និងអន្តរជាតិ

**១.១. សញ្ញាណទូទៅប្រកាសនីយបត្រតក្កកម្មជាតិ**......៥
១.១.១. និយមន័យ......៥
១.១.២. បុព្វហេតុនៃការកកើត......៥
១.១.៣. គោលបំណង និង កម្មវត្ថុនៃការបង្កើត......៥
១.១.៤. តក្កករ និង តក្កកម្ម......៦
១.១.៥ អត្ថប្រយោជន៍ប្រកាសនីយបត្រតក្កកម្ម......៧
**១.២. ប្រភេទប្រកាសនីយបត្រតក្កកម្ម**......៩
១.២.១. ប្រកាសនីយបត្រតក្កកម្មជាតិ......៩
១.២.២. ប្រកាសនីយបត្រតក្កកម្មបរទេស......៩
**១.៣. សញ្ញាណទូទៅប្រកាសនីយបត្រតក្កកម្មអន្តរជាតិ**......១១
១.៣.១. និយមន័យ......១១
១.៣.២. ប្រវត្តនៃការកកើតប្រកាសនីយបត្រតក្កកម្មអន្តរជាតិ......១១

១.៣.៣. គោលបំណង....................................................................................................១២

## ជំពូកទី២

## ការចុះបញ្ជីប្រកាសនីយបត្រតក្កកម្មជាតិ

**២.១. លក្ខខណ្ឌគ្រឹះនៃការចុះបញ្ជី**....................................................................................................១៤
២.១.១. ថ្មី....................................................................................................១៤
២.១.២. ជំហាននៃការរកឃើញថ្មី....................................................................................................១៥
២.១.៣. អាចអនុវត្តបានក្នុងឧស្សាហកម្មបាន....................................................................................................១៦
**២.២. លក្ខខណ្ឌទម្រង់នៃការចុះបញ្ជី**....................................................................................................១៧
២.២.១. ពាក្យសុំ....................................................................................................១៨
២.២.២. សេចក្ដីអត្ថាធិប្បាយ....................................................................................................១៩
២.២.៣. សេចក្ដីអះអាង....................................................................................................២០
២.២.៤. ខ្លឹមសារសង្ខេប....................................................................................................២០
២.២.៥. ការស្នើសុំបំបែកលិខិតស្នើសុំ....................................................................................................២១
២.២.៦. សមត្ថកិច្ចទទួលបន្ទុកពាក្យសុំ....................................................................................................២២
**២.៣. ការផ្ដល់ប្រកាសនីយបត្រតក្កកម្ម និងអនុភាពនៃការការពារ**....................................................................................................២២
២.៣.១. កាលបរិច្ឆេទនៃការចុះបញ្ជី....................................................................................................២២
២.៣.២. ការផ្សព្វផ្សាយជាសាធារណៈ....................................................................................................២៣
២.៣.៣. តក្កកម្មដែលមិនទទួលបានការការពារ....................................................................................................២៤
២.៣.៤. ការសម្រេចបដិសេធការផ្ដល់ប្រកាសនីយបត្រតក្កកម្ម....................................................................................................២៤
២.៣.៥. សិទ្ធិដែលកើតចេញពីប្រកាសនីយបត្រតក្កកម្ម....................................................................................................២៥
២.៣.៥.១. សិទ្ធិធ្វើអាជីវកម្មផ្ដាច់មុខ....................................................................................................២៥
២.៣.៥.២. ការធ្វើអាជីវកម្មដែលមិនស្ថិតនៅក្នុងវិសាលភាពនៃសិទ្ធិ....................................................................................................២៦
២.៣.៥.៣. សិទ្ធិអនុញ្ញាតឱ្យតតិយជនធ្វើអាជីវកម្មជំនួស និងអនុប្បទានសិទ្ធិ....................................................................................................២៧
២.៣.៥.៤. ការធ្វើអាជីវកម្មដោយរាជរដ្ឋាភិបាល ឬដោយបុគ្គលទទួលការអនុញ្ញាតពីរដ្ឋាភិបាល....២៩
២.៣.៦. អាជ្ញាយុកាលនៃសិទ្ធិការពារប្រកាសនីយបត្រតក្កកម្ម....................................................................................................៣០

**២.៤. ទោសបញ្ញត្តិ**..........៣១
២.៤.១. អំពើរំលោភសិទ្ធិ..........៣១
២.៤.២. យន្តការដោះស្រាយ..........៣២
២.៤.៣. មោឃភាព..........៣៣
២.៤.៤. ទណ្ឌកម្ម..........៣៣

**ជំពូកទី៣**

**ការចុះបញ្ជីប្រកាសនីយបត្រតក្កកម្មអន្តរជាតិ**

**៣.១. នីតិវិធីនៃការចុះបញ្ជី**..........៣៥
៣.១.១. ការដាក់ពាក្យស្នើសុំអន្តរជាតិ..........៣៥
៣.១.២. ការិយាល័យទទួល..........៣៧
៣.១.៣. ការស្រាវជ្រាវអន្តរជាតិ និង របាយការណ៍ស្រាវជ្រាវអន្តរជាតិ..........៣៩
៣.១.៣.១. ការស្រាវជ្រាវអន្តរជាតិ..........៤០
៣.១.៣.២. របាយការណ៍ស្រាវជ្រាវអន្តរជាតិ..........៤១
៣.១.៤. ការពិនិត្យជំហានដំបូងអន្តរជាតិ និងរបាយការណ៍ពិនិត្យជំហានដំបូងអន្តរជាតិ..........៤២
៣.១.៤.១. ការពិនិត្យជំហានដំបូងអន្តរជាតិ..........៤៣
៣.១.៤.២. របាយការណ៍ពិនិត្យជំហានដំបូងអន្តរជាតិ..........៤៥
៣.១.៤. ការចុះផ្សាយអន្តរជាតិ..........៤៦
៣.១.៦. ការត្រួតពិនិត្យថ្នាក់ជាតិ..........៤៧
**៣.២. ភាពដូច និង ភាពខុសគ្នារវាងប្រកាសនីយបត្រតក្កកម្មជាតិ និងអន្តរជាតិ**.....៤៨
**៣.៣. គុណសម្បត្តិ និង គុណវិបត្តិ**..........៤៩
**សេចក្ដីសន្និដ្ឋាន**..........៥១
**អនុសាសន៍**..........៥៣
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# តារាងអក្សរកាត់

| ល.រ | អក្សរកាត់ | ពាក្យពេញជាភាសាអង់គ្លេស | ពាក្យពេញជាភាសារខ្មែរ |
|---|---|---|---|
| ១ | WTO | World Trade Organization | អង្គការពាណិជ្ជកម្មពិភពលោក |
| ២ | WIPO | World Intellectual Property | អង្គការកម្មសិទ្ធិបញ្ញា ពិភពលោក |
| ៣ | PCT | Patent Cooperation Treaty | សន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម |
| ៤ | IPEA | International Preliminary Examining Authority | អជ្ញាធរត្រួតពិនិត្យបឋមអន្តរជាតិ |
| ៥ | BIRPI | United International Bureau for the Protection of Intellectual Property | ការិយាល័យអន្តរជាតិសម្រាប់ការការពារកម្មសិទ្ធិបញ្ញា |
| ៦ | BAT | Agreement between the United States of America and the Kingdom of Cambodia on Trade Relations and Intellectual Property Rights Protection | កិច្ចព្រមព្រមព្រៀងពាណិជ្ជកម្មរវាងសហរដ្ឋអាមេរិក និងព្រះរាជណាចក្រកម្ពុជាស្តីពីការការពារកម្មសិទ្ធិបញ្ញា |
| ៧ | BTA | Bilateral Trade Agreement | កិច្ចព្រមព្រៀងពាណិជ្ជកិច្ចទ្វេភាគី |
| ៨ | IP | Intellectual Property | កម្មសិទ្ធិបញ្ញា |
| ៩ | IPRs | Intellectual Property rights | សិទ្ធិកម្មសិទ្ធិបញ្ញា |

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

ព្រះរាជាណាចក្រកម្ពុជា គឺជាប្រទេសមួយដែលកំពុងអភិវឌ្ឍន៍ស្ទើរគ្រប់វិស័យ ហើយក៏ជាប្រទេសមួយដែលមានសន្តិភាព ឯករាជ្យភាព ពេញបូរិបូណ៌ ។ ព្រះរាជាណាចក្រកម្ពុជា កំពុងយកចិត្តទុកដាក់ទៅលើវិស័យជាច្រើនដូចជា វិស័យអប់រំ សុខាភិបាល ជាពិសេសទៅទៀតក៏បានយកចិត្តទុកដាក់លើវិស័យកម្មសិទ្ធិបញ្ញាផងដែរ។

យើងសង្កេតឃើញថា ប្រជាពលរដ្ឋកម្ពុជាមានការយកចិត្តទុកដាក់យ៉ាងខ្លាំងលើវិស័យកម្មសិទ្ធិបញ្ញា ពីព្រោះ ប្រជាពលរដ្ឋកម្ពុជាបានធ្វើការសិក្សា ស្វែងយល់នៃការច្នៃប្រឌិត បង្កើតនូវគំនិតស្នាដៃថ្មីៗ ដែលកើតចេញពីគំនិតបញ្ញារបស់មនុស្ស កើនឡើងជាបន្តបន្ទាប់។

ការការពារកម្មសិទ្ធិបញ្ញា គឺជាការលើកទឹកចិត្តទៅដល់អ្នកដែលបានបង្កើតនូវស្នាដៃថ្មី ឬការរកឃើញថ្មីមិនធ្លាប់មានពីមុនមក។ វិស័យកម្មសិទ្ធិបញ្ញាជា ២ ផ្នែកគឺ កម្មសិទ្ធិឧស្សាហកម្ម និង កម្មសិទ្ធិអ្នកនិពន្ធ។ អនុសញ្ញាបង្កើតអង្គការកម្មសិទ្ធិបញ្ញាពិភពលោក នៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៩៦៧ បានចែងថាកម្មសិទ្ធិបញ្ញាត្រូវរាប់បញ្ចូលនូវសិទ្ធិដែលទាក់ទងជាមួយនឹង ស្នាដៃអក្សរសាស្ត្រ សិល្បៈ និង វិទ្យាសាស្ត្រ ការសម្តែងរបស់សិល្បៈករ ភាគយន្ត និងបណ្តាញផ្សព្វផ្សាយ ការស្រាវជ្រាវ ផ្នែកវិទ្យាសាស្ត្រ ការច្នៃប្រឌិត ការបង្កើតថ្មី គំនូរឧស្សាហកម្ម ម៉ាក ការប្រឆាំងនិងអំពើប្រកួតប្រជែងមិនស្មោះត្រង់ ម៉ាកទីតាំងភូមិសាស្ត្រ ការបង្កាត់ពូជដំណាំថ្មី និង ប្រកាសនីយបត្រតក្កកម្ម។

ប្រកាសនីយបត្រតក្កកម្មផ្តល់នូវអត្ថប្រយោជន៍ជាច្រើនដែលធ្វើឱ្យប្រទេសជាច្រើនក្នុងពិភពលោកបានយកចិត្តទុកដាក់ ហើយនិងបានព្រមព្រៀងគ្នាបង្កើតនូវនីតិវិធីចុះបញ្ជីនៅទៅតាមប្រទេសរៀងៗខ្លួន និងមានការព្រមព្រៀងគ្នាបង្កើតនូវនីតិវិធីដើម្បីសម្របសម្រួលទៅដល់ការចុះបញ្ជីទទួលបានការការពារអន្តរជាតិ ។ ព្រះរាជាណាចក្រកម្ពុជាបានយកទឹកទុកដាក់យ៉ាងខ្លាំងលើសំណុំលិខិតស្នើសុំម្ចាស់តក្កកម្មទាំងអស់។ ហេតុដូចនេះហើយទើប ប្រទេសកម្ពុជា យើងបានចូលជាសមាជិក នៃសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មស្តីពីការចុះបញ្ជីប្រកាសនីយប្រតក្កកម្មអន្តរជាតិ នៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៦។

## ២. ចំណោទបញ្ហា

តាមការសិក្សាកម្មសិទ្ធិបញ្ញាកន្លងមកទាក់ទងនិង ប្រកាសនីយបត្រតក្កកម្មជាតិ និងអន្តរជាតិ យើងសង្កេតឃើញថាប្រទេសកម្ពុជា បានទាញនូវផលចំណេញពីការចុះបញ្ជីតក្កកម្មជាតិ និងអន្តរជាតិជាច្រើន ដែលប្រទេសកម្ពុជាជាសមាជិកនៃសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មនេះ ទើបក្រុមនាងខ្ញុំមានគំនិតក្នុងការសរសេរសារណានេះឡើងក្រោមប្រធានបទ " **នីតិវិធីនៃការចុះបញ្ជីប្រកាសនីយបត្រតក្កកម្មជាតិ និង អន្តរជាតិ**" ។ ជាហេតុដើម្បីឱ្យកាន់តែមានភាពស៊ីជម្រៅលើប្រធានបទនេះយើងសិក្សាអំពីបញ្ហា ៣ គឺ (១) តើលក្ខខណ្ឌ

ណាខ្លះដែលទទួលបានប្រកាសនីយបត្រតក្កកម្ម? (២) តើអានុភាពកើតចេញពីប្រកាសនីយបត្រតក្កកម្មមានអ្វីខ្លះ? និង (៣) តើនីតិវិធីនៃការចុះបញ្ជីប្រកាសនីយបត្រតក្កកម្មជាតិ និងអន្តរជាតិ តក្កករ ឬអ្នកដាក់ពាក្យសុំត្រូវបំពេញសំណុំបែបបទអ្វីខ្លះ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ដើម្បីឱ្យសារណា ឬ ការសិក្សាមានភាពជោគជ័យ និង លទ្ធិផលមានល្អ យើងគួរគប្បីកំណត់គោលបំណងឱ្យបានច្បាស់លាស់ជាមុនសិន គោលបំណងទាំងនោះរួមមាន៖

- ស្វែងយល់អំពីគោលបំណង ព្រមទាំងចរឹកលក្ខណៈរបស់ប្រកាសនីយបត្រតក្កកម្ម
- ស្វែងយល់អំពីលក្ខខណ្ឌនៃការផ្តល់ប្រកាសនីយបត្រតក្កកម្ម
- សិក្សាអំពីនីតិវិធីចុះបញ្ជីប្រកាសនីយបត្រតក្កម្ម
- សិក្សាអំពីការទទួលបានសិទ្ធិ និង អនុភាពពីប្រកាសនីយបត្រតក្កកម្ម
- ប្រៀបធៀបភាពដូច និង ភាពខុសគ្នារវាងប្រកាសនីយបត្រតក្កកម្មជាតិ និងអន្តរជាតិ
- គុណសម្បត្តិ និង គុណវិបត្តនៃប្រកាសនីយបត្រតក្កកម្ម។

## ៤. ដែនកំណត់នៃការស្រាវជ្រាវ

ក្នុងការសិក្សាស្រាវជ្រាវប្រធានបទស្តីពី **"នីតិវិធីនៃការចុះបញ្ជីប្រកាសនីយបត្រតក្កកម្មជាតិ និងអន្តជាតិ"** សារណានេះផ្តោតទៅលើការចុះបញ្ជីជាតិ និងអន្តរជាតិ ដោយការចុះបញ្ជីប្រកាសនីយបត្រតក្កកម្មជាតិអនុលោមទៅតាមច្បាប់ស្តីពី ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧហ្សាហកម្ម ឆ្នាំ២០០៣ នៃព្រះរាជាណាចក្រកម្ពុជា។ ការចុះបញ្ជីប្រកាសនីយបត្រតក្កកម្មអន្តរជាតិយោងតាម សន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម ដោយផ្អែកទៅលើឯកសារដែលមានជាក់ស្តែងតែប៉ុណ្ណោះ។ បន្ទាប់មកក្រុមនាងខ្ញុំយកមកធ្វើការសិក្សាវែកញែកស្រាវជ្រាវ និងបកស្រាយនូវសេចក្តីលម្អិតទាំងអស់ដែលជាប់ពាក់ព័ន្ធមួយប្រធានបទខាងលើ។

## ៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ បានជួយពង្រឹងការយល់ដឹងកាន់តែច្បាស់ជាមួយចំណេះដឹងទ្រឹស្តីការអនុវត្តន៍ជាក់ស្តែងពាក់ព័ន្ធទៅលើលក្ខខណ្ឌអនុវត្តនីតិវិធីប្រកាសនីយបត្រតក្កកម្មជាតិ និងអន្តរជាតិ។ មួយចំណែកទៀតគឺផ្តល់ការការពារ លើកទឹកចិត្តដល់តក្កករដែលបានរកឃើញ ឬ បង្កើតថ្មី ពុំធ្លាប់មានពីមុនមក និងដើម្បីជួយលើកស្ទួយវិស័យកម្មសិទ្ធិបញ្ញាឱ្យកាន់តែប្រសើរជាងមុនមួយកម្រិតទៀត។

ម្យ៉ាងវិញទៀត ការស្រាវជ្រាវមួយនេះ បានផ្តល់នូវតម្លៃអប់រំសំខាន់ដល់សង្គមជាតិ ដែលធ្វើឱ្យប្រព័ន្ធកម្មសិទ្ធិបញ្ញាមានភាពទូលំទូលាយ ជាមូលហេតុបណ្តាលឱ្យប្រជាពលរដ្ឋបានស្វែងយល់ និងបង្កើននូវចំណេះមួយ

កម្រិតទៀត ។ ពិសេសជាងនេះទៅទៀតការស្រាវជ្រាវនេះ និងផ្តល់ផលប្រយោជន៍ ចំណេះដឹង ដល់អ្នកសិក្សាជំនាន់ក្រោយ និងទុកជាឯកសារសម្រាប់ការស្រាវជ្រាវបន្ថែម ។

## ៦. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ

វិធីសាស្ត្រស្រាវជ្រាវនេះ គឺធ្វើឡើងតាមរបៀបស្វែងរក ពន្យល់ បកស្រាយ ប្រើឯកសារពាក់ព័ន្ធជាជំនួយក្នុងការបកស្រាយ និងបញ្ជាក់អត្ថន័យឱ្យបានកាន់តែច្បាស់។

### ១. ប្រមូលទិន្និន័យ

- ច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម ឆ្នាំ ២០០២
- សន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម ឆ្នាំ ២០១៦
- ប្រកាសស្តីពី ការគ្រប់គ្រង និងនីតិវិធីផ្តល់ប្រកាសនីយបត្រតក្កកម្ម និង វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ឆ្នាំ២០១៦
- សៀវភៅសារណា នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
- ឯកសារបានមកពីការស្វែងរកបានតាមប្រព័ន្ធអ៊ីនធើណេត បណ្ណាល័យ សៀវភៅមេរៀន និងឯកសារតាមស្ថាប័នានា។

### ២. ការបកស្រាយ និង វិភាគ

បន្ទាប់ពីឆ្លងកាត់ប្រមូលទិន្នន័យរួចហើយ ក្រុមយើងខ្ញុំបានធ្វើការជ្រើសរើសទិន្នន័យដែលពាក់ព័ន្ធខ្លឹមសារសំខាន់មកវែកញែកពិភាក្សាបកស្រាយ លើអត្ថន័យក្នុងការចុះបញ្ជីនីតិវិធីលក្ខណ្ឌទទួលបានការការពារប្រកាសនីយ បត្រតក្កកម្មព្រមទាំងបញ្ញត្តិសម្រាប់ផ្តន្ទាទោសចំពោះអំពើរំលោភបំពានលើប្រកាសនីយបត្រតក្កម្ម ដែលចែងបាន ក្នុងច្បាប់ព្រះរាជាណាចក្រកម្ពុជា។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

អត្ថបទសារណាក្រោមប្រធាន " នីតិវិធីនៃការចុះបញ្ជីប្រកាសនីយបត្រតក្កកម្មជាតិ និងអន្តរជាតិ" ត្រូវបានបែងចែកចេញជា ៥ ផ្នែកធំៗដូចខាងក្រោម៖

- **សេចក្តីផ្តើម** ជាផ្នែកផ្តើមដំបូងគេដែលរៀបរាប់អំពីលំនាំបញ្ហា ចំណោទបញ្ហា គោលបំណងនៃការស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ ព្រមទាំងវិធីសាស្ត្រនៃការស្រាវជ្រាវ ។
- **ជំពូកទី១ សញ្ញាណទូទៅនៃការចុះបញ្ជីប្រកាសនីយបត្រតក្កកម្ម** ក្នុងផ្នែកនេះនិយាយពាក់ព័ន្ធទៅនិង និយមន័យ បុព្វហេតុនៃការកកើត គោលបំណង សញ្ញាណទូរទៅរបស់ប្រកាសនីយបត្រតក្កកម្មជាតិ និងអន្តរជាតិ ព្រមទាំង ការបែងចែកប្រកាសនីយបត្រតក្កម្ម។

- **ជំពូកទី២ ការអនុវត្តន៍ការចុះបញ្ជីប្រកាសនីយបត្រតក្កកម្មជាតិ** ក្នុងផ្នែកនេះដែលយើងសិក្សាអំពីលក្ខខណ្ឌនៃការចុះបញ្ជី ការផ្តល់ប្រកាសនីយបត្រតក្កកម្ម និងអានុភាពដែលទទួលបាន និងសិក្សាអំពីទោសបញ្ញត្តិអំពីការរំលោភបំពានប្រកាសនីយបត្រតកក្កកម្ម។
- **ជំពូកទី៣ ទិដ្ឋភាពទូទៅនៃការចុះបញ្ជីប្រកាសនីយបត្រតក្កកម្មអន្តរជាតិ** ក្នុងផ្នែកនេះដែលយើងសិក្សាអំពី ការដាក់ពាក្យស្នើសុំអន្តរជាតិ ការប្រៀបធៀបចំណុចដូច និងខុសគ្នារវាងប្រកាសនីយបត្រតក្កកម្មជាតិ និងអន្តរជាតិ និងគុណសម្បត្តិ គុណវិបត្តិប្រកាសនីយបត្រតក្កកម្មអន្តរជាតិ ។
- **សេចក្តីសន្និដ្ឋាន និងអនុសាសន៍** ចំណុចនេះជាផ្នែកចុងក្រោយនៃសារណាដែលសរុបសេចក្តីបញ្ចូល ខ្លឹមសារឡើងវិញលទ្ធផលដែលបានធ្វើ ការស្រាវជ្រាវ និងបង្ហាញអនុសាសន៍ដែលជាដំណោះស្រាយបញ្ហាដែលបានកើតឡើងចំពោះការចុះបញ្ជីប្រកាសនីយបត្រតក្កកម្មជាតិ និងអន្តរជាតិ។

# ជំពូកទី ១
# សញ្ញាណទូទៅនៃ
# ប្រកាសនីយបត្រតក្កកម្ម

# ជំពូកទី ១

# សញ្ញាណទូទៅនៃប្រកាសនីយបត្រតក្កកម្មជាតិ និងអន្តរជាតិ

## ១.១. សញ្ញាណទូទៅនៃប្រកាសនីយបត្រតក្កកម្មជាតិ

អ្វីជាប្រកាសនីយបត្រតក្កកម្ម? គឺជាផ្នែមួយនៃកម្មសិទ្ធិបញ្ញាដែលសិក្សាអំពី បុព្វហេតុនៃការកកើត គោលបំណងនៃការបង្កើតប្រកាសនីយបត្រតក្កកម្ម ដែលផ្តល់អត្ថប្រយោជន៍ដល់ម្ចាស់តក្កកម្ម។

### ១.១.១. និយមន័យ

ប្រកាសនីយបត្រតក្កកម្ម គឺជាវិញ្ញាបនបត្រដែលបានផ្តល់ការការពារតក្កកម្មដែលចេញដោយការិយាល័យរបស់រដ្ឋាភិបាលណាមួយ ឬការិយាល័យសម្រាប់តំបន់ណាមួយដែលដើរតួនាទីក្នុងនាមរដ្ឋច្រើន ហើយវាអាស្រ័យទៅតាមការដាក់ពាក្យសុំ។

### ១.១.២. បុព្វហេតុនៃការកកើត

ប្រកាសនីយបត្រតក្កកម្មបានចាប់កំណើត និងមានការវិវត្តន៍អស់រយៈពេលជាច្រើនឆ្នាំកន្លងមកហើយ ប៉ុន្តែគេសង្កេតឃើញ មានទ្រង់ទ្រាយច្បាស់លាស់ ក្នុងការប្រគល់នូវប្រកាសនីយបត្រតក្កកម្មនៅក្នុងឆ្នាំ១៧០០ ដោយមានចែងក្នុងរដ្ឋធម្មនុញ្ញសហរដ្ឋអាមេរិកដែលផ្តល់អំណាចដែលសភាCongress ក្នុងការការពារប្រកាសនីយបត្រតក្កកម្ម និងស្នាដៃនិពន្ធ។ សព្វថ្ងៃនេះប្រព័ន្ធប្រកាសនីយបត្រតក្កកម្ម ត្រូវបានអភិវឌ្ឍន៍ឱ្យក្លាយទៅជាប្រព័ន្ធអន្តរជាតិមួយយ៉ាងទំនើបដោយប្រកាសនីយបត្រតក្កកម្ម នេះត្រូវបានការពារតាមរយៈសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម Patent Cooperation Treaty(PCT)។

ការចាប់កំណើតប្រកាសនីយបត្រតក្កកម្ម នៅកម្ពុជាទើបតែមានការយកចិត្តទុកដាក់ អំពីបញ្ហានេះក្នុងអំឡុកពេលដែលកម្ពុជាត្រៀម ចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោកតែប៉ុណ្ណោះ។ ជាលទ្ធផលកម្ពុជាបានបង្កើតច្បាប់ស្តីពី ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម ដែលមានអនុម័តនៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៣។ ច្បាប់នេះពាក់ព័ន្ធនិងអ្វីដែលគេហៅថាកម្មសិទ្ធិបញ្ញាផ្នែកឧស្សាហកម្ម។

### ១.១.៣. គោលបំណង និងកម្មវត្ថុនៃការបង្កើត

- <u>**កម្មវត្ថុនៃច្បាប់ប្រកាសនីយបត្រតក្កកម្ម**</u>

ដើម្បីទទួលបាននូវប្រកាសនីយបត្រតក្កកម្ម តក្កកម្មនេះដាច់ខាតត្រូវតែបំពេញឱ្យបានគ្រប់លក្ខខណ្ឌដែលច្បាប់បានកំណត់។ ជាទូទៅកម្មវត្ថុនោះ ត្រូវតែ ស្របច្បាប់ ហើយវាត្រូវតែបង្កើតថ្មីដែលចេញពីគំនិតបញ្ញារបស់មនុស្ស ផលិតចេញមកត្រូវតែស្របច្បាប់ និងដែលវាមានផលប្រយោជន៍សម្រាប់ការប្រើប្រាស់ ជាពិសេស

អាចយកទៅធ្វើអាជីវកម្មបាន។ តក្កកម្មនោះនឹងមិនត្រូវទទួលបាននូវការការពារតាមរយៈប្រកាសនីយបត្រតក្កកម្មទេប្រសិន បើការរកឃើញនោះជាការរកឃើញនូវវត្ថុធាតុដើម ឬក៏ជាសារធាតុដែល មានស្រាប់ក្នុងធម្មជាតិ។

- **<u>គោលបំណងនៃច្បាប់ប្រកាសនីយបត្រតក្កកម្ម</u>**
  - លើកទឹកចិត្តចំពោះការច្នៃប្រឌិតថ្មី និងចំពោះការស្រាវជ្រាវ និងការអភិវឌ្ឍន៍វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា
  - ជំរុញ និងលើកទឹកចិត្តការធ្វើពាណិជ្ជកម្ម ក្នុងស្រុកនិងក្រៅប្រទេស និងការវិនិយោគ
  - លើកទឹកចិត្តចំពោះការផ្ទេរបច្ចេកវិទ្យាមកក្នុងព្រះរាជាណាចក្រកម្ពុជាដើម្បីជួយសម្របសម្រួលសកម្មភាពឧស្សាហកម្ម និងការអភិវឌ្ឍន៍សេដ្ឋកិច្ច
  - ផ្តល់ការការពារចំពោះសិទ្ធិនៃកម្មសិទ្ធិឧស្សាហកម្ម និងការប្រឆាំងចំពោះការរំលោភសិទ្ធិខាងលើក៏ដូចជាប្រឆាំង និងការធ្វើជំនួញដោយមិនស្របច្បាប់។

### ១.១.៤.តក្កករ និង តក្កកម្ម

**តក្កករ** គឺសំដៅលើអ្នកដែលបានបង្កើតស្នាដៃ អ្នកដែលរកឃើញផលិតផលថ្មី ឬ ដំណើរការផលិតកម្ម ឬ អាចជាការរកឃើញអ្វីមួយ ដែលទាក់ទងទៅនឹងផលិតផល ឬ ដំណើការផលិតកម្ម ។[1] មួយវិញទៀត តក្កករ សំដៅលើសិទ្ធិជាម្ចាស់នៃប្រកាសនីយបត្រតក្កកម្ម គឺជាកម្មសិទ្ធិរបស់តក្កករ ដែលជាអ្នកបង្កើតស្នាដៃ និង យកទៅចុះបញ្ជីបានមុនគេ។

**តក្កករ** ជាបុគ្គលដែលបង្កើតស្នាដៃ ដូចជា និយោជិតរបស់សហគ្រាស កម្មសិក្សាការី ឬអាចជាមន្ត្រីនៅក្នុងជំនាញផលិតកម្ម នៃស្ថាប័នរដ្ឋ។

- **តក្កកម្មរបស់និយោជិត** តាមរយៈកិច្ចសន្យាការងារ និយោជិតមានចំណង ក្រោមបង្គាប់បញ្ជារបស់និយោជក មានន័យថានិយោជិត មានកាតព្វកិច្ចបំពេញការងារ ដែលនិយាយបានប្រគល់ឱ្យស្របតាមច្បាប់កិច្ចសន្យា និងច្បាប់ការងារ។ ក្នុងករណីនេះ ជាគោលការណ៍ តក្កកម្មដែលកើតចេញពីបេសកម្ម ឬ សេវាកម្មក្នុងក្របខណ្ឌនៃ កិច្ចសន្យាការងារ តក្កកម្មនោះជាកម្ម សិទ្ធិរបស់និយោជក (មាត្រា ១៤ នៃ ច្បាប់ប្រកាសនីយបត្រតក្កកម្ម)។ផ្អែកតាមបទប្បញ្ញត្តិខាងលើ យើងទាញចេញជាគោលការណ៍នៃសច្ចធារណ៍ តាមច្បាប់ បានចែងថា រាល់តក្កកម្ម ទាំងអស់ត្រូវចាត់ទុកជាកម្មសិទ្ធិរបស់និយោជក ប្រសិនបើតក្កកម្មនោះត្រូវបានបង្កើតឡើង ៖
  - ក្នុងម៉ោងធ្វើការ

[1] មាត្រា ៣ ច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម ។

- ក្នុងក្របខណ្ឌសកម្មភាពការងារ
- ដោយការប្រើប្រាស់មធ្យោបាយរបស់សហគ្រាស។

➢ **តក្កកម្មរបស់កម្មសិក្សាការី** ជាគោលការណ៍កម្មសិក្សាការីមិនស្ថិតនៅក្រោមរបបគិតយុត្តដូចនិយោជិតនោះទេ ។ ច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៧ នៃប្រទេសកម្ពុជា ពុំបានកំណត់អំពី លក្ខខណ្ឌ នៃការបញ្ចប់កម្មសិក្សាតែប៉ុណ្ណោះ។[2] នៅក្នុងអនុវត្តកម្ពុជា ពុំទាន់មានដំណោះស្រាយនោះឡើយទេ។ ក្នុងករណីនេះប្រសិនបើច្បាប់អនុវត្តមានក្នុងកំណត់បញ្ញត្តិពាក់ព័ន្ធ វាជាសេរីភាពរបស់គូភាគី ដែលត្រូវកំណត់លក្ខខណ្ឌជាក់លាក់ នៅក្នុងកិច្ចសន្យា (រវាងអ្នកដឹកនាំកម្មសិក្សា និង កម្មសិក្សាការី )។

➢ **តក្កកម្មរបស់មន្ត្រី** ក្នុងក្របខណ្ឌគិតយុត្តកម្ពុជា ពុំមានបទប្បញ្ញត្តិណាមួយកំណត់អំពីម្ចាស់សិទ្ធិលើតក្កកម្ម ដែលត្រូវបង្កើតឡើងដោយមន្ត្រីសាធារណៈ ដែលមានជំនាញ និងគ្រប់គ្រងវិស័យបច្ចេកវិទ្យាណាមួយនោះទេ។[3]

➢ **តក្កកម្ម** គឺសំដៅលើគំនិតរបស់តក្កករ ដែលអាចយកទៅអនុវត្តបាន ក្នុងដំណោះស្រាយបញ្ហាជាក់លាក់ណាមួយ ក្នុងវិស័យបច្ចេកវិជ្ជា។[4] មួយវិញទៀត តក្កកម្ម គឺជាផលិតផល ដែលកើតចេញពីគំនិតបញ្ញាផ្ទាល់ របស់តក្កករហើយអាចយកទៅអនុវត្តបានក្នុងវិស័យឧស្សាហកម្ម។ តាមន័យគតិយុត្ត ក៏ដូចជាក្នុងករណី នៃស្នាដៃនិពន្ធ ដែលជាតក្កកម្ម គឺត្រូវតែជាផលិតផល នៃគំនិតប្រាជ្ញាផ្ទាល់របស់ តក្កករ ដែលជាអ្នកបង្កើតវា។ ប៉ុន្តែនេះពុំមានន័យថា គ្រប់ផលិតផលនៃគំនិតរបស់ តក្កករ ទាំងអស់សុទ្ធសឹងតែអាចចាត់ទុកថាជា តក្កកម្មបាននោះទេ ពោលលុះត្រាតែគំនិតរបស់ស្នាដៃទាំងអស់នោះ អាចបំពេញតាមលក្ខខណ្ឌទាំងឡាយដែលច្បាប់បានកំណត់ផង និង ត្រូវតែស្ថិតនៅក្នុងវិស័យ ដែលច្បាប់ ទទួលស្គាល់ទៀតផង ពោលគឺ តក្កកម្មនោះជាតក្កកម្មដែលមិនពាក់ព័ន្ធ ក្នុងវិស័យ ឧស្សាហកម្ម ត្រូវការពារដោយច្បាប់ ដោយឡែក ក្នុងមាត្រា ៤ និង មាត្រា ៩។[5]

### ១.១.៥. អត្ថប្រយោជន៍នៃប្រកាសនីយបត្រតក្កកម្ម

ទោះបីជាការទទួលបានប្រកាសនីយបត្រតក្កកម្មនេះពីរដ្ឋតម្រូវឱ្យតក្កករជាប់កាតព្វកិច្ចមួយចំនួនក៏ដោយ ប៉ុន្តែច្បាប់ប្រភេទនេះគឺជា ប្រភពអត្ថប្រយោជន៍ជាច្រើនដល់តក្កករកាលបើបានធ្វើជាម្ចាស់របស់វាផងដែរ។ ក្រៅ

---

2 សៀវភៅ នីតិកម្មសិទ្ធិបញ្ញា សាស្ត្រាចារ្យ ទេព សុខ ទំព័រ២២ ឆ្នាំ២០២០-២០២១ ។

3 សៀវភៅ នីតិកម្មសិទ្ធិបញ្ញា សាស្ត្រាចារ្យ ទេព សុខ ទំព័រ២២ ឆ្នាំ២០២០-២០២១ ។

4 ច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម មាត្រា ៣ កថាខណ្ឌ១ ។

5 សៀវភៅ នីតិកម្មសិទ្ធិបញ្ញា សាស្ត្រាចារ្យ ទេព សុខ ទំព័រទី ២៣ ឆ្នាំ២០២០-២០២១ ។

ពីទទួលសិទ្ធិក្នុងការធ្វើអាជីវកម្មលើតក្កកម្ម ដែលច្បាប់បានប្រគល់ដល់ម្ចាស់នៃប្រកាសនីយបត្រតក្កកម្មនោះក៏មានអត្ថប្រយោជន៍ជាច្រើនទៀតដែលម្ចាស់នៃតក្កកម្មអាចទទួលបានពីការសុំប្រកាសនីយបត្រតក្កកម្មនេពីរដ្ឋ។

ប្រកាសនីយបត្រតក្កកម្ម អាចត្រូវបានចាត់ទុកដូចជាការធានាមួយរបស់រដ្ឋដើម្បីប្រឆាំងទៅនឹងអំពើនៃការក្លែងបន្លំទាំងឡាយណា ចំពោះតក្កកម្មដែលជាកម្មវត្ថុនៃប្រកាសនីយបត្រតក្កកម្មឱ្យដល់តក្ករ។ អំពើនៃការក្លែងបន្លំ គឺសំដៅដល់រូបភាពនៃអំពើទាំងឡាយណា ដែលបំពានដល់សិទ្ធិលើតក្កកម្មនៃម្ចាស់ប្រកាសនីយបត្រតក្កកម្មនេះ ទាំងលើផលិតផល ឬដំណើរការផលិតផលដែលតក្ករនោះបានចុះបញ្ជី និងទាំងលើមធ្យោបាយនានាដែលត្រូវប្រើប្រាស់សម្រាប់ជាជំនួយដល់ការផលិត ឬដំណើការផលិតកម្មនោះផងទៀត។ មួយវិញទៀតដោយសារវត្តមាន នៃប្រកាសនីយបត្រតក្កកម្មនេះទើបអំពើនៃការក្លែងបន្លំអាចនឹងត្រូវផ្តន្ទាទោសតាមច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្មជាមិនខាន ។[៦] ពិសេសលើសពីនេះទៅទៀតការប្រកាសនីយបត្រតក្កកម្ម ត្រូវបានទទួលស្គាល់ និងការការពារដោយច្បាប់ រាល់ពេលមានការបំពាន ការលួចចម្លង និងការផ្តល់ភាពងាយស្រួល ក្នុងការតតាំងជាមួយតតិយជន។

ប្រកាសនីយបត្រតក្កម្មនេះដែរ ក៏ពិតជាអាចជម្រុញដល់ការលើកម្ពស់អភិវឌ្ឍសេដ្ឋកិច្ចរបស់សហគ្រាសបាន ពីព្រោះប្រកាសនីយបត្រតក្កម្មនេះ ត្រូវបានចាត់ទុកជាធាតុផ្សំមួយនៃទ្រព្យសកម្មនៃសហគ្រាស និងជាប្រភពផ្ទាល់នៃការទាក់ទាញអ្នកបណ្តាក់ទុន ដើម្បីបង្កើនអ្នកវិនិយោគរបស់សហគ្រាសនេះកាន់តែច្រើនឡើង។ មួយវិញទៀតវាមានសារៈប្រយោជន៍ខាងសេដ្ឋកិច្ចរបស់សហគ្រាស ឬ អាជីវកម្មរបស់ម្ចាស់ប្រកាសនីយបត្រតក្កកម្មនេះដូចជា ជួយសម្រួលដល់ការផ្ទេរបច្ចេកវិទ្យាសម្រាប់ក្នុងការវិនិយោគទុនរបស់សហគ្រាស ម្យ៉ាងទៀតប្រកាសនីយបត្រតក្កកម្មនេះ ក៏បានជួយលើទឹកចិត្តដល់ម្ចាស់តក្កកម្មមានការខិតខំសិក្សាស្រាវជ្រាវបន្ថែម ស្វែងរកអ្វីដែលថ្មី ដើម្បីឱ្យមានការអភិវឌ្ឍន៍បន្តបន្ទាប់ទៀត ពោលគឺប្រកាសនីយបត្រតក្កកម្មនេះជាចំណែកមួយជួយសម្រួលដល់ ការពន្លឿនដល់ការបង្កើតបច្ចេកវិទ្យាថ្មីៗ ក៏ដូចជាការបង្កើតមុខជំនួញថ្មីៗដល់សហគ្រាសទៀតផង ។ មួយវិញទៀតប្រកាស នីយបត្រតក្កកម្ម គឺជាកូនសោរមួយដ៏សំខាន់ នៅក្នុងកិច្ចសហការគ្នាលើវិស័យជំនួញដែលទាញយកពីផលប្រយោជន៍នៃការទទួលប្រកាសនីយបត្រតក្កកម្ម គឺម្ចាស់ប្រកាសនីយបត្រតក្កកម្មមានសិទ្ធិផ្តាច់មុខនៅលើវង្វង់ដែនដីរបស់ខ្លួនតាមរយៈការប្រើប្រាស់ ការលក់ ឬការនាំចូលនៃតក្កកម្ម។ ក្នុងនោះដែលប្រកាសនីយបត្រតក្កកម្មមានអត្ថប្រយោជន៍ដូចជា **ជម្រុញការបង្កើតថ្មី និងអភិវឌ្ឍន៍បច្ចេកវិទ្យា និង សិទ្ធិផ្តាច់ មុខ និង ឧត្តមភាព ទីផ្សារ**។ ប្រកាសនីយបត្រតក្កកម្ម ក៏បានផ្តល់នូវផលចំណូលត្រឡប់មកវិញចំពោះការ វិនិយោគដែលបានបោះទុន វិនិយោគ ជាប្រាក់ និង ពេលវេលាមួយចំនួនធំ ក្នុងការបង្កើតផលិតផល ប្រកបដោយគំនិតច្នៃ

[៦] សៀវភៅ នីតិកម្មសិទ្ធិបញ្ញា សាស្ត្រាចារ្យ កាន់ សុទ្ធប៉ូលីន ទំព័រ ១៩២ ឆ្នាំ២០១៤ ។

ប្រឌិត អាជីវកម្មរបស់ម្ចាស់ស្នាដៃ អាចធ្វើពាណិជ្ជកម្មលើគំនិតច្នៃប្រឌិតនោះ ក្រោមផ្លាកសិទ្ធិផ្តាច់មុខទាំងនោះ ហើយអាចឱ្យអាជីវកម្មរបស់ម្ចាស់ស្នាដៃ ទទួលបាននូវផលចំណូលខ្ពស់ជាងរបស់ម្ចាស់ស្នាដៃទទួលបាននូវផលចំណូលខ្ពស់ជាងមុនអំពីការវិនិយោគលើតក្កកម្មនេះ។[7]

ប្រកាសនីយបត្រតក្កម្មក៏ចាត់ទុកដូចជាយុទ្ធសាស្ត្រ មួយដ៏ល្អប្រសើរបំផុត ក្នុងការផ្សព្វផ្សាយកេរ្តិ៍ឈ្មោះ និង ដើម្បីពង្រឹងនីត្យានុភាពរបស់សហគ្រាសដែលជាម្ចាស់ប្រកាសនីយបត្រតក្កកម្ម ទៅដល់បណ្តាលសាធារណៈជនក៏ដូចអតិថិជន និងដៃគូរប្រកួតប្រជែងរបស់សហគ្រាសនោះផងដែរ។ ស្ថិតក្នុងភាពជាម្ចាស់ស្នាដៃប្រកាសនីយបត្រតក្កកម្មនេះ សហគ្រាសទាំងឡាយរមែងមានឥទ្ធិពលខ្ពស់ជាងគេ នៅក្នុងទំនាក់ទំនងពាណិជ្ជកម្មមួយនឹងដៃគូនានារបស់ខ្លួនជានិច្ច។

ប្រកាសនីយបត្រតក្កម្ម ផ្តល់នូវសិទ្ធិផ្តាច់មុខចំពោះម្ចាស់ស្នាដៃចំពោះស្នាដៃរបស់ខ្លួនដែលបានរកឃើញ និង បានចុះបញ្ជីបានត្រឹមត្រូវតាមលក្ខខណ្ឌកំណត់ ជាធម្មតាច្បាប់អនុញ្ញាតឱ្យ ប្រើប្រាស់អាជីវកម្មលើតក្កកម្មបានរយៈពេល ២០ឆ្នាំ គិតតាំងពីកាលបរិច្ឆេទ នៃការដាក់ពាក្យសុំចុះបញ្ជីប្រកាសនីយបត្រតក្កម្ម។[8]

## ១.២.ប្រភេទនៃប្រកាសនីយបត្រតក្កកម្មជាតិ

ប្រកាសនីយបត្រតក្កម្ម តាមច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ការស្នើសុំប្រកាសនីយបត្រតក្កកម្មត្រូវបានបែកចែកជា ២ផ្នែកគឺ ការស្នើសុំប្រកាសនីយបត្រតក្កកម្មជាតិ និង ការស្នើសុំប្រកាសនីយបត្រត្កកម្មបរទេស។

### ១.២.១.ប្រកាសនីយបត្រតក្កកម្មជាតិ

ប្រកាសនីយបត្រតក្កកម្មជាតិ គឺសំដៅលើការរកឃើញនូវស្នាដៃថ្មីទាំងឡាយណា ដែលបានរកឃើញស្ថិតនៅក្នុងប្រទេសដែលបានស្នើសុំប្រកាសនីយបត្រតក្កកម្ម ហើយសំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្មនេះ គេហៅថាសំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្មជាតិ ដែលបែបបទក្នុងការស្នើសុំចុះបញ្ជីត្រូវអនុលោមតាមច្បាប់អ្នកកំណត់ ជាទូទៅនៅពេលដែលតក្កកម្មមួយដែលបានរកឃើញត្រូវចាំបាច់ស្នើសុំការការពារដោយច្បាប់ ចំពោះបែបបទក្នុងការស្នើសុំម្ចាស់តក្កកម្មត្រូវបំពេញរួមមាន ពាក្យសុំ សេចក្តីអត្ថាធិប្បាយ សេចក្តីអះអាង និង ខ្លឹមសារសង្ខេប។

### ១.២.២.ប្រកាសនីយបត្រតក្កកម្មបរទេស

ប្រកាសនីយបត្រតក្កកម្មបរទេស គឺសំដៅលើតក្កកម្ម ដែលបានរកឃើញមិនស្ថិតនៅក្នុងប្រទេសដែលបានដាក់ពាក្យស្នើសុំចុះបញ្ជីប្រកាសនីយបត្រប្រកាសនីយបត្រតក្កកម្មឡើយ។ ប្រកាសនីយបត្រតក្កកម្មដែល

[7] សៀវភៅ នីតិកម្មសិទ្ធិបញ្ញា សាស្ត្រាចារ្យ ទេព សុខ ទំព័រ ១៨ និង ១៩ ឆ្នាំ ២០២០-២០២១ ។

[8] ច្បាប់ស្តីពី ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម មាត្រា ៤៥ ។

ទទួលបានការការពារនៅក្នុងប្រទេសមិនមែនមានន័យថា មានវិសាលភាពការការពារទូរទាំងពិភពលោកនោះទេ គឺវាមានវិសាលភាពទទួលបានការការពារត្រឹមតែដែនដីដែល តក្កករ បានស្នើសុំចុះបញ្ជីប៉ុណ្ណោះ។ ប្រសិនបើម្ចាស់ស្នាដៃ ចង់ទទួលបានការការពារនូវកន្លែង ឬ ប្រទេសណាមួយផ្សេងទៀត ម្ចាស់ស្នាដៃនោះត្រូវតែ ធ្វើការស្នើសុំចុះបញ្ជីនោះឱ្យស្របទៅតាមលក្ខខណ្ឌនៃប្រទេសនីមួយៗ។ **ឧទាហរណ៍:** ការរកឃើញឡានមួយប្រើប្រាស់ដោយអគ្គីសនីមួយៗបានចុះបញ្ជីការពារនៅប្រទេសជប៉ុន ឡាននោះអាចការពារនៅប្រទេសកម្ពុជាបានលុះត្រាតែតក្កកម្មនោះបានចុះបញ្ជីនៅកម្ពុជា។ ករណីពិសេសមួយទៀតគេអាចការពារជាលក្ខណៈអន្តរជាតិបានដោយសារតែបញ្ហាកម្មសិទ្ធិបញ្ញាមាន អង្គការពីរដែលតែងតែយកចិត្តទុកដាក់អំពីបញ្ហានេះគឺ អង្គការពាណិជ្ជកម្មពិភពលោក World Intellectual Property Organization (WTO) និង អង្គការកម្មសិទ្ធិបញ្ញាពិភពលោក (WIPO) តែអង្គការដែលគ្រប់គ្រងលើកម្មសិទ្ធិបញ្ញា គឺអង្គការ (WIPO)។ រាល់សមាជិករបស់អង្គការ (WIPO) ត្រូវទទួលស្គាល់នូវការការពារនេះ ពោលគឺគ្រប់ប្រទេសដែលជាសមាជិករបស់អង្គការ (WIPO) ត្រូវទទួលស្គាល់អានុភាពការការពារនេះ ទោះបីតក្កករមិនបានចុះបញ្ជីនេះប្រទេសខ្លួនក៏ដោយ ក្នុងករណីនេះមិនអនុវត្តទៅលើប្រទេសដែលមិនមែនជាសមាជិករបស់ (WIPO) ឡើយ។ ប៉ុន្តែអ្វីជាបញ្ហាចោទត្រង់លក្ខខណ្ឌ មូលដ្ឋានគ្រឹះដែលទាមទារក្នុងការចុះបញ្ជីគឺថា ប្រសិនបើប្រទេសណាមួយចង់តម្កល់តក្កកម្មរបស់ខ្លួននៅប្រទេសកម្ពុជា គឺត្រូវគោរពលក្ខខណ្ឌដែលបានកំណត់នៅប្រទេសកម្ពុជា ។ ត្រង់ចំណុចនេះដែលអ្នកដែលបានដាក់ពាក្យសុំត្រូវបង្ហាញពីសិទ្ធិអាទិភាពនៃសំណុំលិខិតស្នើសុំដែលបានចុះបញ្ជីមុនគេនៅប្រទេសណាមួយឬតំបន់ណាមួយ។

អ្នកដាក់ពាក្យសុំ ត្រូវផ្តល់ជូនដល់មន្ត្រីកាន់កាប់បញ្ជីនូវកាលបរិច្ឆេទ និងលេខនៃសំណុំលិខិតស្នើសុំទាំងឡាយ ដែលខ្លួនបានដាក់នៅឯបរទេស ហើយដែលវាពាក់ព័ន្ធទៅនឹងតក្កកម្មដូចគ្នា ឬ ស្ទើរតែដូចគ្នាដែលបានអះអាងនៅក្នុងសំណុំលិខិតស្នើសុំ។[៩]

អ្នកស្នើសុំប្រកាសនីយបត្រតក្កកម្មបរទេស ត្រូវបំពេញសំណុំបែបទមួយចំនួនដូចខាងក្រោមៈ

- ភ្ជាប់មកជាមួយឯកសារចម្លងនៃលិខិតឆ្លើយឆ្លង ដែលពាក់ព័ន្ធទៅនឹងលទ្ធផលនៃការស្រាវជ្រាវ ឬ លទ្ធផលនៃការត្រួតពិនិត្យសំណុំលិខិតស្នើសុំនៅឯបរទេស ដែលអ្នកដាក់ពាក្យសុំបានទទួល។
- ឯកសារចម្លងនៃប្រកាសនីយបត្រតក្កកម្ម ដែលបានផ្តល់ឱ្យតាមការដាក់ពាក្យសុំនៅបរទេស។
- ជនបរទេស ឬ ការបដិសេធមិនផ្តល់ជូននូវប្រកាសនីយបត្រតក្កកម្មតាមសំណើលិខិតនៃសំណុំលិខិតការស្នើសុំនោះ។[10]

[៩] ច្បាប់ស្តីពី ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម មាត្រា ៣០ ។

[10] ច្បាប់ស្តីពី ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម មាត្រា ៣១ ។

## ១.៣. សញ្ញាណទូទៅនៃប្រកាសនីយបត្រតក្កកម្មអន្តរជាតិ

ដើម្បីកាន់តែយល់ច្បាស់ ស៊ីជម្រៅ យើងគួរគប្បីសិក្សាទៅលើនិយមន័យ ប្រវត្តនៃការកកើត ដែលជាហេតុនាំឱ្យបង្កើតនូវប្រកាសនីយបត្រតក្កកម្មអន្តរជាតិ ដោយអនុលោមសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មអន្តរជាតិ (PCT) ដូចទៅ៖

### ១.៣.១. និយមន័យ

ប្រកាសនីយបត្រតក្កកម្ម តាមរយៈសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម (PCT) ជាសន្ធិសញ្ញាមួយដែលផ្តល់ជាមូលដ្ឋានគ្រឹះសម្រាប់រៀបចំបែបទពាក្យស្នើសុំប្រកាសនីយបត្រតក្កកម្ម និង ផ្តល់ឱ្យតក្កករនូវការការពារបាន ប្រកាសនីយបត្រតក្កកម្មនៅក្នុងប្រទេសច្រើននៅជុំវិញពិភពលោកលើគោលការណ៍ពាក្យស្នើសុំប្រកាសនីយបត្រតក្កកម្មតែមួយ។[11] សន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម ជួយសម្រួលនូវនីតិវិធីសម្រាប់តក្កករ ឬអ្នកស្នើសុំប្រកាសនីយបត្រតក្កកម្ម គោលបំណងមួយក្នុងគោលបំណងជាច្រើនគឺជម្រុញការផ្លាស់ប្តូរព័ត៌មានបច្ចេកវិទ្យាដែលមានក្នុង ឯកសារប្រកាសនីយបត្រតក្កកម្មក្នុងចំណោមប្រទេសជាច្រើន។[12]

### ១.៣.២. ប្រវត្តនៃការកកើតការកកើតប្រកាសនីយបត្រតក្កកម្មអន្តរជាតិ

បន្ទាប់ពីសន្និសីទការទូតនៅទីក្រុងប៉ារីស ប្រទេសបារាំងឆ្នាំ១៨៨០ រួចមកហើយអនុញ្ញាតឱ្យទីក្រុងប៉ារីសសម្រាប់ការការពារកម្មសិទ្ធិឧស្សាហកម្ម បានចុះហត្ថលេខានៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៨៨៣ ដោយប្រទេសចំនួន១១ ( បែលសិក ប្រេស៊ីល បារាំង ហ្គាតេម៉ាឡា អ៊ីតាលី ហូឡង់ ព័ទុយហ្គាល់ អែលសាវ៉ាឌ័រ ស៊ែប៊ី អេស្ប៉ាញ និង ស្វីស ) ជាសមាជិកនៅពេលនោះ ហើយគិតមកដល់ថ្ងៃ១៥ ខែកក្កដា ឆ្នាំ១៨៨៣ មានប្រទេសជាសមាជិក ១៧៧ ។ អនុញ្ញាតនេះបានគ្រប់ដណ្តប់លើកម្មសិទ្ធិបញ្ញាច្រើនប្រភេទរួមមាន ការការពារលើប្រកាសនីយបត្រតក្កកម្ម ពាណិជ្ជសញ្ញា គំនូរឧស្សាហកម្ម ម៉ូដែលមានប្រយោជន៍ សេវាសញ្ញា ពាណិជ្ជនាម ការចង្អុលបង្ហាញ លក្ខណៈភូមិសាស្ត្រ និងទប់ស្កាត់ការប្រកួតប្រជែងមិនស្មោះត្រង់។ អនុសញ្ញានេះបានធ្វើវិសោធនកម្មចំនួន ៦ លើ រួមមានដូចខាងក្រោម៖

- លើកទី១ ធ្វើឡើងនៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩០០ នៅទីក្រុងប្រ៊ុសស៊ែល ប្រទេសបែលសិក
- លើកទី២ នៅថ្ងៃទី០២ ខែមិថុនា ឆ្នាំ១៩១១ នៅរដ្ឋធានីវ៉ាស៊ីនតោន សហរដ្ឋអាមេរិក
- លើកទី៣ នៅថ្ងៃទី០៦ ខែមិថុនា ឆ្នាំ១៩៣៤ នៅទីក្រុងឡុងដ៏ ចក្រភពអង់គ្លេស

11 ប្រធានបទ សន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម កិច្ចការស្រាវជ្រាវ ចាន់ អ៊ុយម៉ាន់ ទំព័រ ២ ។
12 មេរៀន នីតិកម្មសិទ្ធិបញ្ញា អនុបណ្ឌិត លឹម យូសួ ទំព័រ ៦៩។

- លើកទី ៥ នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៨៥ នៅទីក្រុងស្តុក ប្រទេសស្វីស

បន្ទាប់ពីនេះអនុសញ្ញានេះបានធ្វើវិសោធនកម្មចំនួនមួយលើកនៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ១៩៧៩។ ក្រោយមកក៏មានសន្ធិសញ្ញាការទូតនៅរដ្ឋវ៉ាស៊ីនតោន សហរដ្ឋអាមេរិក លើសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម ដែលធ្វើឡើងនៅថ្ងៃទី១៩ ខែឧសភា រហូតដល់ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ១៩៧០ ។ សន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម បានបញ្ចប់ការចង់ក្រង និង ចុះហត្ថលេខានៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ១៩៧០ រដ្ឋធានីវ៉ាស៊ីនតោន សហរដ្ឋអាមេរិក ហើយបានចូលជាធរមាន នៅថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៧៨ ។ នៅថ្ងៃទី០១ ខែមិថុនា ឆ្នាំ១៩៧៨ ពាក្យស្នើសុំប្រកាសនីយបត្រតក្កកម្ម តាមសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម លើកចុងក្រោយគេបង្អស់បានដាក់ស្នើសុំ ។ សន្ធិសញ្ញានេះបានបើកទូលាយឱ្យសមាជិករបស់អនុសញ្ញាទីក្រុងបារីសសម្រាប់ការការពារឧស្សាហកម្មចូលរួម ហើយវាធ្លាប់បានធ្វើវិសោធទនកម្មចំនួនបីលើក ដែលលើកទីមួយនៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ១៩៧៩ លើកទីពីរនៅថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ១៩៨៤ និង លើកទីបី នៅថ្ងៃទី០៣ ខែតុលា ឆ្នាំ ២០០១។[13]

### ១.៣.៣.គោលបំណង

សន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម PCT ជាសន្ធិសញ្ញាមួយដែលផ្តល់នូវការបំពេញបែបបទដើម្បីទទួលបាននូវកិច្ចការពារប្រកាសនីយបត្រតក្កកម្មនៅច្រើនប្រទេស។ វាផ្តល់នូវនីតិវិធីងាយស្រួលសម្រាប់តក្កករ ឬអ្នកស្នើសុំប្រកាសនីយបត្រតក្កកម្មចំណោមប្រទេសជាច្រើន និងក្នុងគោលបំណងជាច្រើន គឺជម្រុញ ការផ្លាស់ប្តូរព័ត៌មានមានបច្ចេកទេសវិទ្យាសាស្ត្រដែលមានក្នុងឯកសារ ប្រកាសនីយបត្រតក្កកម្មក្នុងចំណោម បណ្តាប្រទេសនានា នៅក្នុងសហគមវិទ្យាសាស្ត្រដែលតក្កករ និងឧស្សាហកម្មធ្វើការទំនាក់ទំនងក្នុងវិស័យជាមួយគ្នា។

ដូចនេះដើម្បីបន្ថែមនីតិវិធីកាន់តែមានភាពងាយស្រួលទទួលបាន ប្រកាសនីយបត្រតក្កកម្មវាសំខាន់ណាស់សម្រាប់គោលបំណងសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម PCT ធ្វើការផ្សព្វផ្សាយកាន់តែមានប្រសិទ្ធិភាពនូវចំណេះដឹង និង បច្ចេកទេសទាំងឡាយមាននៅក្នុងឯកសារប្រកាសនីយបត្រតក្កកម្ម ទោះបីយ៉ាងណាក៏ដោយប្រព័ន្ធសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម PCT មិនផ្តល់ប្រកាសនីយបត្រតក្កកម្មក្នុងពិភពលោក។[14]

13 ប្រធានបទ សន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម កិច្ចការស្រាវជ្រាវ ចាន់ អ៊ុយម៉ាន់ ទំព័រ ២ និង ទំព័រ ៣។

14 នីតិកម្មសិទ្ធិបញ្ញា សាស្ត្រាចារ្យ គន យឿន ទំព័រ១៨១ ឆ្នាំ២០១៣ ។

គោលបំណងសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម PCT នេះ មានគោលបំណងធ្វើឱ្យរីកចម្រើនផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា តាមរយៈដូចខាងក្រោម៖

- កែលម្អ និងសម្រួលនីតិវិធីដើម្បីទទួលការការពារតក្កកម្មតាមផ្លូវច្បាប់
- ធ្វើឱ្យមានភាពងាយស្រួល និង សន្សំសំចៃចំពោះការទទួលបាននូវការការពារតក្កកម្មក្នុងបណ្ដាលប្រទេសជាច្រើន
- ជួយសម្រួល និង ពន្លឿនដំណើរការអាជ្ញាធរសាធារណៈចំពោះឯកសារសេចក្ដីអត្ថាធិប្បាយបច្ចេក ទេសនៃតក្កកម្ម
- ជំរុញ និង ពន្លឿនការអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ប្រទេសកំពុងអភិវឌ្ឍតាមរយៈការអនុម័តនូវវិធានដែលចងក្រងឡើងដើម្បីបង្កើនប្រសិទ្ធិភាពនៃប្រព័ន្ធច្បាប់ សម្រាប់ផ្ដល់ភាពងាយស្រួល និងរកដំណោះស្រាយបច្ចេកទេសពាក់ព័ន្ធតក្កកម្មនៅក្នុងភាពជឿនលឿននៃបច្ចេកវិទ្យាសម័យទំនើបជាងយន្តការថ្នាក់ជាតិ ឬ តាមតំបន់។[15]

[15] នីតិវិធីនៃការចុះបញ្ជីប្រកាសនីយបត្រតក្កកម្មតាមសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម របាយការណ៍ស្រាវជ្រាវបញ្ចប់ការសិក្សា រស់ រតនា ទំព័រ ៩ ។

# ជំពូកទី ២

# ការចុះបញ្ជីប្រកាសនីយបត្រតក្ក កម្ពុជាតិ

# ជំពូកទី ២

# ការចុះបញ្ជីប្រកាសនីយបត្រតក្កកម្មជាតិ

ការចុះបញ្ជីប្រកាសនីយប័ត្រតក្កកម្មជាតិ គឺជាស្នើសុំចុះបញ្ជីរបស់តក្កករដែល បានបង្កើត និង រកឃើញនូវស្នាដៃថ្មី នៅក្នុងប្រទេសដែលរកឃើញដើម្បីទទួលបានការការពារ។ ដើម្បីស្វែងយល់អំពីខ្លឹមសារឱ្យកាន់តែស៊ីជម្រៅ គប្បីសិក្សាអំពីលក្ខខណ្ឌ និង បែបបទអ្វីខ្លះដែលតក្ករត្រូវបំពេញក្នុងការចុះបញ្ជីជាមុនសិន។

## ២.១. លក្ខខណ្ឌគ្រឹះនៃការចុះបញ្ជី

តក្កកម្ម តម្រូវឱ្យបំពេញនូវលក្ខខណ្ឌជាច្រើនដើម្បីអាចនឹងទទួលបាននូវការការពារហើយចំណុចសំខាន់នោះគឺ ការបង្កើត ឬការច្នៃប្រឌិតថ្មីទាំងនោះ កម្មវត្ថុរបស់វាត្រូវស្របច្បាប់ ថ្មី ជំហាននៃការរកឃើញថ្មី អាចអនុវត្តបានក្នុងឧស្សាហកម្ម ហើយពិសេសជាងនេះទៀត ម្ចាស់ស្នាដៃត្រូវបង្ហាញពីការបង្កើតថ្មី របស់ខ្លួននៅក្នុងពាក្យស្នើសុំប្រកាសនីយបត្រតក្កកម្មនិងត្រូវបំពេញទៅតាមលក្ខខណ្ឌតម្រូវផ្សេងទៀតដែលបានកំណត់ដោយច្បាប់។

### ២.១.១. ថ្មី

ថ្មី គឺត្រូវបានគេប្រើទៅលើវត្ថុ ឬឧបករណ៍ប្រើប្រាស់ផ្សេងៗដែលគេមិនធ្លាប់ត្រូវបានប្រើ ឬមិនធ្លាប់បានឃើញពីមុនមក។

តក្កកម្មដែលអាចចាត់ទុកថាថ្មីបានលុះត្រាតែតក្កកម្មនោះពុំទាន់មានអ្នកណាបានឃើញពីមុនមក ។[16] ការរកឃើញពីមុន គឺ តក្កកម្មដែលសាធារណៈជននៅកន្លែងណាមួយនៅពិភពលោកបានដឹងមុនកាលបរិច្ឆេទសុំចុះបញ្ជី សំណុំលិខិតស្នើសុំនោះ តាមរយៈការផ្សព្វផ្សាយ ដោយប្រើរូបភាពជាក់ស្តែង ឬដោយផ្ទាល់មាត់ តាមរយៈការប្រើប្រាស់តក្កកម្មនោះ ឬតាមរយៈមធ្យោបាយផ្សព្វផ្សាយទៀត។

មិនត្រូវចាត់ទុកថាជាការដឹងដល់សាធារណៈជនចំពោះករណីដូចខាងក្រោម៖

១. ការដឹងដល់សាធារណៈជននូវតក្កកម្មដែលបានកើតឡើងក្នុងអំឡុងពេល ១២ខែ មុនកាលបរិច្ឆេទសុំចុះបញ្ជីសំណុំលិខិតស្នើសុំ ឬកាលបរិច្ឆេទអាទិភាព[17]។ ទោះបីជាតក្កកម្មបានដឹងឮដល់សាធារណៈជនរួចហើយក៏ដោយ ក៏ត្រូវបានគេចាត់ទុកថាតក្កកម្មថ្មីដែរ នោះប្រសិនបើដឹងឮពីតក្កកម្មនោះបានកើតឡើងក្នុងរយៈពេល ១២ខែ មុនចុះបញ្ជី ឬកាលបរិច្ឆេទអាទិភាព។

២. ការធ្វើឱ្យលេចឮ ខូចខាតព័ត៌មានស្តីពីតក្កកម្មតាមរយៈអ្នកដាក់ពាក្យសុំ តាមរយៈអ្នកស្នងរបស់បុព្វជន ឬតាមរយៈការរំលោភរបស់តតិយជនជនទៅលើអ្នកដាក់ពាក្យសុំ ឬអ្នកស្នងរបស់បណ្តាលឱ្យ

[16] ច្បាប់ស្តីពី ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម មាត្រា៦ ។

[17] ជាកាលបរិច្ឆេទ ដែលបានដាក់សំណុំលិខិតស្នើសុំមុនគេបង្អស់ដែលប្រើប្រាស់សម្រាប់ធ្វើជាមូលដ្ឋានក្នុងការទទួលបានសិទ្ធិអាទិភាព ដូចដែលចែងក្នុងសន្ធិសញ្ញាទីក្រុងប៉ារីស ឆ្នាំ១៩៨៣។

លេចឮ។ ការរកឃើញពីមុន គឺតក្កកម្មដែលសាធារណៈជន នៅកន្លែងណាមួយនៅលើពិភពលោក បានដឹងមុនកាលបរិច្ឆេទសុំចុះបញ្ជីសំណុំលិខិតស្នើសុំ ឬកាលបរិច្ឆេទអាទិភាពនៃសំណុំលិខិតស្នើសុំនោះ តាមរយៈការផ្សព្វផ្សាយដោយប្រើរូបភាពជាក់ស្តែង ឬដោយផ្ទាល់មាត់ តាមរយៈកាប្រើប្រាស់តក្កកម្មនោះ ឬតាមរយៈមធ្យោបាយផ្សព្វផ្សាយផ្សេងទៀត។[18]

### ២.១.២. ជំហាននៃការរកឃើញថ្មី

ជំហាននៃការរកឃើញថ្មី ជាចំណុចដែលមានភាពច្នៃប្រឌិតមានការលំបាកជាងគេព្រោះថា វាទាមទារឱ្យមានការត្រួតពិនិត្យដែលមាន លក្ខណៈបច្ចេកទេសយ៉ាងលំអិតទើបអាចដឹងថាមាន ឬគ្មានជំហាននៃការរកឃើញថ្មី។ ជំហាននៃការរកឃើញថ្មីមានន័យថា តក្កកម្មមានលក្ខណៈស្មុគស្មាញដោយបុគ្គលកម្រិតធម្មតាក្នុងជំនាញមិនអាចយល់ដឹងបាន ហើយវាទាមទារឱ្យបុគ្គលដែលមានកម្រិតខ្ពស់ទើបអាចយល់ដឹងបានពីដំណើរការរបស់តក្កកម្មនោះ។

ប្រសិនបើតក្កកម្មដែលទើបតែរកឃើញ អាចឱ្យបុគ្គលកម្រិតជំនាញធម្មតាអាចយល់ដឹងបាននោះមានន័យថា តក្កកម្មនោះមិនមានជំហាននៃការរកឃើញថ្មីទេ ពីព្រោះវាបានបាត់បង់នូវភាពអស្ចារ្យ ឬលក្ខណៈពិសេសរបស់វាហើយ ។ ដូចនេះជំហាននៃការរកឃើញថ្មី សំដៅលើវិធីសាស្ត្រ បច្ចេកទេស ស្នាដៃ ដែលមិនងាយក្នុងរកឃើញ ឬក៏មិនងាយនឹងអាចធ្វើឱ្យតក្កកម្មនោះអាចដំណើរការ ឬប្រើប្រាស់បាន។

ច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្មរបស់កម្ពុជាចែង ដោយផ្អែកទៅលើការរកឃើញពីមុន ផ្អែកតាមសំណុំលិខិតស្នើសុំដែលអាចអះអាងអំពីតក្កកម្មនោះ នឹងដូចដែលមានចែងនៅក្នុងវាក្យខណ្ឌទី២ នៃមាត្រា៦នៃច្បាប់នេះតក្កកម្មត្រូវចាត់ទុកថាមានជំហានរកឃើញថ្មីប្រសិនបើតក្កកម្មនោះមិនអាចឱ្យបុគ្គលណាដែលមានកម្រិតធម្មតាក្នុងជំនាញយល់ដឹងបាន។[19]

ប៉ុន្តែទាំងនេះ មិនជាបញ្ហាដែលមិនអាចដោះស្រាយបាននោះទេ ព្រោះវាមិនមែនឱ្យតែអាច ប្រើប្រាស់បាន ឬអនុវត្តបាន គឺត្រូវទទួលបានការការពារដោយប្រកាសនីយបត្រតក្កកម្មទាំងអស់នោះឡើយ។

ជំនាញមិនអាចយល់ដឹងបាន ហើយវាទាមទារឱ្យបុគ្គលដែលមានកម្រិតខ្ពស់ទើបអាចយល់ដឹងបានពីដំណើរការរបស់តក្កកម្មនោះ។

[18] ច្បាប់ស្តីពី ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម មាត្រា៦ ។

[19] ច្បាប់ស្តីពី ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម មាត្រា៧ ។

ប្រសិនបើតក្កកម្មដែលទើបតែរកឃើញ អាចឱ្យបុគ្គលកម្រិតជំនាញធម្មតាអាចយល់ដឹងបាននោះមានន័យថា តក្កកម្មនោះមិនមានជំហាននៃការរកឃើញថ្មីទេ ពីព្រោះវាបានបាត់បង់នូវភាពអស្ចារ្យ ឬ លក្ខណៈពិសេសរបស់វាហើយ ។ ដូចនេះជំហាននៃការរកឃើញថ្មី សំដៅលើវិធីសាស្ត្រ បច្ចេកទេស ស្នាដៃ ដែលមិនងាយក្នុងរកឃើញ ឬក៏មិនងាយនឹងអាចធ្វើឱ្យតក្កកម្មនោះអាចដំណើរការ ឬប្រើប្រាស់បាន។

ច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្មរបស់កម្ពុជាចែង ដោយផ្អែកទៅលើការរកឃើញពីមុន ផ្អែកតាមសំណុំលិខិតស្នើសុំដែលអាចអះអាងអំពីតក្កកម្មនោះ នឹងដូចដែលមានចែងនៅក្នុងវាក្យខណ្ឌទី២ នៃមាត្រា៦ នៃច្បាប់នេះតក្កកម្មត្រូវចាត់ទុកថាមានជំហានរកឃើញថ្មី ប្រសិនបើតក្កកម្មនោះមិនអាចឱ្យបុគ្គលណាដែលមានកម្រិតធម្មតាក្នុងជំនាញយល់ដឹងបាន។[20]

### ២.១.៣. អាចអនុវត្តក្នុងឧស្សាហកម្មបាន

តក្កកម្មដែលបានរកឃើញ ឬទើបបានបង្កើតថ្មីនោះត្រូវតែឱ្យយកទៅ ផលិតប្រើប្រាស់នៅក្នុងប្រភេទណាមួយនៃឧស្សាហកម្ម ។ ការវិនិច្ឆ័យបែបនេះមានលក្ខណៈទូលំទូលាយណាស់ ពីព្រោះថាស្ទើរតែគ្រប់កម្មវត្ថុទាំងអស់អាចយក ទៅអនុវត្ត ឬប្រើប្រាស់បានក្នុងឧស្សាហកម្ម ទោះបីវាស្ថិតនៅក្នុងដំណាក់កាលនៃការស្រាវជ្រាវក៏ដោយ ប៉ុន្តែទាំងនេះ មិនជាបញ្ហាដែលមិនអាចដោះស្រាយបាននោះទេ ព្រោះវាមិនមែនឱ្យតែអាច ប្រើប្រាស់បាន ឬអនុវត្តបាន គឺត្រូវទទួលបានការការពារដោយប្រកាសនីយបត្រតក្កកម្មទាំងអស់នោះឡើយ។

➢ <u>**កម្មវត្ថុស្របច្បាប់**</u>

ដើម្បីទទួលបាននូវប្រកាសនីយបត្រតក្កកម្ម តក្កកម្មនោះដាច់ខាតត្រូវបំពេញឱ្យ បានគ្រប់លក្ខខណ្ឌដែលច្បាប់បានកំណត់ ។ ជាទូទៅកម្មវត្ថុនៃតក្កកម្មនៃតក្កកម្មនោះ ត្រូវតែ ស្របច្បាប់ហើយវាត្រូវតែបង្កើតថ្មីដែលចេញពីគំនិតបញ្ញាមនុស្ស ផលិតចេញមកស្របច្បាប់ និងមានប្រយោជន៍ប្រើប្រាស់ធ្វើអាជីវកម្មបាន។

តក្កកម្មទាំងនោះ នឹងមិនត្រូវទទួលបានការការពារតាមរយៈប្រកាសនីយបត្រតក្កកម្មទេ ប្រសិនបើការរកឃើញនោះជាការរកឃើញនូវវត្ថុធាតុដើម ឬក៏ជាសារធាតុមួយដែលមានស្រាប់នៅក្នុងធម្មជាតិ។ បើយោងតាមមាត្រា ៤ នៃច្បាប់ប្រកាសនីយបត្រតក្កកម្មនៃព្រះរាជាណាចក្រកម្ពុជាយើងវិញបានចែងថា៖

១. ការរកឃើញនូវទ្រឹស្តីវិទ្យាសាស្ត្រ និងវិធីសាស្ត្រគណិតវិទ្យា

២. គម្រោងការ ក្បួនឬវិធីសាស្ត្រសម្រាប់ជំនួញ សម្រាប់បធ្វើហ្គឹកហ្វឺនខាងប្រាជ្ញាសុទ្ធសាធ ឬសម្រាប់ល្បែងកំសាន្ត

[20] ច្បាប់ស្តីពី ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម មាត្រា៧ ។

៣. វិធីសាស្ត្រសម្រាប់ព្យាបាលរាងកាយមនុស្ស ឬសត្វដោយការវះកាត់ ឬក៏ដោយការព្យាបាល ក៏ដូចជាវិទ្យាសាស្ត្រវិនិច្ឆ័យរោគដែលបានអនុវត្តលើរាងកាយមនុស្ស សត្វ

៤. ផលិតផលឱសថដូចមានចែងក្នុងមាត្រា១៣៦

៥. រុក្ខជាតិ ឬសត្វដែលមិនមែនជាមីក្រូសរីរាង្គ និងដំណើរកកើតតាមលក្ខណៈជីវសាស្ត្រសំខាន់សម្រាប់ផលិតកម្មរុក្ខជាតិ ឬសត្វ

៦. ប្រភេទផ្សេងៗនៃប្រភេទរុក្ខជាតិណាមួយ។

ចំពោះវិធីសាស្ត្រដែលមានចែងនៅចំណុច ៣ ខាងលើនេះមិនត្រឹមតែព្រះរាជាណាចក្រកម្ពុជាប៉ុណ្ណោះទេ ដែលមិនផ្តល់ការការពារឱ្យ ប៉ុន្តែសូម្បីតែបណ្តាលប្រទេសផ្សេងៗទៀត ក៏ ពុំផ្តល់ការការពារឱ្យដែរ។

ទាក់ទងទៅនឹងផលិតផលឱសថ គឺមានលក្ខណៈគ្រប់គ្រាន់ដើម្បីទទួលបាននូវការការពារ ពីព្រោះគ្រប់ឱសថទាំងអស់ គឺពិបាកណាស់ក្នុងស្រាវជ្រាវ ចំណាយពេលវេលា និងថវិកាច្រើន។ តាមពិតទៅឱសថក៏ទទួលបាននូវការការពារតាមផ្លូវច្បាប់ផងដែរ តែដោយសារតែមានសំណូមពរពីបណ្តាល ប្រទេសដែលមានការអភិវឌ្ឍន៍តិចតួចមួយចំនួនទៅអង្គការពាណិជ្ជកម្មពិភពលោក ដើម្បីកុំឱ្យមានការការពារចំពោះផលិតផលឱសថក្នុងនៅបណ្តាលប្រទេសពួកគេ ដោយហេតុថានៅក្នុងបណ្តាលប្រទេសទាំងនោះកំពុងមានជម្ងឺឆ្លងច្រើន ហើយប្រជាជនពុំមានលទ្ធភាពក្នុងការទិញឱសថដែលមានតម្លៃថ្លៃមកប្រើនោះទេ ក៏ដូចជាបណ្តាលប្រទេសមួយចំនួននៅទ្វីបអាហ្វ្រិក និងកម្ពុជាយើង។ តាមរយៈស្នើសុំនេះអង្គការពិភពលោកបានយល់ព្រមដោយមិនការពារចំពោះផលិតផលឱសថរហូតដល់ឆ្នាំ២០៣១។[21] ដូច្នេះនាពេលសព្វថ្ងៃនេះ ផលិតផលឱសថនៅព្រះរាជាណាចក្រកម្ពុជា មិនទទួលបាននូវការការពារទេវាជាទ្រព្យសាធារណៈ ដែលបុគ្គលគ្រប់រូបអាចយករូបមន្តឱសថទាំងអស់នោះផលិតផល ដើម្បីធ្វើអាជីវកម្មបាន។

ក្នុងចំណុចទី៦ នៃមាត្រាដែលនេះដែរ មិនមែនគ្រប់បណ្តាលប្រទេសទាំងអស់ក្នុងពិភពលោកយើងនេះមិនផ្តល់ការការពារចំពោះពូជរុក្ខជាតិថ្មីនោះទេ គឺប្រទេសភាគច្រើន បានផ្តល់ការការពារតាមច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្មទេ គឺត្រូវការពារតាមច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំឆ្នាំ២០០៨។

## ២.២. លក្ខខណ្ឌទម្រង់នៃការចុះបញ្ជី

រាល់តក្កកម្មដែលបានរកឃើញថ្មី ប្រសិនបើម្ចាស់នៃតក្កកម្មចង់ទទួលបានការការពារពីប្រកាសនីយបត្រតក្កកម្ម ម្ចាស់តក្កកម្មត្រូវតែគោរពទៅតាមលក្ខខណ្ឌនៃនីតិវិធីការចុះចញ្ជីរួមមាន ពាក្យសុំ សេចក្តីអត្ថាធិប្បាយ សេចក្តីអះអាង ខ្លឹមសារសង្ខេប។

---

21 សម្រាប់ព្រះរាជាណាចក្រកម្ពុជាបានពន្យាពេលនៃការការពារលើកទី២រហូតដល់ឆ្នាំ២០៣៣ (មាត្រា១៣៦ ថ្មី)

### ២.២.១. ពាក្យសុំ

នៅក្នុងពាក្យសុំ អ្នកដាក់ពាក្យសុំត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់អំពីអត្តសញ្ញាណនៃតក្កកម្ម ហើយដែលនេះគឺជា កិច្ចដំបូងនៅក្នុងការរៀបចំនូវពាក្យសុំលិខិតស្នើសុំ រួមទាំងទិន្នន័យទាំងឡាយដែលពាក់ព័ន្ធ និងត្រូវភ្ជាប់មកជាមួយដែលនូវចំណងជើងនៃតក្កកម្មនោះ។ ហើយប្រសិនបើអ្នកដាក់ពាក្យសុំនោះមិនមែន ជាតក្កករទេនោះ អ្នកដាក់ពាក្យសុំនោះត្រូវភ្ជាប់មកនូវជាមួយឯកសារបញ្ជាក់ពីការផ្ទេរ សិទ្ធិមកជាមួយផង។[22] មួយវិញទៀតអ្នកដាក់ពាក្យសុំមិនមែនតក្កករ ក៏តម្រូវឱ្យបំពេញពាក្យសុំនោះត្រូវបញ្ជាក់ឈ្មោះ និងអាសយដ្ឋានរបស់តក្កករម្នាក់ៗ ដូចទៅនឹងពាក្យសុំជាតក្កករផងដែរ ប្រសិនបើអ្នកដាក់ពាក្យសុំប្រកាសនីយបត្រតក្កម្មនេះត្រូវធ្វើឡើងតាមរយៈអ្នកតំណាងរបស់ តក្កករ នោះអត្តសញ្ញាណរបស់អ្នកតំណាងស្របច្បាប់នោះត្រូវដាក់ក្នុងពាក្យសុំផងដែរ។

ម្យ៉ាងទៀតចំពោះចំណងជើងនៃតក្កកម្មត្រូវតែខ្លី ហើយច្បាស់លាស់ ដោយមិនអនុញ្ញាតឱ្យប្រើប្រាស់ចំណងជើង ឬឈ្មោះតក្កកម្មនោះ មានលក្ខណៈស្មុគស្មាញ មិនច្បាស់លាស់នោះទេ។[23]

ក្នុងករណីតក្កករ ពុំមានទីលំនៅអចិន្ត្រៃយ៍ ឬទីតាំងប្រកបអាជីវកម្មសំខាន់ក្នុងប្រទេសកម្ពុជាទេការដាក់ពាក្យសុំប្រកាសនីយបត្រតក្កកម្មនេះ ត្រូវធ្វើឡើងតាមរយៈអ្នកតំណាងរបស់តក្កករ នោះអត្តសញ្ញាណរបស់អ្នកតំណាងស្របច្បាប់ដែលជាភ្នាក់ងារដែលមានទីលំនៅ និងកំពុងប្រកបវិជ្ជាជីវៈនៅក្នុងប្រទេសកម្ពុជា និងដែលបានបំពេញលក្ខខណ្ឌទាំងឡាយដែល បានកំណត់ដោយបញ្ញត្តិដោយឡែករបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ [24]

តក្កកម្ម ត្រូវតែចុះបញ្ជីនៅ នាយដ្ឋានកម្មសិទ្ធិបញ្ញាឧស្សាហកម្ម នៃនាយកដ្ឋានឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍ ដើម្បីទទួលបាននូវការការពារស្របច្បាប់ និង ទទួលបានសិទ្ធិផ្តាច់មុខលើតក្កកម្មនោះ។

ការដាក់ពាក្យសុំចុះបញ្ជីប្រកាសនីយបត្រតក្កម្ម ត្រូវធ្វើឡើងដោយម្ចាស់តក្កកម្ម ឬអ្នកតំណាងស្របច្បាប់របស់ម្ចាស់តក្កកម្ម ដោយបំពេញតាមទម្រង់ដែលកំណត់ដោយច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនាយកដ្ឋានឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍ ។ អាទិភាពនៃការដាក់ពាក្យសុំប្រកាសនីយបត្រតក្កម្មនេះត្រូវបានផ្តល់ឱ្យអ្នកដែលបានចុះបញ្ជីជាផ្លូវការមុនគេ ឬអ្នកដែលបានអះអាងថាមានអាទិភាព។ ក្នុងន័យនេះសំដៅទៅលើស្នាដៃណាដែលបានចុះបញ្ជីមុន គេគឺស្នាដៃនោះត្រូវបានមានសិទ្ធិអាទិភាពមុនគេ ដោយមិនមានម្ចាស់តក្កកម្មផ្សេងទៀតមកបំពានសិទ្ធិបាន។

22 មេរៀន នីតិកម្មសិទ្ធិបញ្ញា សាស្ត្រាចារ្យ ឃឹម គីរី ទំព័រ ២២ ឆ្នាំ២០០៩ ។

23 ប្រកាស ស្តីពីការគ្រប់គ្រង និង នីតិប្រកាសនីយតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ប្រការ៩ ប្រកាសលេខ ២០៣ ។

24 ការប្រៀបធៀបនីតិវិធីប្រកាសនីយបត្រតក្កកម្មនៅកម្ពុជា និង តាមសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម សារណាបញ្ចប់ការសិក្សា នួន កន្និកា ទំព័រ ១៤ ។

### ២.២.២. សេចក្តីអត្ថាធិប្បាយ

ក្នុងចំណុចនេះគឺ តម្រូវឱ្យមានការបកស្រាយអំពីព័ត៌មានទំនាក់ទំនង និងបច្ចេកទេស ពីតក្កកម្មនោះឱ្យបានច្បាស់លាស់ ហើយនិងមានលក្ខណៈ ពេញលេញ ដើម្បីអាចបង្ករឱ្យបុគ្គលមានកម្រិតជំនាញធម្មតាអាចយល់ នឹងអាចអនុវត្តតក្កកម្មនោះបាន ពោល គឺត្រូវតែពន្យល់ បកស្រាយអាចបុគ្គលធម្មតាដែល មិនមែនជាមន្ត្រីជំនាញ បានយល់ដឹងអំពីដំណើរការអនុវត្តន៍ក្នុងការ ផលិតតក្កកម្មចាប់ពីដំបូងរហូតដល់តក្កកម្មបានជោគជ័យ បញ្ជាក់ឱ្យបានជាក់លាក់នូវរបៀបដែលតក្កកម្មអាចយកទៅអនុវត្តបាន នៅក្នុងលក្ខណៈឧស្សាហកម្ម និងរបៀបដែលតក្កកម្មអាចត្រូវយកទៅផលិត និងប្រើប្រាស់ ឬប្រសិនបើតក្កកម្មអាចត្រូវប្រើប្រាស់តែប៉ុណ្ណោះ ត្រូវបញ្ជាក់របៀបដែលអាចយកប្រើប្រាស់នោះ នៅពេលដែលតក្កកម្មមានសភាពខុសប្លែកពីសេចក្តីអត្ថាធិប្បាយ ឬលក្ខណៈរបស់តក្កកម្ម។

មាត្រា ១៨ ច្បាប់ស្តីប្រកាសនីយបត្រតក្កកម្មបានបញ្ញត្តិថា សេចក្តីអត្ថាធិប្បាយត្រូវលើកឡើងអំពីតក្កកម្មនោះក្នុងលក្ខណៈច្បាស់លាស់ និងពេញលេញ ដើម្បីឱ្យបុគ្គលដែលមានកម្រិតជំនាញធម្មតាក្នុងជំនាញអាចអនុវត្តបាននូវតក្កកម្មនោះ ។ ដោយឡែកសេចក្តីអត្ថាធិប្បាយនោះ ត្រូវចង្អុលឱ្យដឹងនូវវិធីដែលល្អជាងគេ ដើម្បីអនុវត្តតាមបាននូវ តក្កកម្មខាងលើនៅពេលចុះបញ្ជីកាលបរិច្ឆេទសុំចុះបញ្ជី ឬនៅពេលចុះបញ្ជីកាលបរិច្ឆេទអាទិភាពនៃសំណុំលិខិតនៃស្នើសុំក្នុងករណីអាទិភាពត្រូវបានអះអាង។[25] សេចក្តីអត្ថាធិប្បាយនៃតក្កកម្មមានគោលដៅបញ្ជាក់អំពីព័ត៌មានទាក់ទង បច្ចេកទេស ឬដំណើរនៃការផលិតផលដែលត្រូវបានប្រើប្រាស់ដើម្បីបង្កើតតក្កកម្មនោះ។ អត្ថន័យនៃសេចក្តីអត្ថាធិប្បាយនៃតក្កកម្មនេះ ត្រូវបានកំណត់ដោយប្រកាសរបស់ស្ថាប័នរដ្ឋ ។ ក្នុងសេចក្តីអត្ថាធិប្បាយនេះ ត្រូវបញ្ជាក់អំពី ឈ្មោះ ឬចំណងជើងនៃតក្កកម្ម និងបញ្ជាក់អំពីលក្ខណៈបច្ចេកទេស ដែលពាក់ព័ន្ធនឹង ស្នាដៃក្នុងលក្ខខណ្ឌមួយដែលអាចយល់បានដោយមន្ត្រីចុះបញ្ជី។ សេចក្តីអត្ថាធិប្បាយត្រូវពណ៌នាពីផលប្រយោជន៍នៃតក្កកម្មដែលអាចយកទៅផលិតនិងប្រើប្រាស់បានក្នុងវិស័យឧស្សាហកម្មមួយជាក់លាក់។[26]

ម្យ៉ាងវិញទៀតត្រូវបញ្ជាក់ពីស្នាដៃជាមូលដ្ឋាន ដែលបានដឹងចំពោះអ្នកដាក់ពាក្យសុំ អាចត្រូវចាត់ទុកថាប្រើប្រាស់សម្រាប់ការយល់ដឹង ការស្រាវជ្រាវ និងការត្រួតពិនិត្យតក្កកម្ម និងការដកស្រង់ឯកសារដែលឆ្លុះបញ្ចាំងនូវស្នាដៃនោះ។[27]

---

25 មាត្រា ១៨ ច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម។

26 សៀវភៅ នីតិកម្មសិទ្ធិបញ្ញា សាស្ត្រាចារ្យ ទេព សុខ ទំព័រ ២៨ ឆ្នាំ២០២០-២០២១។

27 ប្រកាសស្តីពី ការគ្រប់គ្រង និងនីតិវិធីផ្តល់ប្រកាសនីយតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ប្រការ១០ នៃប្រកាសលេខ ២០៣ ។

### ២.២.៣.សេចក្ដីអះអាង

អ្នកដាក់ពាក្យស្នើសុំត្រូវកំណត់ឱ្យបានច្បាស់លាស់នូវចំណុច ដែលចង់សុំឱ្យមានការការពារ។ ហើយជាងនេះទៅទៀតក៏អាចតម្រូវឱ្យប្រើប្រាស់នូវសេចក្ដីអត្ថាធិប្បាយ និងគំនូសបង្ហាញដើម្បីធ្វើការបកស្រាយពីសេចក្ដីអះអាង។ សេចក្ដីអះអាងត្រូវច្បាស់លាស់ និងសង្ខេប ។ គួរចង់ចាំថា សេចក្ដីអះអាងពឹងផ្អែកទាំងស្រុងលើសេចក្ដីអត្ថាធិប្បាយ។[28]

ជាទូទៅគេតម្រូវឱ្យអ្នកដាក់ពាក្យសុំភ្ជាប់ជាមួយនូវគំនូសបង្ហាញ ដែលជាកត្តា ដ៍ចាំបាច់ ក្នុងការធ្វើការបកស្រាយពន្យល់ដល់មន្ត្រីទទួលបន្ទុកកាន់កាប់បញ្ជីងាយស្រួលយល់ពីតក្កកម្មនោះ ។ កម្មវត្ថុនៃសេចក្ដីអះអាងមានគោលដៅបញ្ជាក់នូវលក្ខណៈបច្ចេកទេស សុទ្ធសាធរបស់តក្កកម្មដើម្បីបញ្ជាក់ថាតក្កកម្មដែលត្រូវដាក់ពាក្យសុំនេះមិនស្ថិតនៅក្នុងវិស័យណាមួយដែលត្រូវបានការពារ ដោយប្រកាសនីយបត្រតក្កកម្មរួចហើយ ឬវិស័យសាធារណៈ ឬដែលបម្រុងទុក ការពារឱ្យតក្កកម្មដែលនៅមានសុពលភាពឡើយ ហើយសេចក្ដីអះអាងនេះត្រូវមានលក្ខណៈច្បាស់លាស់ និង សមស្រប។[29]

### ២.២.៤. ខ្លឹមសារសង្ខេប

ខ្លឹមសារសង្ខេបគឺជាអត្ថន័យនៃលក្ខណៈបច្ចេកទេស នៃតក្កកម្មដែលជាកម្មវត្ថុនៃការដាក់ពាក្យសុំប្រកាសនីយបត្រតក្កកម្មសម្រាប់តម្កល់ឯកសារ។ ខ្លឹមសារសង្ខេបត្រូវធ្វើឡើងខ្លី ងាយយល់ និង ភ្ជាប់ជាមួយដោយគំរូពន្យល់អំពីតក្កកម្ម ដែលបានចុះបញ្ជីនោះ។[30]

អ្នកដាក់ពាក្យសុំ ត្រូវបានតម្រូវឱ្យធ្វើការបកស្រាយត្រឹមតែពីព័ត៌មានបច្ចេកទេសដែលទាក់ទងទៅនឹងតក្កកម្មនោះតែប៉ុណ្ណោះ ជាពិសេសអ្នកដាក់ពាក្យស្នើសុំមិនត្រូវធ្វើការបកស្រាយអំពីវិសាលភាពនៃការពាររបស់តក្កកម្មនោះឡើយ ។ លក្ខខណ្ឌមួយចំនួនដែលតម្រូវឱ្យមាននៅក្នុងពាក្យស្នើសុំប្រកាសនីយបត្រតក្កកម្ម ហើយក៏នូវមានចំណុចមួយចំនួនទៀត ដូចជាការរួមបញ្ចូលគ្នាតែមួយនៃតក្កកម្ម ការកែតម្រូវ និងការបំបែកសំណុំលិខិតស្នើសុំ។ ទោះបីអ្នកដាក់ពាក្យសុំបានបំពេញបែបបទ បានគ្រប់គ្រាន់ហើយក៏ដោយ ក៏អ្នកដាក់ពាក្យសុំអាចដកសុំណុំស្នើសុំរបស់ខ្លួនមកវិញនៅពេលណាក៏បាន ឱ្យតែក្នុងករណីដែលសំណុំលិខិតស្នើសុំនោះ ស្ថិតក្នុងដំណាក់កាលនៃការព្យួរទុកសម្រាប់ពិនិត្យដើម្បីផ្ដល់ប្រកាសនីយបត្រតក្កកម្ម។សំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្ម ដាច់ខាតត្រូវតែពាក់ព័ន្ធទៅនឹងតក្កកម្ម តែមួយគត់ ឬ តក្កកម្មតែមួយគត់ ឬតក្កកម្មមួយក្រុម ដែលទាក់ទងគ្នាក្នុងការ

---

28 មេរៀន នីតិកម្មសិទ្ធិបញ្ញា សាស្ត្រាចារ្យ ឃឹម គីរី ទំព័រ ២៣ ឆ្នាំ២០០៩ ។

29 សៀវភៅ នីតិកម្មសិទ្ធិបញ្ញា សាស្ត្រាចារ្យ ទេព សុខ ទំព័រ ២៨ ឆ្នាំ២០២០-២០២១ ។

30 សៀវភៅ នីតិកម្មសិទ្ធិបញ្ញា សាស្ត្រាចារ្យ ទេព សុខទំព័រ ២៨ ឆ្នាំ២០២០-២០២១ ។

បង្កើតបានជាទសន្សនៈរួមមួយនៃតក្កកម្មនោះ។

អ្នកដាក់ពាក្យសុំ អាចស្នើសុំធ្វើការកែតម្រូវនូវសំណុំលិខិតស្នើសុំរបស់ខ្លួនបាន នៅមុនពេលផ្តល់ប្រកាសនីយបត្រតក្កកម្ម ប៉ុន្តែរាល់ការកែតម្រូវនោះមិនត្រូវបន្ថែមអ្វីឱ្យលើសពី ខ្លឹមសារដែលបានបញ្ជាក់នៅក្នុងសំណុំលិខិតដំបូងនោះឡើយ។

ក្នុងករណីដែលតក្កកម្មមួយបានទទួលនូវប្រកាសនីយបត្រតក្កម្មរួចហើយ ប៉ុន្តែសំណុំលិខិតស្នើសុំរបស់អ្នកដាក់នោះ មិនទាន់បានគោរពតាមលក្ខខណ្ឌដែល បានតម្រូវនៃការរួមបញ្ចូលគ្នាតែមួយនៃតក្កកម្មក៏ដោយ ក៏ខ្វះខាតនេះមិនមែនជាមូលហេតុ ដែលនាំឱ្យប្រកាសនីយបត្រតក្កកម្មនោះអស់សុពលភាពឡើយ។

ក្នុងករណីមួយទៀត ប្រសិនបើអ្នកដាក់ពាក្យសុំយល់ឃើញថា តក្កកម្មរបស់ខ្លួននឹងមិនអាចទទួលបាននូវការការពារតាមរយៈប្រកាសនីយបត្រតក្កកម្មនោះទេ អ្នកដាក់ពាក្យស្នើសុំនោះ អាចធ្វើការផ្លាស់ប្តូរនូវសុំឯកសារនៃពាក្យសុំប្រកាសនីយបត្រតក្កកម្ម នោះទៅជាសំណុំឯកសារស្នើសុំឱ្យមានការការពារតាមរយៈវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍វិញបាន ឱ្យតែផ្លាស់ប្តូរនេះស្របតាមច្បាប់បានកំណត់ (ស្ថិតនៅក្នុងកំឡុងពេលរងចាំដើម្បីទទួលបានប្រកាសនីយបត្រតក្កកម្ម)។[31]

### ២.២.៥. ការស្នើសុំបំបែកលិខិតស្នើសុំ

អ្នកដាក់ពាក្យស្នើសុំ ក៏អាចបំបែកនូវសំណុំឯកសារនៃលិខិតស្នើសុំនោះឱ្យដាច់ពីគ្នាជាពីរ ឬច្រើនក៏បាន ក្នុងករណីដែលតតក្កកម្មរួមគ្នាក្នុងការបង្កើតតក្កកម្មនោះ នៅមុនពេលផ្តល់ប្រកាសនីយបត្រតក្កកម្ម ។ ប៉ុន្តែអ្នកដាក់ពាក្យស្នើសុំមិនត្រូវបន្ថែមនូវអ្វីដែលនាំឱ្យ លើសពីខ្លឹមសារនៃឯកសារដើមនោះឡើយ។ សំណុំលិខិតស្នើសុំនីមួយៗ ដែលបានបំបែក នឹងទទួលបានកាលបរិច្ឆេទនៃការសុំចុះបញ្ជី និងកាលបរិច្ឆេទអាទិភាពដូចៗគ្នា ទៅនឹងសំណុំលិខិតដែលបានស្នើសុំដំបូងដែរ។

ក្នុងករណីអាទិភាពនៃសំណុំលិខិតស្នើសុំមុន ចំនួនពីរ ឬ ច្រើន ត្រូវបានអះអាងសម្រាប់សំណុំលិខិតស្នើសុំពីដំបូង សំណុំលិខិតស្នើសុំបំបែកអាចទទួលបានផលប្រយោជន៍តែអាទិភាពមួយ ឬច្រើន ដែលអាចអនុវត្តចំពោះខ្លួនតែប៉ុណ្ណោះ។[32] ប្រសិនបើស្នើសុំប្រកាសនីយបត្រតក្កកម្មត្រូវបានបដិសេធ អ្នកដាក់ពាក្យស្នើសុំអាចដាក់ពាក្យស្នើសុំការការពារពីម៉ូដែលមានអត្ថប្រយោជន៍វិញបាន ឱ្យតែការស្នើសុំនេះស្របតាមច្បាប់បានដែលកំណត់ (ស្ថិតនៅក្នុងកំឡុងពេលរងចាំដើម្បីទទួលបានប្រកាសនីយបត្រតក្កកម្ម)។

---

[31] មេរៀន នីតិកម្មសិទ្ធិបញ្ញា សាស្ត្រាចារ្យ ឃឹម គីរី ទំព័រ ២៣ និងទំព័រ ២៤ ឆ្នាំ២០០៩ ។

[32] ប្រកាសស្តីពីការ គ្រប់គ្រង និង នីតិវិធីផ្តល់ប្រកាសនីយតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ប្រការ២១ នៃប្រកាសលេខ ២០៣ ។

### ២.២.៦. សមត្ថកិច្ចទទួលបន្ទុកពាក្យសុំ

ការស្នើសុំប្រកាសនីយបត្រតក្កកម្ម ត្រូវធ្វើនៅ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ហើយចំពោះពាក្យសុំនេះត្រូវដាក់ជូនទៅ នាយកដ្ឋានឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នាវានុវត្តន៍។ នាយកដ្ឋាននេះដឹកនាំដោយប្រធាន នាយកដ្ឋានមួយរូប ដែលមានតួនាទីតាមច្បាប់ គឺជាមន្ត្រីកាន់កាប់ សម្រាប់រាល់ការស្នើសុំប្រកាសនីយបត្រតក្កកម្មទាំងអស់ ។ ការដាក់ស្នើសុំអ្នកដាក់ពាក្យសុំប្រកាសនីយបត្រតក្កកម្ម តក្ករ ត្រូវតែដាក់ឈ្មោះរបស់ខ្លួន លើកលែងតែមានការប្រកាសលាយលក្ខណ៍អក្សរពិសេសណាមួយ ហើយផ្ញើរជូនមន្ត្រីកាន់កាប់បញ្ជី ដោយបញ្ជាក់ថា គាត់ពុំមានបំណងបញ្ចេញឈ្មោះទេ។

ការដាក់សំណុំលិខិតស្នើសុំចុះបញ្ជីប្រកាសនីយបត្រតក្កកម្ម គឺជាការដាក់សំណុំបែបបទដែលត្រូវបង់កម្រៃមុន ហើយសំណុំលិខិតប្រកាសនីយបត្រតក្កកម្ម ត្រូវត្រួតពិនិត្យជាចាំបាច់។

## ២.៣. ការផ្ដល់ប្រកាសនីយបត្រតក្កកម្ម និងអានុភាពនៃការពារ

បន្ទាប់ពីការបំពេញសំណុំលិខិតស្នើសុំ តក្ករត្រូវបញ្ជូនទៅ មន្ត្រីទទួលបន្ទុកកាន់កាបបញ្ជីដើម្បីត្រួតពិនិត្យលើសំណុំលិខិតស្នើសុំបាន បំពេញគ្រប់លក្ខខណ្ឌតាមច្បាប់កំណត់។ មន្ត្រីកាន់កាបបញ្ជីមានតួនាទីចុះកាលបញ្ជីនៃការចុះបញ្ជី ការផ្សព្វផ្សាយជាសាធារណៈ និងផ្ដល់សិទ្ធិនិងការពារដល់តក្កម្ម។

### ២.៣.១.កាលបរិច្ឆេទនៃការចុះបញ្ជី

មន្ត្រីកាន់កាប់បញ្ជី ត្រូវទទួលស្គាល់នូវកាលបរិច្ឆេទនៃការទទួលសំណុំលិខិតស្នើសុំ ថាជាកាលបរិច្ឆេទនៃការសុំចុះបញ្ជីសំណុំលិខិតស្នើសុំបាន លុះត្រាតែនៅពេលទទួលសំណុំលិខិតស្នើសុំនោះបានបំពេញឯកសារត្រឹមត្រូវដូចដែលបានកំណត់ខាងក្រោម៖

១. ត្រូវបញ្ជាក់យ៉ាងច្បាស់លាស់ ឬ ប្រាប់អំពីបំណងនៃការសុំផ្ដល់ប្រកាសនីយបត្រតក្កកម្ម

២.ការបញ្ជាក់អំពីអត្តសញ្ញាណនៃដាក់ពាក្យស្នើសុំ

៣. សំណុំលិខិតស្នើសុំនោះ ត្រូវមានសេចក្ដីអត្ថាធិប្បាយអំពីតក្កកម្ម។[33]

នៅពេលដែលទទួលបាននូវសំណុំលិខិតប្រកាសនីយបត្រតក្កកម្ម មន្ត្រីទទួលបន្ទុកកាន់កាប់បញ្ជីពាក្យសុំត្រូវពិនិត្យលើលក្ខខណ្ឌត្រឹមត្រូវខ្លឹមសារនិងទម្រង់បានភ្ជាប់មកជាមួយសំណុំលិខិតស្នើសុំនោះគ្រប់គ្រាន់ មន្ត្រីទទួលបន្ទុកអាចផ្ដល់ប្រកាសនីយបត្រតក្កកម្ម ព្រមទាំងចុះកាលបរិច្ឆេទ។

ប៉ុន្តែប្រសិនបើសំណុំលិខិតស្នើសុំមិនទាន់បំពេញ ឱ្យបានគ្រប់គ្រាន់មិនពេញលេញទៅតាមលក្ខខណ្ឌបានកំណត់នោះ មន្ត្រីតំរូវឱ្យអ្នកដាក់ពាក្យសុំយកទៅកែប្រែកែតម្រូវ។

[33] ច្បាប់ស្ដីពី ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម មាត្រា៣៣ ។

បើអ្នកដាក់ពាក្យសុំបានធ្វើការកែតម្រូវរួចហើយ នោះមន្ត្រីទទួលបន្ទុកកាន់កាប់បញ្ជី ត្រូវកត់ត្រាកាលបរិច្ឆេទនៃការសុំចុះបញ្ជីសំណុំលិខិតស្នើសុំទៅតាមកាលបរិច្ឆេទដែលបានកែតម្រូវ ។ មន្ត្រីទទួលបន្ទុកកាន់កាប់បញ្ជីត្រូវត្រួតពិនិត្យមើលសំណុំលិខិតស្នើសុំនោះឱ្យបានត្រឹមត្រូវតាមលក្ខខណ្ឌដែលបានតម្រូវ បន្ទាប់ពីមានការយល់ព្រមទៅលើកាលបរិច្ឆេទសុំចុះបញ្ជី។[34]

➢ សំណុំលិខិតស្នើសុំត្រូវមានកាលបរិច្ឆេទគឺជា

- ជាកាលបរិច្ឆេទដែលចាប់ផ្តើមការពារតក្កកម្ម
- កាលបរិច្ឆេទអាទិភាពប្រឆាំងជាមួយតតិយជន
- កាលបរិច្ឆេទអាទិភាពអាចយកទៅដាក់ពាក្យសុំប្រទេសផ្សេងទៀតបាន។

### ២.៣.២. ការផ្សព្វផ្សាយជាសាធារណៈ

ការផ្សព្វផ្សាយជាសាធារណៈ ក៏មានសារៈសំខាន់ដែលព្រោះថាវាបានបង្ហាញឱ្យមនុស្សទាំងអស់បានដឹងឮពីតក្កកម្ម និងតក្ករ។ លើសពីនេះទៅទៀត បុគ្គលទាំងឡាយដែលមានប្រយោជន៍ដែលពាក់ព័ន្ធជាតក្កកម្ម នោះអាចដាក់ពាក្យប្តឹងជំទាស់ពីការប្រគល់នូវ ប្រកាសនីយបត្រតក្កកម្មនេះបានរយៈពេលដាក់ពាក្យបណ្តឹង ១២ ខែបន្ទាប់ពីបោះពុម្ពផ្សាយ។

- ចេញលិខិតបញ្ជាក់ពីការប្រកាសនីយបត្រតក្កកម្មចម្លងមួយច្បាប់ឱ្យដល់អ្នកដាក់ពាក្យសុំ
- ច្បាប់ចម្លងនៃប្រកាសនីយបត្រតក្កកម្មត្រូវមានសម្រាប់សាធារណៈអាចជាវតាមតម្លៃដែលបានកំណត់។

➢ គោលបំណងផ្សព្វផ្សាយជាសាធារណៈ

- លើកទឹកចិត្តដល់តក្ករ
- ទទួលបានការវិនិយោគ (ទិញស្នាដៃ សុំអាជ្ញាបណ្ណទៅធ្វើអាជីវកម្ម)
- អាចដាក់ពាក្យជំទាស់ (ដោយប៉ះពាល់ដល់តក្ករដូចជាតក្កកម្មមានរួចហើយ)
- ចុះផ្សាយពីសេចក្តីបញ្ជាក់អំពីការផ្តល់ប្រកាសនីយបត្រតក្កកម្មនោះ។

[34] ច្បាប់ស្តីពី ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម មាត្រា៣៥ ។

### ២.៣.៣. តក្កកម្មដែលមិនអាចទទួលបានការការពារ

តក្កកម្មដែលបានរកឃើញ ឬទើបបានបង្កើតថ្មីនោះ ត្រូវតែមអាចយកទៅផលិតប្រើប្រាស់នៅក្នុងប្រភេទឧស្សាហកម្មបាន ។ ប៉ុន្តែមិនមែនឱ្យតែអាចអនុវត្តក្នុងឧស្សាហកម្មបាន ឬប្រើប្រាស់ គឺត្រូវទទួលបានការការពារដោយប្រកាសនីយបត្រតក្កកម្មទាំងអស់ឡើយ។

មាត្រា៩ ច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្មនៃព្រះរាជាណាចក្រកម្ពុជាចែងថា តក្កកម្មណាដែលអាចធ្វើអាជីវកម្មពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា៖

- ផ្ទុយពីសណ្តាប់ធ្នាប់សាធារណៈ ឬសីលធម៌
- មិនការពារជីវិត ឬសុខភាពរបស់មនុស្ស សត្វ ឬរុក្ខជាតិ
- ធ្វើឱ្យខូចបរិស្ថានធ្ងន់ធ្ងរ ឬ
- ត្រូវបានច្បាប់ហាមឃាត់ មិនត្រូវផ្តល់ប្រកាសនីយបត្រឱ្យបានទេ។

ដូចនេះ រាល់តក្កកម្មដែលបានចែងក្នុងមាត្រា ៩នៃច្បាប់ប្រកាសនីយបត្រតក្កកម្មនៃព្រះរាជាណាចក្រកម្ពុជាមិនអាច ផ្តល់សិទ្ធិទទួលបានការការពារ ដោយប្រកាសនីយបត្រតក្កកម្មបានទេ។

### ២.៣.៤. ការសម្រេចបដិសេធការផ្តល់ប្រកាសនីយបត្រតក្កកម្ម

មូលហេតុនៃការបដិសេធជាគោលការណ៍ ការបដិសេធផ្តល់ប្រកាសនីយបត្រតក្កកម្ម ជូនដល់អ្នកដាក់ពាក្យសុំណាម្នាក់ ត្រូវចាត់ទុកថានូវទណ្ឌកម្មខាងរដ្ឋបាល ក្នុងករណីដែលសំណុំនៃពាក្យសុំពុំគោរពនូវលក្ខខណ្ឌតម្រូវរបស់ច្បាប់។ មានមូលដ្ឋាន ២យ៉ាងដែលអាចនាំឱ្យមន្ត្រីកាន់កាប់បញ្ជីត្រូវធ្វើការបដិសេធ គឺការដាក់ពាក្យសុំប្រកាសនីយបត្រតក្កកម្មមិនគោរពតាមលក្ខខណ្ឌគ្រឹះ និងលក្ខខណ្ឌទម្រង់។

➢ <u>**ការមិនគោរពលក្ខខណ្ឌគ្រឹះ**</u>

បើមន្ត្រីកាន់កាប់បញ្ជីបានពិនិត្យឃើញថា តក្កកម្មដែលបានស្នើសុំប្រកាសនីយបត្រតក្កកម្មនោះពុំបានបំពេញ នូវលក្ខណៈវិនិច្ឆ័យតាមខ្លឹមសារនៃតក្កកម្មដែលបានតម្រូវទេនោះទេសិ មន្ត្រីកាន់កាប់បញ្ជី ត្រូវបដិសេធលើលិខិតស្នើសុំនោះជាដាច់ខាន[35] ដោយមិនមានការអនុញ្ញាតកែតម្រូវជាថ្មីឡើងវិញ។ ដូចនេះកង្វះខាតនៃលក្ខខណ្ឌទាក់ទង នឹងខ្លឹមសាររបស់តក្កកម្មនេះគឺជាមូលដ្ឋានជាការបដិសេធដាច់ខាត នៅក្នុងការផ្តល់ប្រកាសនីយបត្រតក្កកម្មនេះ។

[35] ប្រកាសស្តីពី នីតិវិធីផ្តល់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ប្រការ២៦ចំណុចទី២ នៃប្រកាសលេខ ៧០៦ ។

➢ **មិនគោរពលក្ខខណ្ឌទម្រង់**

កាលណាមន្ត្រីកាន់កាប់បញ្ជីបានរកឃើញថាសំណុំលិខិតស្នើសុំទាំងនោះពុំបានគោរពតាមលក្ខខណ្ឌទម្រង់ដែលបានកំណត់ទេនោះ មន្ត្រីកាន់បន្ទុកបញ្ជី និងណែនាំអ្នកដាក់ពាក្យសុំ កែប្រែជាថ្មីឡើងវិញ។ ប៉ុន្តែប្រសិនបើសំណុំលិខិតទាំងនោះពុំបានកែប្រែតាមការណែនាំទេ មន្ត្រីកាន់កាប់បញ្ជី និងបដិសេធពាក្យសុំនោះចោល ដោយចាត់ទុកថា ដូចមិនបានសុំចុះបញ្ជី។[36]

## ២.៣.៥. សិទ្ធិដែលកើតចេញពីប្រកាសនីយបត្រតក្កកម្ម

ការសម្រេចជូនដល់អ្នកដាក់ពាក្យសុំ នូវប្រកាសនីយបត្រតក្កកម្ម ក៏មានន័យដែលថារដ្ឋព្រមទទួលស្គាល់សិទ្ធិមួយចំនួនដែលច្បាប់នេះបានកំណត់ ឱ្យអ្នកដាក់ពាក្យស្នើសុំក្នុងឋានៈជាម្ចាស់នៃប្រកាសនីយបត្រតក្កកម្ម។ ការផ្តល់នូវសិទ្ធិនេះគឺអនុញ្ញាតឱ្យម្ចាស់នៃប្រកាសនីយបត្រតក្កកម្មអាចធ្វើអាជីវកម្មផ្តាច់មុខ លើតក្កកម្មនេះបាន និងអាចឱ្យម្ចាស់ប្រកាសនីយបត្រតក្កកម្ម ហាមឃាត់លើតតិយជនណាម្នាក់ មិនអាចធ្វើអាជីវកម្មលើតក្កកម្មរបស់ខ្លួនបានផងដែរ។ តតិយជនណាម្នាក់ ដែលហ៊ានធ្វើអាជីវកម្ម លើតក្កកម្មដែលមានទទួលបានការការពារប្រកាសនីយបត្រតក្កកម្ម ដោយគ្មានការអនុញ្ញាត ឬការយល់ព្រមពីម្ចាស់ប្រកាសនីយបត្រតក្កកម្ម និងត្រូវចាត់ទុកជាការរំលោភបំពានលើសិទ្ធិស្របច្បាប់ របស់តក្កករ។ ក្នុងករណីនេះ និងអាចមានយន្តការដោះស្រាយសំដៅលើការធានាសិទ្ធិស្របច្បាប់ដល់ម្ចាស់សិទ្ធិផងដែរ។

ផលប្រយោជន៍ជាច្រើនដែលកម្មសិទ្ធិករទទួលបានរួមមានដូចជា ផលប្រយោជន៍ខាងសេដ្ឋកិច្ច និងសីលធម៌រួមទាំង ការប្រើប្រាស់ផ្សេងៗទៀតដែលស្របតាមច្បាប់ហើយ វាក៏ជាឆន្ទៈ និងសិទ្ធិរបស់តកម្មសិទ្ធិករ ក្នុងការផ្ទេរ លក់ ឬការធ្វើជាអំណោយជាអាទិ៍ ។ ប៉ុន្តែសិទ្ធិនេះក៏អាចត្រូវបានដកហូតប្រសិនបើការប្រើប្រាស់នោះផ្ទុយពីច្បាប់ជាធរមាន។

### ២.៣.៥.១. សិទ្ធិធ្វើអាជីវកម្មផ្តាច់មុខ

សិទ្ធិដែលទទួលបានពីប្រកាសនីយបត្រតក្កកម្ម គឺមានលក្ខណៈដាច់ខាត ផ្តាច់មុខ និងជារាងរហូត (សិទ្ធិសីលធម៌) ពោលគឺសិទ្ធិដែលទទួលបាននេះគ្មានអាជ្ញាយុកាលទេ។ សិទ្ធិមិនត្រូវបានផុតរលត់ទៅតាម ការប្រើប្រាស់ ឬមិនត្រូវផុតរលត់ទៅតាមការស្លាប់ របស់តក្កករ ឬកម្មសិទ្ធិករនោះដែរ ហើយសិទ្ធិនេះក៏អាចផ្ទេរទៅឱ្យទាយាទ របស់តក្កករ ឬកម្មសិទ្ធិករនៃប្រកាសនីយបត្រតក្កកម្ម ។ គ្មាននរណាម្នាក់អាចប្រើប្រាស់តក្កកម្មដែលទទួលបាននូវការការពារស្របច្បាប់នេះដោយពុំមានការអនុញ្ញាតពីម្ចាស់កម្មសិទ្ធិករបានឡើយ។

[36] ច្បាប់ស្តីពី ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍និងគំនូរឧស្សាហកម្ម មាត្រា ៣៤(២) ។

សិទ្ធិនេះអនុវត្តក្រោមរូបភាព ២យ៉ាងគឺ ពោលអាចជាសិទ្ធិផ្តាច់មុខ របស់ម្ចាស់ នៃប្រកាសនីយបត្រក្នុងអាជីវកម្ម ខ្លួនឯងលើតក្កកម្មផង និងវាជាសិទ្ធិរបស់ម្ចាស់ប្រកាសនីយបត្រតក្កកម្មក្នុងការអនុញ្ញាតឱ្យ តតិយជនជនធ្វើ អាជីវកម្មលើតក្កកម្មរបស់ខ្លួននេះនៅក្រោមទម្រង់នៃកិច្ចសន្យាបានផងទៀត។

- សិទ្ធិធ្វើអាជីវកម្មដោយម្ចាស់នៃប្រកាសនីយបត្រតក្កកម្មខ្លួនឯង

ការធ្វើអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជានូវតក្កកម្មដែលបានទទួលប្រកាសនីយបត្រតក្កកម្មរួចហើយ ដោយបុគ្គលដទៃទៀត ចាំបាច់ត្រូវតែមានការយល់ព្រមពីម្ចាស់ប្រកាសនីយបត្រតក្កកម្មនោះ។[37] ក្រៅពីគោរពនូវ គោលការណ៍ពេលវេលា អាជ្ញាយុកាលនៃសិទ្ធិម្ចាស់នៃប្រកាសនីយបត្រមានសិទ្ធិកម្មសិទ្ធិផ្តាច់មុខទៅលើតក្ក កម្មនោះក្នុងរបៀបស្រដៀងគ្នា និងសិទ្ធិកម្មសិទ្ធិផងដែរ ពោលគឺ សិទ្ធិប្រើប្រាស់ អាស្រ័យផល និងចាត់ចែង។

- ការធ្វើអាជីវកម្មដែលស្ថិតនៅក្នុងវិសាលភាពនៃសិទ្ធិ

ការធ្វើអាជីវកម្ម ដែលទទួលបានប្រកាសនីយបត្រតក្កកម្មរួចហើយ សំដៅសកម្មភាព ២ ប្រភេទគឺ ប្រកាស នីយបត្រតក្កកម្មសម្រាប់ជីវកម្ម ចំពោះផលិតផល និងប្រកាសនីយបត្រតក្កកម្មចំពោះដំណើរការផលិតកម្ម។ ទាក់ទង នឹងសិទ្ធិរបស់ប្រកាសនីយបត្រតក្កកម្មទៅលើផលិតផលនេះរួមមាន៖ ទាំងលើការផលិត ការនាំចូល ការផ្គត់ផ្គង់សម្រាប់ការលក់ ឬការស្តុបទុកផលិតផល នឹងសម្រាប់ប្រើប្រាស់ផងដែរ។

**២.៣.៥.២. ការធ្វើអាជីវកម្មដែលមិនស្ថិតនៅក្នុងវិសាលភាពនៃសិទ្ធិ**

មានករណីដោយឡែកមួយចំនួនដែលមានសិទ្ធិនៃប្រកាសនីយបត្រតក្កកម្មពុំអាចអនុវត្តបាននោះគឺម្ចាស់ នៃប្រកាសនីយបត្រតក្កកម្មពុំមានសិទ្ធិប្រឆាំង នឹង សកម្មភាពធ្វើអាជីវកម្មនោះបានទេបើទោះបីជាសកម្មភាព នោះបំពានដល់សិទ្ធិផ្តាច់មុខរបស់ខ្លួន ក្នុងការធ្វើអាជីវកម្មនោះក៏ដោយ។ ក្នុងន័យតាមបែបច្បាប់សិទ្ធិដែលប្រ-គល់តាមរយៈប្រកាសនីយបត្រតក្កកម្មមិនអនុវត្តចំពោះករណីដូចខាងក្រោម៖

១. សកម្មភាពពាក់ព័ន្ធសម្ភារៈដែលបានដាក់តាំងនៅលើទីផ្សារនៃព្រះរាជាណាចក្រកម្ពុជា ឬនៅលើទីផ្សារ ក្រៅព្រះរាជាណាចក្រកម្ពុជា ដោយម្ចាស់ប្រកាសនីយបត្រតក្កកម្ម ឬ ដោយមានការយល់ព្រមពីម្ចាស់ប្រកាសនីយ បត្រតក្កកម្ម។

២. ការប្រើប្រាស់សម្ភារៈនៅលើអាកាសយាន យានដ្ឋានផ្លូវគោក ឬ នាវារបស់ប្រទេសដទៃ ដែលបានចូល ចតជាបណ្តោះអាសន្ន ឬចតដោយជួបឧបទ្ទវហេតុក្នុងដែនអាកាស ដែនគោក ឬក្នុងដែនទឹក។

៣. ជាសកម្មភាពដែលធ្វើត្រឹមតែក្នុងគោលបំណងយកទៅពិសោធន៍ដែលទាក់ទងទៅ នឹងតក្កកម្មដែល បាននូវប្រកាសនីយបត្រតក្កកម្មរួមហើយ។

---

[37] ច្បាប់ស្តីពី ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍និងគំនូរឧស្សាហកម្ម មាត្រា ៤១ ។

៤. សកម្មភាពដែលប្រព្រឹត្តក្នុងគោលបំណងល្អដោយបុគ្គលណាម្នាក់ដោយប្រើប្រាស់តក្កកម្ម ក៏ជាការធ្វើរៀបចំឱ្យមានប្រសិទ្ធិភាព និងហ្មត់ចត់នូវតក្កកម្មនោះមុន កាលបរិច្ឆេទសុំចុះបញ្ជីសំណុំលិខិតស្នើសុំ ឬមុនកាលបរិច្ឆេទអាទិភាពនៃសំណុំលិខិតស្នើសុំ។

### ២.៣.៥.៣. សិទ្ធិអនុញ្ញាតឱ្យតតិយជនធ្វើអាជីវកម្មជំនួសខ្លួន និងអនុប្បទានសិទ្ធិ

ម្ចាស់ប្រកាសនីយបត្រតក្កកម្ម មានសិទ្ធិក្នុងការអនុញ្ញាត ឬមិនអនុញ្ញាតឱ្យតតិយជនជនណាម្នាក់ធ្វើអាជីវកម្មលើតក្កកម្មដែលខ្លួនបានចុះបញ្ជីរួចហើយនោះបាន។ សិទ្ធិក្នុងការអនុញ្ញាតឱ្យតតិយជនជន ធ្វើអាជីវកម្មលើតក្កកម្ម គឺត្រូវធ្វើឡើងក្រោមទម្រង់កិច្ចសន្យា។ ប៉ុន្តែសិទ្ធិសម្រេចនេះពុំដាច់ខាតនោះឡើយ ពីព្រោះតែក្នុងករណីខ្លះច្បាប់បានផ្តល់អំណាចដល់អាជ្ញាធររដ្ឋឱ្យអាចសម្រេច បង្ខំដល់ម្ចាស់ប្រកាសនីយបត្រតក្កកម្មដែលបានចុះបញ្ជីនោះត្រូវតែផ្តល់សិទ្ធិធ្វើអាជីវកម្មទៅតតិយជនបើទោះជាម្ចាស់ប្រកាសនីយបត្រនោះគ្មានឆន្ទៈនិងផ្តល់ក៏ដោយ។

អាជីវកម្មកម្ម គឺសំដៅទៅលើសកម្មភាពទាំងឡាយដូចជាការផលិត ការនាំចូលការផ្គត់ផ្គង់សម្រាប់លក់ និងការប្រើប្រាស់ផលិតផលនោះ ឬការស្តុបទុកផលិតផលក្នុងគោលបំណងសម្រាប់លក់ ឬប្រើប្រាស់។ ជាទូទៅកិច្ចសន្យាព្រមព្រៀងរវាងតក្កករ និងតតិយជនគឺធ្វើឡើងតាមរយៈកិច្ចសន្យាអាជ្ញាបណ្ណ័។ មានន័យថាការអនុវត្តន៍នូវសិទ្ធិធ្វើអាជីវកម្ម ឬប្រគល់សិទ្ធិធ្វើអាជីវកម្មលើប្រកាសនីយបត្រតក្កកម្មឱ្យទៅតតិយជនដែលនាំឱ្យអ្នកទទួលសិទ្ធិធ្វើអាជីវកម្ម ឬប្រគល់សិទ្ធិធ្វើអាជីវកម្មលើប្រកាសនីយបត្រតក្កកម្មឱ្យតតិយជនជនដែលនាំឱ្យអ្នកទទួលសិទ្ធិបន្តទាំងនោះមានសិទ្ធិដូចតក្កករដែរ។ ចំពោះករណីតក្កកម្មជានិយោជិត ការផ្ទេរសិទ្ធិទៅឱ្យនិយោជករបស់ខ្លួន គឺតាមរយៈកិច្ចសន្យាការងារ ហើយរាល់ការអនុវត្តន៍សិទ្ធិ និងកាតព្វកិច្ចឬសំខាន់ផ្សេងៗទៀតអាស្រ័យទៅ លើការព្រមព្រៀងរវាង គូភាគីទាំងសងខាង។

ចំពោះតតិយជនដែលទទួលបានការអនុញ្ញាតឱ្យធ្វើអាជីវកម្ម អាចផ្ទេរសិទ្ធិនោះបានជាមួយតែសហគ្រាសឬ ក្រុមហ៊ុនរបស់តតិយជនជនដែលកំពុងធ្វើអាជីវកម្មលើតក្កកម្មនោះតែប៉ុណ្ណោះ។ រាល់ការអនុញ្ញាតឱ្យធ្វើអាជីវកម្មជាចាំបាច់ត្រូវមានកិច្ចសន្យាអាជ្ញាបណ្ណ័ដែលធ្វើឡើងដោយម្ចាស់កម្មសិទ្ធិករ ឬអនុវត្តបន្តសិទ្ធិធ្វើអាជីវកម្មដោយម្ចាស់ប្រកាសនីយបត្រតក្កកម្ម។

- **ការអនុញ្ញាតដោយឆន្ទៈនៃប្រកាសនីយបត្រ**

ការអនុញ្ញាតនេះអាចស្តែងឡើងក្រោមទម្រង់ពីរយ៉ាងពោល គឺអាចដាក់ការលក់សិទ្ធិនៃប្រកាសនីយបត្រតក្កកម្មឱ្យតតិយជនតែម្តង ឬអាចគ្រាន់តែជាការជួលសិទ្ធិនោះប៉ុណ្ណោះតាមយន្តការនៃកិច្ចសន្យាដែលឱ្យឈ្មោះថា អាជ្ញាប័ណ្ណរាល់ការអនុញ្ញាត របស់ម្ចាស់ប្រកាសនីយបត្រតក្កកម្មឱ្យតតិយជន (ជនទី៣ធ្វើអាជីវកម្មលើ តក្ក

កម្មដែលខ្លួនបានចុះបញ្ជីនោះត្រូវមានកាតព្វកិច្ច ជូនដំណឹងទៅអាជ្ញាធររដ្ឋ)។ គ្រប់កិច្ចសន្យាពាក់ព័ន្ធនឹងការផ្លាស់ប្តូរម្ចាស់កម្មសិទ្ធិនៃប្រកាសនីយបត្រតក្កកម្ម ឬវិញ្ញាបនបត្រម៉ូលដែលមានអត្ថប្រយោជន៍ ឬការចុះបញ្ជីម្ចាស់កម្មសិទ្ធិនៃសំណុំលិខិតស្នើសុំត្រូវធ្វើជាលាយលក្ខណ៍អក្សរ ហើយត្រូវកត់ត្រាចូលបញ្ជី និងចុះផ្សាយជាសាធារណៈដោយមន្ត្រីកាន់កាប់បញ្ជី លើកលែងតែករណីនៃសំណុំលិខិតស្នើសុំដែល មិនត្រូវមានធ្វើការចុះផ្សាយ។[38] ការប្តូរ ម្ចាស់កម្មសិទ្ធិនេះ នឹងមិនមានអានុភាពចំពោះភាគីទីបីឡើយ រហូតដល់កត់ត្រាចូលបញ្ជីត្រូវបានធ្វើរួចជាស្ថាពរ។

➢ **ការអនុញ្ញាតដោយបង្ខំឆន្ទៈនៃម្ចាស់ប្រកាសនីយបត្រតក្កម្ម**

ក្នុងករណីមួយចំនួន អាជ្ញាធររដ្ឋដែលតំណាងដោយរដ្ឋអាចសម្រេចឱ្យមានការធ្វើអាជីវកម្មលើតក្កកម្ម ទោះបី ជាម្ចាស់ប្រកាសនីយបត្រតក្កកម្មនោះពុំផ្តល់ឆន្ទៈយល់ព្រមក៏ដោយ ។ ការអនុញ្ញាតនេះអាចស្តែងឡើងក្រោមរូបភាពពីរយ៉ាងផ្សេងគ្នា មួយការអនុញ្ញាតឱ្យធ្វើអាជីវកម្មដោយរដ្ឋាភិបាល ឬដោយបុគ្គលដែលបានទទួលការអនុញ្ញាតពីរដ្ឋាភិបាល និងក៏អាចជាអាជ្ញាបណ្ណ័បញ្ជា។ ដោយសារតែការអនុញ្ញាតក្រោមទម្រង់ទាំងពីរនេះសុទ្ធសឹងតែត្រូវបានសម្រេចដោយអាជ្ញាធររដ្ឋ ដោយពុំអាចផ្ទេរបន្តតាមឆន្ទៈខ្លួនទៅបុគ្គលផ្សេងទៀតបានដោយសេរីបានទេ លើកលែងតែមានការយល់ព្រមពីអាជ្ញាធររដ្ឋនោះ។ ប៉ុន្តែដោយសារតែវាជាសិទ្ធិបេតិកភ័ណ្ឌ វាក៏ជាផ្នែកមួយនៃទ្រព្យសកម្មរបស់អ្នកទទួលបានអាជ្ញាបណ្ណ័ជារូបវន្តបុគ្គល ឬមូលនិធិពាណិជ្ជកម្មរបស់សហគ្រាសដែល នឹងផ្ទេរបានក្នុងករណីពិសេសមួយចំនួន ដូចជាការផ្ទេរបានក្នុងករណីពិសេសមួយចំនួន ដូចជាការផ្ទេរជាមួយទ្រព្យ ឬមូលនិធិពាណិជ្ជកម្មទាំងមូល ដោយមូលហេតុបំណុលក្ស័យធន ទទួលមរណៈភាព ឬដោយលក់មូលនិធិពាណិជ្ជកម្មនោះ។ល។

➢ **ការធ្វើអនុប្បទានសិទ្ធិលើប្រកាសនីយបត្រ**

សម្រាប់កិច្ចសន្យាលក់ សិទ្ធិ ហៅម៉្យាងទៀតថា ការធ្វើអនុប្បទានសិទ្ធិ គឺជាកិច្ចសន្យាដែលតាមនោះ អនុប្បទា(អ្នកធ្វើអនុប្បទានដែលជាម្ចាស់ប្រកាសនីយបត្រតក្កកម្ម) សម្រេចផ្ទេរនូវសិទ្ធិកម្មសិទ្ធិលើប្រកាសនីយបត្រតក្កកម្មដែលខ្លួនមានទៅឱ្យអនុប្បទានិក (តតិយជនដែលត្រូវទទួលសិទ្ធិ) ជាថ្នូរ នឹងកម្រៃណាមួយ (តាវកាលិក)។ ពុំមានរបបគតិយុត្តដោយឡែកណាមួយដែលច្បាប់ស្តីពី ប្រកាសនីយបត្រតក្កកម្មនេះកំណត់ឱ្យឡើយ ដូចនេះត្រូវអនុវត្តរបបគតិយុត្តនៃវិធានរួម ពិសេសគឺវិធាន នៃកិច្ចសន្យាទិញលក់ ។ ម៉្យាងទៀត បើប្រកាសនីយបត្រតក្កកម្ម គឺជាសិទ្ធិរួមគ្នារបស់បុគ្គលពីរ ឬច្រើននាក់នោះការផ្ទេរនេះអាចធ្វើទៅតាមចំណែកនៃសិទ្ធិដែលបុគ្គលម្នាក់ៗមានប៉ុណ្ណោះ។ តាមយន្តការនៃ កិច្ចសន្យាប្រភេទនេះ កាតព្វកិច្ចមួយចំនួនដែលបានអនុប្បទាយី ត្រូវធានាដល់

[38] ច្បាប់ស្តីពី ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍និងគំនូរឧស្សាហកម្ម មាត្រា ១១៥ ។

អនុប្បទានិកគឺត្រូវតែមាន ជាពិសេសគឺការធានាអំពីសុពលភាពនៃប្រកាសនីយបត្រតក្កកម្ម ដែលជាកម្មវត្ថុនៃកិច្ចសន្យានេះតែម្តង។

➢ **ការផ្តល់អាជ្ញាប័ណ្ណសិទ្ធិចំពោះប្រកាសនីយបត្រ**

សម្រាប់កិច្ចសន្យាជួលសិទ្ធិ ឬហៅម៉្យាងទៀតថា ការផ្តល់អាជ្ញាប័ណ្ណ គឺជាកិច្ចសន្យាដែលមិនសំដៅផ្ទេរសិទ្ធិកម្មសិទ្ធិលើប្រកាសនីយបត្រតក្កកម្មនោះឡើយ ។ តាមយន្តការនេះ ម្ចាស់នៃប្រកាសនីយបត្រតក្កកម្ម ដែលនៅក្រោយការបង្កើតកិច្ចសន្យានេះ នៅតែជាម្ចាស់សិទ្ធិលើ ប្រកាសនីយបត្រតក្កកម្មដែលនោះ សម្រេចអនុញ្ញាតផ្តល់សិទ្ធិធ្វើអាជីវកម្មលើតក្កកម្មរបស់ខ្លួន (ទាំងមូល ឬដោយផ្នែក) ទៅដល់បុគ្គលម្នាក់ហៅថាជាអ្នកទទួលបានអាជ្ញាប័ណ្ណ ជាថ្នូរនឹងកម្រៃណាមួយ។ ជាទូទៅកិច្ចសន្យា ប្រភេទនេះអាចត្រូវបានប្រដូចនឹង កិច្ចសន្យាជួលទូទៅផលដែរ ពោលគឺអាចធ្វើឡើងដោយមាន ការកម្រិតសិទ្ធិដែលត្រូវអនុញ្ញាតនោះ ឬដោយគ្មានកម្រិតសិទ្ធិ។ ក្នុងករណីដដែលនៃកិច្ចសន្យាពុំបាន ហាមឃាត់អ្នកទទួលបានអាជ្ញាប័ណ្ណ អាចសម្រេចជួលសិទ្ធិនេះបន្តទៅឱ្យបុគ្គលផ្សេងទៀតផងដែរ អាជ្ញាប័ណ្ណបន្ត។ កិច្ចសន្យាអាជ្ញាប័ណ្ណនៃប្រកាសនីយបត្រតក្កកម្ម ឬវិញ្ញាបនបត្រម៉ូលដែលមានអត្ថប្រយោជន៍ ឬគំនូរឧស្សាហកម្មដែលបានចុះបញ្ជីរួចហើយ ឬសំណុំ លិខិត ករណីខាងលើនេះ ត្រូវដាក់ជូនទៅមន្ត្រីកាន់កាប់បញ្ជី។[39] មន្ត្រីកាន់កាន់បញ្ជីត្រូវរក្សា ការសម្ងាត់ដែលមាននៅក្នុងសន្យាអាជ្ញាប័ណ្ណនេះ មិនមានអានុភាពភាគីទីបីឡើយ រហូតដល់ការកត់ត្រាចូលបញ្ជីត្រូវធ្វើរួមជាស្ថាពរ។

**២.៣.៥.៤. ការធ្វើអាជីវកម្មដោយរដ្ឋាភិបាលឬដោយបុគ្គលទទួលបានការអនុញ្ញាតពីរដ្ឋាភិបាល**

ការសម្រេចអនុញ្ញាត ត្រូវតែឈរលើមូលដ្ឋាននៃការបម្រើផលប្រយោជន៍ សាធារណៈឬមូលហេតុនៃការធានាឱ្យមានការប្រកួតប្រជែងមួយដោយស្មោះត្រង់។[40] ដើម្បីបុព្វខាងលើទាំងពីរខាងលើនេះ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មអាចជ្រើសរើសតតិយជនណាម្នាក់ដែលអាចជាអង្គភាពចំណុះរដ្ឋ ឬឯកជនសុទ្ធសាធ ឱ្យធ្វើអាជីវកម្មលើតក្កកម្មបាន ទោះបីគ្មានការយល់ព្រមពីម្ចាស់នៃប្រកាសនីយបត្រតក្កកម្មក៏ដោយ។ ការពិតទៅការសម្រេចនេះអាចត្រូវបានចាត់ ទុកដូចជាការសម្រេចបង្ខំ ឱ្យម្ចាស់ប្រកាសនីយបត្រតក្កកម្ម ធ្វើអាជ្ញាបណ្ណ័លើតក្កកម្មរបស់ខ្លួនដោយគ្រាន់តែតាមរយៈយន្តការនេះ ម្ចាស់នៃប្រកាសនីយបត្រតក្កកម្មនឹងបាត់បង់សេរីភាពក្នុងការចុះកិច្ចសន្យា ពីព្រោះការសម្រេចជ្រើសរើស ដៃគូនៃកិច្ចសន្យាប្រភេទអាជ្ញាប័ណ្ណនេះ និងការកំណត់អំពីខ្លឹមសារនៃកិច្ចសន្យានេះ ត្រូវធ្វើឡើងដោយ រដ្ឋមន្ត្រីប៉ុណ្ណោះ។ ក្រៅពីនេះនៅពេលតក្កករបានធ្វើអាជីវកម្មលើតក្កកម្មខុស

---

[39] ច្បាប់ស្តីពី ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍និងគំនូរឧស្សាហកម្ម មាត្រា ១១៥ ។

[40] ច្បាប់ស្តីពី ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍និងគំនូរឧស្សាហកម្ម មាត្រា៤៧(១)។

ច្បាប់ រដ្ឋមានសិទ្ធិរឹបអូសមកធ្វើជាសម្បត្តិរបស់សាធារណៈដោយគ្មានការតវ៉ា ។ ប៉ុន្តែម្ចាស់ប្រកាសនីយបត្រនៅតែជាម្ចាស់នៃអាជ្ញាប័ណ្ណដែលមានសិទ្ធិទទួលបានផលប្រយោជន៍សមរម្យដូចករណីអាជ្ញាប័ណ្ណទៅដដែល។ លើសពីនេះទៀត យន្តការនៃអាជ្ញាប័ណ្ណដោយការសម្រេចរបស់រដ្ឋនេះ ផ្តល់អំណាចសម្រេចធំធេងណាស់ដល់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មនេះ ។[41] រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម អាចសម្រេចកែប្រែលើខ្លឹមសារនៃអាជ្ញាបណ្ណ ឬសម្រេចបញ្ចប់អាជ្ញាបណ្ណ នៅក្នុងសុពលភាពនៃអាជ្ញាបណ្ណនោះក៏បាន។

ជាចុងក្រោយ ការអនុញ្ញាតនេះ គឺគ្រាន់តែជាសេចក្តីសម្រេចរដ្ឋបាលដែលនៅ ក្នុងករណីមិនពេញចិត្តនឹងសេចក្តីសម្រេចនេះ ម្ចាស់ប្រកាសនីយបត្រតក្កកម្មនៅតែមាន សិទ្ធិប្តឹងប្រឆាំងតវ៉ាទៅតុលាការមានសមត្ថកិច្ចបាន។[42]

- **អាជ្ញាបណ្ណបញ្ញា**

អាជ្ញាបណ្ណប្រភេទនេះ គឺជាកិច្ចសន្យាដែលតាមនោះ រដ្ឋបង្ខំឱ្យម្ចាស់ប្រកាសនីយបត្រតក្កកម្ម បង្កើតកិច្ចសន្យាព្រមព្រៀងមួយជាមួយនឹងតតិយជន ណាម្នាក់តាមការស្នើសុំរបស់តតិយជនគឺ នោះនៅក្រោមរូបភាពជាទណ្ឌកម្មនៃការមិន ធ្វើអាជីវកម្មដែលបានចុះបញ្ជី រួចហើយរបស់ម្ចាស់នៃប្រកាសនីយបត្រតក្កកម្មនោះ។

ដើម្បីទទួលបាននូវសិទ្ធិធ្វើអាជីវកម្មតាមរយៈអាជ្ញាបណ្ណនេះ ក៏បានតម្រូវឱ្យតតិយជនដែលជាអ្នកស្នើសុំត្រូវបង្ហាញភស្តុតាងអំពីលក្ខខណ្ឌដូចច្បាប់កំណត់។ លក្ខខណ្ឌទាំងនោះជាពីរ មួយដោយសារតែមិនធ្វើអាជីវកម្ម ឬធ្វើអាជីវកម្មមិនពេញលេញ នៅក្នុងព្រះរាជាណាចក្រកម្ពុជា អ្នកទទួលបានអាជ្ញាប័ណ្ណមានកាតព្វកិច្ចអនុវត្តធ្វើអាជីវកម្មលើតក្កកម្មឱ្យបានពេញលេញតាមលក្ខខណ្ឌច្បាប់។[43] ម៉្យាងទៀត គឺដោយសារតែមានជម្លោះលើការធ្វើអាជីវកម្មលើ ប្រកាសនីយបត្រតក្កកម្មទាក់ទងគ្នា ។ បុព្វហេតុនៃការបង្កើតអាជ្ញាប័ណ្ណប្រភេទនេះគឺដើម្បីជៀសវាងនូវជម្លោះក្នុងការរំលោភសិទ្ធិគ្នានៃ ប្រកាសនីយបត្រតក្កកម្មនីមួយៗនេះនាពេលធ្វើអាជីវកម្មប៉ុណ្ណោះ ។

### ២.៣.៦. អាជ្ញាយុកាលនៃសិទ្ធិការពារប្រកាសនីយបត្រតក្កកម្ម

ប្រកាសនីយបត្រតក្កម្មដែលទទួលស្គាល់ដោយច្បាប់ ឬត្រូវបានទទួលស្គាល់តែនៅក្នុងកំឡុងពេលដែលច្បាប់កំណត់ឱ្យ ។ ប្រកាសនីយបត្រតក្កកម្ម មានរយៈពេលការពារ ២០ឆ្នាំ (ម្ភៃឆ្នាំ) គិតចាប់ពីកាលបរិច្ឆេទសុំចុះបញ្ជីនៃការស្នើសុំប្រកាសនីយបត្រតក្កកម្មនេះមក។[44]

[41] ច្បាប់ស្តីពី ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍និងគំនូរឧស្សាហកម្មមាត្រា ៤៨ និង ៤៩ ។
[42] ច្បាប់ស្តីពី ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍និងគំនូរឧស្សាហកម្ម មាត្រា៥៥ ។
[43] ច្បាប់ស្តីពី ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍និងគំនូរឧស្សាហកម្ម មាត្រា ៥៨។
[44] ច្បាប់ស្តីពី ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍និងគំនូរឧស្សាហកម្ម មាត្រា៤៥ ។

ចំពោះបញ្ហានៃការពន្យារពេលនៃសិទ្ធិនេះ ឬការចុះបញ្ជីឡើងវិញ ក្រោយបញ្ចាក់សុពលភាពនៃ មានការប្រែប្រួលទៅតាម ប្រព័ន្ធច្បាប់នៃប្រទេសនីមួយៗ និងតាមវិស័យនីមួយៗផងដែរ ។ ដោយឡែកនៅព្រះរាជាណាចក្រកម្ពុជារយៈពេលនៃការការពារប្រកាសនីយបត្រតក្កកម្ម ពុំអាចធ្វើការពន្យារ ឬស្នើសុំឡើងវិញបានទេ ។ រយៈពេលដែលច្បាប់បានកំណត់នេះ តក្កករ ឬអ្នកទទួលបានសិទ្ធិបន្ត មានពេលវេលាសមរម្យក្នុងការទាញ យកផលប្រយោជន៍ពីស្នាដៃរបស់ខ្លួន ព្រោះវាមានរយៈពេលយូរល្មមសម្រាប់ការពារ ។ ដូចនេះប្រទេសសមាជិកនីមួយៗពិតជាអាចបង្កើតយន្តការការចុះបញ្ជីឡើងវិញ ឬពន្យាររយៈពេល ទៅតាមផលប្រយោជន៍នៃប្រទេសរៀងខ្លួនបាន ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ជាទ្រឹស្តីរយៈពេលនៃសុពលភាពនេះ ពុំដែលត្រូវបានផ្តល់ឱ្យយូរអង្វែងនោះទេ ពីព្រោះថាការពារ ដោយផ្តល់សិទ្ធិផ្តាច់មុខយូរពេកនឹងបង្អាក់ដល់ការស្រាវជ្រាវ និងអភិវឌ្ឍន៍ថ្មីៗរបស់ប្រទេសជាតិជាក់ជាមិនខាន ។ នៅពេលដែលសុពលភាពនេះត្រូវបានបញ្ចប់ តក្កម្មនោះ នឹងក្លាយទៅជាសម្បត្តិសាធារណៈរបស់រដ្ឋ។

ក្នុងករណីខ្លះ តក្កកម្មមួយចំនួនអាចត្រូវបាត់បង់នូវតម្លៃដោយខ្លួនឯង នៅពេលដែលតក្កករដដែលនេះ ឬតក្កករផ្សេងទៀតបានរកឃើញនូវតក្កកម្មថ្មីមួយដែលមានលក្ខណៈប្រសើរជាងមុន ដែលធ្វើឱ្យអ្នកប្រើប្រាស់សម្រេចចិត្តជ្រើសរើសអ្វីដែលប្រសើរជាងនេះគឺជាមូលហេតុធ្វើឱ្យតក្កកម្មដែលរកឃើញមុនបាត់បង់នូវតម្លៃបន្តិចម្តងៗ។ ទោះបីតក្កកម្មនោះផុតរយៈពេលនៃការការពារតាមផ្លូវច្បាប់ក៏ដោយក៏តក្កករនៅតែអាចបន្តប្រើប្រាស់តក្កកម្មរបស់ខ្លួនបានដដែល គ្រាន់តែគ្មានសិទ្ធិហាមឃាត់នូវរាល់ការធ្វើអាជីវកម្មផ្សេងៗ របស់មនុស្សទូទៅ។

## ២.៤. ទោសបញ្ញត្តិ

ទោសបញ្ញត្តិ ច្បាប់ចែងសម្រាប់ផ្តន្ទាទោសចំពោះបុគ្គលទាំងឡាយណាដែល ប្រព្រឹត្តខុស និងអំពើរំលោភបំពានទៅលើប្រកាសនីយបត្រតក្កកម្ម ឬ សិទ្ធិរបស់តក្កកម្មរបស់អ្នកផ្សេង។ មិនត្រឹមតែប៉ុណ្ណោះក៏បញ្ញត្តិអំពីយន្តការក្នុងការដោះស្រាយ ការរំលោភបំពានរបស់តក្កករ។

### ២.៤.១. អំពើរំលោភសិទ្ធិ

ការរំលោភ គឺជាការអនុវត្តន៍សកម្មភាពរំលោភសិទ្ធិទាំងឡាយនៅក្នុងព្រះរាជាណាចក្រកម្ពុជាដោយបុគ្គលដទៃទៀតដោយគ្មានការព្រមព្រៀងពីម្ចាស់តក្កកម្មដែលទទួលបានសិទ្ធិដូចមានចែងក្នុងច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម។[45]

ជាទូទៅ តក្កកម្មដែលបាននូវសិទ្ធិក្នុងការការពារស្នាដៃរបស់ខ្លួនដោយស្រប ច្បាប់គាត់អាចសម្រេចថាតើជនណាម្នាក់មានឬ គ្មានសិទ្ធិក្នុងការទាញយកផលប្រយោជន៍ពីតក្កកម្មរបស់គាត់។ នៅក្នុងរយៈពេលនៃការ

[45] ច្បាប់ស្តីពី ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម មាត្រា ១២៥ ។

ការពារតាមច្បាប់តក្កកម្មមានសិទ្ធិគ្រប់យ៉ាងដើម្បីប្រឆាំងនឹងតតិយជន ក្នុងការទាញផលប្រយោជន៍ដោយពុំមានការអនុញ្ញាត ព្រោះរាល់សកម្មភាពនៃការរំលោភទាំងឡាយដែលសកម្មភាពទាំងនោះ ត្រូវបានកំណត់ថាទាញយកនូវផលប្រយោជន៍ពីតក្កកម្មដោយខុសច្បាប់ តក្កករ ឬជនដែលមានផលប្រយោជន៍ពាក់ព័ន្ធ អាចដាក់ពាក្យប្តឹងទៅតុលាការបាន ប៉ុន្តែការដាក់ពាក្យប្តឹងនោះត្រូវបង្ហាញនូវ វត្ថុតាងឱ្យបានច្បាស់លាស់ ថាពិតជាមានការរំលោភបំពានកើតឡើងប្រាកដមែន។ ការបង្ហាញភស្តុងតាងស្តីពីការរំលោភសិទ្ធិត្រូវតែមានទំនាក់ទំនងទៅនឹងផលិតផល ឬ ដំណើរការផលិតកម្មដែលស្ថិតក្នុងវិសាលភាពនៃការការពាររបស់ប្រកាសនីយបត្រតក្កកម្ម ។[46] ផ្ទុយទៅវិញចំពោះ ម្ចាស់សិទ្ធិដែលទទួលបានតាមរយៈកិច្ចសន្យាអនុប្បទាន ឬ តាមរយៈអាជ្ញាប័ណ្ណទាំងឡាយពុំអាចស្នើសុំទៅ តុលាការដោយផ្ទាល់នោះបានឡើយ ពោលគឺត្រូវស្នើសុំឱ្យម្ចាស់ប្រកាសនីយបត្រតក្កកម្មជាអ្នកប្តឹងផ្ទាល់ទើបបាន។

### ២.៤.២. យន្តការដោះស្រាយ

យន្តការដោះស្រាយក្នុងការរំលោភបំពានសិទ្ធិ មានយន្តការបណ្តោះអាសន្ន និង ស្ថាពររបស់តុលាការ ។ ទាក់ទងទៅនឹងយន្តការ ដោះស្រាយ ចំពោះករណីរំលោភសិទ្ធិរបស់ម្ចាស់ ប្រកាសនីយបត្រតក្កកម្មនេះ ច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម គ្រាន់តែបានបញ្ញត្តិអំពីយន្តការតុលាការ តែមួយមុខគត់។ តាមយន្តការនេះ តុលាការអាចសម្រេចឱ្យយន្តការជា បណ្តោះអាសន្ន នៅមុនពេលរកឃើញអំពីអត្ថិភាពនៃការរំលោភសិទ្ធិ ឬ ជាស្ថាពរតែម្តង នៅបន្ទាប់ពីបានរកឃើញនូវ ការរំលោភសិទ្ធិយ៉ាងប្រាកដ។

ចំពោះយន្តការបណ្តោះអាសន្ន តុលាការមានសមត្ថកិច្ចអាចនឹងចេញសេចក្តីសម្រេចបណ្តោះអាសន្នដើម្បីទប់ស្កាត់ការរំលោភ ឬ ការរំលោភដែលប្រុងនឹងកើតមានឡើងនោះបាន ។ ប៉ុន្តែអ្វី ដែលជាបញ្ហាចោទចំពោះខ្លឹមសារ នៃមាត្រា១២៦ នេះគឺថា៖ ទីមួយ យន្តការបណ្តោះអាសន្ននេះ ហាក់អាចធ្វើទៅបាន លុះណាម្ចាស់ប្រកាសនីយបត្រតក្កកម្ម បានបដិសេធក្នុងការប្តឹងប្រឆាំងនឹង ការក្លែងបន្លំបន្ទាប់ពីមានសំណើពីម្ចាស់ដែលទទួលបានសិទ្ធិ ឬ អ្នកទទួលអាជ្ញាប័ណ្ណរួចហើយ ។ ទីពីរ តាមរយៈយន្តការនេះ ពិតមែនតែយន្តការបណ្តោះអាសន្ន ប៉ុន្តែតុលាការសម្រេចឱ្យមានការសងការខូចខាតដែលករណីនេះអាចនឹងនាំឱ្យផ្ទុយ ទៅនឹងគោលការណ៍យុត្តិធម៌ក្នុងការដាក់ទោសទណ្ឌ តាមរយៈសវនាការត្រឹមត្រូវមិនខាន។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ មាត្រានេះហាក់បានបើកផ្លូវឱ្យចៅក្រមអាចយកវិធានការ គតិយុត្តផ្សេងទៀតក្រៅអំពីច្បាប់ស្តីពីប្រកាសនីយបត្រ

[46] មេរៀន នីតិកម្មសិទ្ធិបញ្ញា សាស្ត្រាចារ្យ ឃឹម គីរី ទំព័រ ៣៥ និង ទំព័រ ៣៦ ឆ្នាំ២០០៩ ។

តក្កកម្មមកប្រើប្រាស់បានចំពោះការរំលោភសិទ្ធិនេះ ដូចជាច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ ក៏ដូចជាសិទ្ធិស្តីពីម៉ាកជាដើម។[47]

### ២.៤.៣. មោឃភាព

ប្រសិនបើតក្កករមានភស្តុតាងបញ្ជាក់ថា មានជនណាម្នាក់បានរំលោភសិទ្ធិរបស់ខ្លួន គាត់ដាក់ពាក្យប្តឹងទៅតុលាការសុំឱ្យធ្វើការរារាំង ឬទប់ស្កាត់ និងបញ្ឈប់នូវរាល់សកម្មភាពទាំងនោះបាន ។ ក្នុងករណី ប្រសិនបើមានតក្កកម្មមួយផ្សេងទៀតបានទទួលនូវ ប្រកាសនីយបត្រតក្កកម្ម ហើយតក្កករមានភស្តុតាងដែលទាក់ទងនឹងបញ្ហាផ្សេងទៀតដែលទាក់ទងទៅនឹងភាពមិនប្រក្រតីរបស់តក្កកម្មនោះ គឺគាត់អាចដាក់ពាក្យប្តឹងទៅតុលាការសុំឱ្យ ធ្វើមោឃភាពនូវប្រកាសនីយបត្រតក្កកម្ម។ ប្រសិនបើតុលាការរកឃើញថា មានភាពមិនប្រក្រតីមែននោះប្រកាសនីយបត្រតក្កកម្មនោះនឹងអស់ សុពលភាពចាប់ពីថ្ងៃចុះបញ្ជី ពោលគឺកាលបើមោឃៈភាពនៃប្រកាសនីយបត្រតក្កកម្ម ត្រូវបានប្រកាសដោយតុលាការ អានុភាពប្រតិសកម្មនៃមោឃៈនេះ នឹងបណ្តាលឱ្យរាល់សំណុំលិខិត និង ឯកសារគតិយុត្ត ទាំងឡាយដែលទាក់ទងនឹងប្រកាសនីយបត្រតក្កកម្មមោឃៈនេះ រួមមានសេចក្តីអះអាង ឬផ្នែកនៃសេចក្តីអះអាងផងត្រូវទុកជាមិនបានការនិងអស់សុពលភាពចាប់ពីថ្ងៃដែលចុះបញ្ជី។[48]

### ២.៤.៤. ទណ្ឌកម្ម

ជនដែលត្រូវបានរកឃើញថាមានកំហុស ហើយត្រូវបានផ្តន្ទាទោស តុលាការដែលមានសមត្ថកិច្ចអាចបញ្ជាឱ្យធ្វើការរឹបអូសទុកជាទ្រព្យសម្បត្តិរដ្ឋ ឬធ្វើការបំផ្លាញ់ចោលរាល់ទំនិញ ឬ ផលិតផលដែលបានមកពីការរំលោភសិទ្ធិនោះ និងរួមទាំងឧបករណ៍ទាំងអស់ ដែលយកមកប្រើប្រាស់ក្នុងការប្រព្រឹត្តអំពើនោះ។ មិនត្រឹមតែប៉ុណ្ណោះជនណាដែលរំលោភបំពានសិទ្ធិនិងត្រូវផ្តន្ទាទោសដូចជា៖

❖ <u>ទោសរដ្ឋប្បវេណី</u>

ក្នុងករណីដែលម្ចាស់ប្រកាសនីយបត្រតក្កកម្ម បានយកតក្កកម្មរបស់ខ្លួនទៅធ្វើអាជីវកម្មដោយខុសច្បាប់ ទោះពុំមានជនណាម្នាក់ដាក់ពាក្យប្តឹងក៏ដោយ ក៏តុលាការអាច នឹង ដកហូតនូវសិទ្ធិលើប្រកាសនីយបត្រកម្មនោះវិញបាន។[49] ប្រសិនបើមានបុគ្គលណាមួយបានយកតក្កកម្មរបស់អ្នកដទៃទៅប្រើប្រាស់ និងទាញយកផលប្រយោជន៍ដោយមិនមានការព្រមព្រៀងពីម្ចាស់តក្កកម្ម ក្នុងករណីនេះម្ចាស់ប្រកាសនីយបត្រតក្កកម្មអាចដាក់ពាក្យបណ្តឹងរដ្ឋប្បវេណីដើម្បីទាមទារសំណងខូចខាតដែលខ្លួនទទួលរងអំពើរំលោភបំពានសិទ្ធិនេះ។[50] ចំពោះការ

---

47 សៀវភៅ នីតិកម្មសិទ្ធិបញ្ញា សាស្ត្រាចារ្យ ទេព សុខ ទំព័រ ៤៤ ឆ្នាំ២០២០-២០២១ ។

48 មេរៀន នីតិកម្មសិទ្ធិបញ្ញា សាស្ត្រាចារ្យ ឃឹម គីរី ទំព័រ ៣៦ ឆ្នាំ២០០៩ ។

49 មេរៀន នីតិកម្មសិទ្ធិបញ្ញា សាស្ត្រាចារ្យ ឃឹម គីរី ទំព័រ ៣៧ ឆ្នាំ២០០៩ ។

50 ច្បាប់ស្តីពី ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍និងគំនូរឧស្សាហកម្ម មាត្រា ១៣២ និង មាត្រា ១៣៥ ។

ទាមទារសំណងរដ្ឋប្បវេណី ជាសិទ្ធិរបស់ម្ចាស់ប្រកាសនីយបត្រតក្កកម្មដែលជាជនរងគ្រោះ។ ច្បាប់ប្រកាសនីយបត្រតក្កកម្មនៃប្រទេសកម្ពុជាពុំបានចែងអំពីរូបមន្តដើម្បីកំណត់សំណងការខូចខាតឡើយ ហើយច្បាប់ក៏មិនបានបិទសិទ្ធិរបស់ម្ចាស់សិទ្ធិស្របច្បាប់ក្នុងការទាមទារសំណងលើការខូចខាតដែល កើតចេញពីអំពើរំលោភសិទ្ធិដោយតតិយជនដែរ។ តែការតាមទាមទារចំពោះសំណងនៃការខូចខាតនេះត្រូវបានធ្វើឡើងដោយម្ចាស់សិទ្ធិស្របច្បាប់ដោយផ្អែកទៅលើទំហំនៃពន្យសនកម្មដោយមានភស្តុតាងមកបញ្ជាក់អំពីទំហំពន្យសនកម្មដែលបានកើតឡើងដោយអំពើរំលោភសិទ្ធិផងដែរ។

❖ <u>ទោសព្រហ្មទណ្ឌ</u>

អំពើរំលោភសិទ្ធិនៃប្រកាសនីយបត្រតក្កកម្ម ក៏ជាកម្មវត្ថុនៃទណ្ឌកម្មព្រហ្មទណ្ឌផងដែរ។ ចំពោះបុគ្គលណាមួយដែលរំលោភដោយចេតនាសិទ្ធិរបស់ប្រកាសនីយបត្រតក្កកម្ម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ និងផ្តន្ទាទោសជាប្រាក់ ដូចបានបញ្ញត្តិដោយច្បាប់ ដោយត្រូវផ្តន្ទាទោសជាប្រាក់ពីប្រាំលាន (៥.០០០.០០០) រៀល ដល់ម្ភៃលាន (២០.០០០.០០០) រៀល ឬ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ មួយ (១) ឆ្នាំ ទៅ ប្រាំ(៥) ឆ្នាំ។[51] មួយវិញទៀតចំពោះបុគ្គលណាដែលផ្តល់ព័ត៌មានមិនពិតនៅក្នុងឯកសារដែលបានដាក់ជូនមន្ត្រីកាន់កាប់បញ្ជី ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ និងផ្តន្ទាទោសជាប្រាក់ ដូចបានបញ្ញត្តិដោយច្បាប់ ត្រូវផ្តន្ទាទោសជាប្រាក់ពីមួយលាន (១.០០០.០០០) រៀល ដល់ប្រាំ (៥.០០០.០០០) រៀល ឬ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ មួយ (១) ខែ ទៅប្រាំមួយ (៦) ខែ។

❖ <u>ទោសរដ្ឋបាល</u>

ក្នុងករណីមន្ត្រីមានសមត្ថកិច្ចណាដែលបានខុសឆ្គងក្នុងការអនុវត្តន៍ភារកិច្ចរបស់ខ្លួន ដែលបានផ្តល់ឱ្យស្របតាមច្បាប់នេះត្រូវ ទទួលរងការពិន័យផ្នែករដ្ឋបាលដោយពុំទាន់គិតដល់បទល្មើសព្រហ្មទណ្ឌផ្សេងទៀត។

---

51 ច្បាប់ស្តីពី ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍និងគំនូរឧស្សាហកម្ម មាត្រា ១៣៣ និង មាត្រា ១៣២ ។

# ជំពូកទី ៣

# ការចុះបញ្ជីប្រកាសនីយបត្រតក្ក

# កម្មអន្តរជាតិ

# ជំពូកទី ៣

# ការចុះបញ្ជីប្រកាសនីយបត្រតក្កកម្មអន្តរជាតិ

ប្រកាសនីយបត្រតក្កកម្មអន្តរជាតិ សំដៅលើតក្កករទាំងឡាយដែលមានគោលបំណងចង់ទទួលបានការការពារពីបណ្តាលប្រទេសជាច្រើនក្នុងពេលតែមួយបាន ដូច្នេះតក្កករត្រូវបំពេញបែបបទតាមនីតិវិធីចុះបញ្ជីតាមរយៈ សន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម ។ ដូចជា នីតិវិធីចុះបញ្ជីការដាក់ពាក្យស្នើសុំអន្តរជាតិ (ការបំពេញពាក្យអន្តរជាតិ ការិយាល័យទទួល ការស្រាវជ្រាវ ការផ្សព្វផ្សាយ ការត្រួតពិនិត្យ) ព្រមទាំង គុណសម្បត្តិ និង គុណវិបត្តិនៃការចុះបញ្ជីប្រកាសនីយបត្រតក្កកម្ម។

## ៣.១. នីតិវិធីនៃការចុះបញ្ជី

ដើម្បីទទួលបានការការពារប្រកាសនីយបត្រតក្កកម្មអន្តរជាតិ តក្កករត្រូវតែគោរពទៅតាមលក្ខខណ្ឌដូចជា ការដាក់ពាក្យស្នើសុំអន្តរជាតិ ការិយាល័យទទួល ការស្រាវជ្រាវ ការផ្សព្វផ្សាយ ការត្រួតពិនិត្យ ។

### ៣.១.១. ការដាក់ពាក្យស្នើសុំអន្តរជាតិ

ដើម្បីទទួលបានការការពារ អ្នកដាក់ពាក្យស្នើសុំ ត្រូវដាក់សំណុំលិខិតស្នើសុំអន្តរជាតិនៅការិយាល័យទទួលនោះ គឺអាចការយាល័យទទួលនោះ គឺអាចជាការិយាល័យថ្នាក់ជាតិ របស់រដ្ឋដែលជាសមាជិកណាមួយ ការិយាល័យកម្រិតតំបន់ ឬការិយាល័យអន្តរជាតិនៃអង្គការកម្មសិទ្ធិបញ្ញាពិភពលោក ហើយសំណុំលិខិតស្នើសុំអន្តរជាតិនោះត្រូវគោរពតាមលក្ខខណ្ឌដូចនឹងលក្ខខណ្ឌនៃសំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្មជាតិផងដែរ ពោលគឺត្រូវមានពាក្យសុំ សេចក្តីអត្ថាធិប្បាយអំពីតក្កកម្ម សេចក្តីអះអាង ខ្លឹមសារសង្ខេប និងគំនូសបង្ហាញ (ក្នុងករណីបើមានគំនូសបង្ហាញ)។

➢ <u>ពាក្យសុំ</u>

ដើម្បីដាក់សំណុំលិខិតស្នើសុំអន្តរជាតិ អ្នកដាក់ពាក្យស្នើសុំត្រូវបំពេញបែបបទតាមទម្រង់ដែលបានកំណត់ជាអន្តរជាតិសម្រាប់សមាជិក PCT ដែលទម្រង់នៃពាក្យសុំនេះ តម្រូវឱ្យអ្នកស្នើសុំត្រូវបង្ហាញព័ត៌មានអំពីសំណុំលិខិតស្នើសុំ អន្តរជាតិលម្អិត ។ ជាគោលការណ៍ពាក្យសុំត្រូវមានព័ត៌មានចាំបាច់ដូចខាងក្រោមៈ

- ឈ្មោះ និងទន្និន័យផ្សេងទៀតពាក់ព័ន្ធនឹងអ្នកដាក់ពាក្យសុំ និងភ្នាក់ងារ ឬអ្នកតំណាង អំពីអាស័យដ្ឋាន សញ្ជាតិ ប្រទេស
- ចំណងជើងរបស់តក្កកម្មខ្លី និងច្បាស់លាស់ (គួរតែចាប់ពី ពីរពាក្យទៅប្រាំពីរពាក្យ)

- ព្រមទាំងឈ្មោះ និងទន្និន័យផ្សេងទៀតពាក់ព័ន្ធតក្កកម្ម ដែលច្បាប់ជាតិរបស់រដ្ឋជម្រើសរើស តម្រូវឱ្យបញ្ជាក់នៅពេលសំណុំលិខិតស្នើសុំជាតិ។[52]

➢ **<u>សេចក្តីអត្ថាធិប្បាយ</u>**

សេចក្តីអត្ថាធិប្បាយ គឺជាការពន្យល់អំពីតក្កកម្មក្នុងលក្ខណៈច្បាស់លាស់និង ពេញលេញដើម្បីឱ្យបុគ្គលដែលមានកម្រិតជំនាញធម្មតាក្នុងជំនាញអាចអនុវត្តបាននូវតក្កកម្មនោះ។ សេចក្តីអត្ថាធិប្បាយអំពីតក្កកម្មត្រូវមានចំណុចសំខាន់ៗដូចខាងក្រោមៈ

- មានចំណាងជើងតក្កកម្ម និងអំពីជំនាញក្នុងវិស័យដែលយកទៅប្រើប្រាស់
- មានព័ត៌មានទូទៅអំពីបច្ចេកវិទ្យាពាក់ព័ន្ធ នឹងតក្កកម្ម
- ពន្យល់អំពីបញ្ហាដែលកំពុងជួបប្រទះហើយបញ្ជាក់ថា តក្កកម្មនេះបានដោះស្រាយបញ្ហាកំពុងជួបប្រទះ និងឥទ្ធិពលជាវិជ្ជមានដល់សង្គមពន្យល់សង្ខេបអំពីបច្ចេកទេសនៃការប្រើប្រាស់ តក្កកម្មដែលល្អជាងគេ។
- បញ្ជាក់ថាតក្កកម្មអាចយកទៅប្រើប្រាស់ក្នុងវិស័យឧស្សាហកម្ម ។[53]
- **<u>សេចក្តីអះអាង</u>**

សេចក្តីអះអាង គឺជាការកំណត់ឱ្យបានច្បាស់លាស់ អំពីចំណុចដែលចង់សុំឱ្យមានការការពារដូច្នេះ សេចក្តីអះអាងត្រូវតែបញ្ជាក់ឱ្យបានច្បាស់លាស់ និងភ្ជាប់មកជាមួយនូវគំនូសបង្ហាញនៃតក្កកម្មនោះ។ ក្នុងករណីសំណុំស្នើសុំអន្តរជាតិនោះមាន សេចក្តីអះអាងច្រើនជាងមួយអ្នកដាក់ពាក្យសុំត្រូវដាក់លេខជាលំដាប់ នៃសេចក្តីអះអាងនោះ។

- **<u>គំនូសបង្ហាញ</u>**

សំណុំលិខិតស្នើសុំអន្តរជាតិ ចាំបាច់ត្រូវមានគំនូសបង្ហាញដើម្បីពន្យល់អំពីតក្កកម្ម ដែលបានដាក់ពាក្យស្នើសុំនោះ ។ **ឧទាហរណ៍** ប្រសិនបើតក្កម្មពាក់ព័ន្ធនឹងប្រព័ន្ធ មេកានិច និងអគ្គិសនីគំនូសតាងបង្ហាញចាំបាច់ត្រូវមាននៅក្នុងសំណុំលិខិតស្នើសុំ។ នៅក្នុងគំនូសបង្ហាញនេះ អ្នកដាក់ពាក្យស្នើសុំត្រូវមានដាក់លេខ និងពន្យល់អំពីតួនាទី និងដំណើរការរបស់តក្កកម្មឱ្យបានច្បាស់លាស់។

[52] សិន្និសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម មាត្រា៤, ៤៣, ៤៤, ៤៥ និង ស្តីពី វិធានក្រោមសន្និសញ្ញាសហប្រតិបត្តិការ ប្រការ ៣,៤ ។

[53] សិន្និសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម មាត្រា៥ ។

- **ខ្លឹមសារសង្ខេបនៃតក្កកម្ម**

ខ្លឹមសារសង្ខេប គឺជាសេចក្តីសង្ខេបអំពីព័ត៌មានបច្ចេកទេស របស់តក្កកម្មក្នុងគោលបំណងពន្យល់ដោយសង្ខេបច្បាស់លាស់អំពីការបង្កើត និងការប្រើប្រាស់ក្នុងការដោះស្រាយបញ្ហាបច្ចេកទេសរបស់តក្កកម្មនោះ។ ខ្លឹមសារសង្ខេបត្រូវសរសេរបានពី ៥០ ទៅ ១៥០ ពាក្យជាភាសាអង់គ្លេស។

### ៣.១.២. ការិយាល័យទទួល

ការិយាល័យទទួល គឺជាការិយាល័យដែលមានសមត្ថភាពទទួលសំណុះលិខិតស្នើសុំចុះបញ្ជីក្រោយនីតិវិធីនៃសិន្ធសញ្ញា PCT ទទួលថវិកាពាក់ព័ន្ធ និងការចុះបញ្ជី និងត្រួតពិនិត្យលើសំណុំលិខិតស្នើសុំដែលបានបំពេញតាមលក្ខខណ្ឌតម្រូវរបស់ PCTដើម្បីទទួលបានការចុះបញ្ជីជាអន្តរជាតិ។[54]

ផ្អែកតាមមាត្រា ១៩ នៃវិធានស្ថិតក្រោមសន្ធិសញ្ញា PCT បានកំណត់បានការិយាល័យទទួលគឺអាចជា៖

- ការិយាល័យចុះបញ្ជីជាតិ នៃប្រទេសហត្ថលេខី
- ប្រទេសហត្ថលេខីមួយនៃសន្ធិសញ្ញា PCT បានព្រមព្រៀងជាមួយ នឹងប្រទេសហត្ថលេខីសន្ធិសញ្ញា PCT ឬអង្គការអន្តរជាតិរដ្ឋាភិបាលមួយថា ការិយាល័យចុះបញ្ជីជាតិ របស់ខ្លួនគឺជាការិយាល័យទទួលជំនួសរដ្ឋហត្ថលេខី ឬអង្គការអន្តររដ្ឋាភិបាល ដែលស្នើសុំនោះ
- ការិយាល័យអន្តរជាតិរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក។

❖ **ការពិនិត្យសំណុំលិខិតស្នើសុំអន្តរជាតិ**

ដើម្បីពិនិត្យសំណុំលិខិតស្នើសុំ ការិយាល័យទទួលត្រូវពិនិត្យមើលលើចំណុចពីរសំខាន់ទី១ ពិនិត្យលើលក្ខខណ្ឌដើម្បីទទួលកាលបរិច្ឆេទនៃការចុះបញ្ជីអន្តរជាតិ។

ផ្អែកតាមមាត្រា ១១ (១) ការិយាល័យទទួលត្រូវចុះកាលបរិច្ឆេទនៃការសុំចុះបញ្ជីលើសំណុំលិខិតស្នើសុំអន្តរជាតិ នៅពេលសំណុំលិខិតនេះបានបំពេញតាមលក្ខខណ្ឌខាងក្រោមត្រឹមត្រូវ៖

- អ្នកដាក់ពាក្យ មានអាស័យដ្ឋាន ឬមានសញ្ជាតិនៃប្រទេសដែលជាសមាជិកសន្ធិសញ្ញា PCT
- សំណុំលិខិតស្នើសុំអន្តរជាតិត្រូវមានភាសាដែលបានកំណត់
- សំណុំលិខិតស្នើសុំអន្តរជាតិត្រូវមានយ៉ាងហោចណាស់នូវធាតុទាំងឡាយដូចតទៅ
  - ការបញ្ជាក់ថាសំណុំលិខិតស្នើសុំនេះត្រូវបានគ្រោងទុកជាសំណុំលិខិតស្នើសុំអន្តរជាតិ
  - មានការជ្រើរើសយ៉ាងហោចណាស់ក៏មានរដ្ឋហត្ថលេខីមួយ

---

[54] សិន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម មាត្រា ១០។

- មានឈ្មោះរបស់អ្នកដាក់ពាក្យសុំយ៉ាងតិចម្នាក់
- មានផ្នែកមួយនៃសេចក្តីអត្ថាធិប្បាយ
- និងមានផ្នែកមួយនៃសេចក្តីអះអាង។

ក្នុងករណីបើសំណុំលិខិតស្នើសុំមិនបានបំពេញតាមលក្ខខណ្ឌខាងលើនេះ ការិយាល័យទទួល នឹងអញ្ជើញអ្នកដាក់ពាក្យសុំឱ្យមកកែតម្រូវក្នុងរយៈពេល២ខែបន្ទាប់ពីចេញ លិខិតអញ្ជើញឱ្យធ្វើការកែតម្រូវ ហើយការកំណត់កាលបរិច្ឆេទនៃការសុំចុះបញ្ជីអន្តរជាតិនឹង ត្រូវផ្តល់ឱ្យនៅពេលអ្នកដាក់ពាក្យសុំបានបំពេញសំណុំបែបបទត្រឹមត្រូវ និងចប់សព្វគ្រប់តាមលក្ខខណ្ឌដែលបានកំណត់។

បន្ទាប់ពីបានពិនិត្យលើចំណុចទី១ដូចមានកំណត់ក្នុងមាត្រា ១១ការពិនិត្យសំណុំលិខិតស្នើសុំអន្តរជាតិក៏ត្រូវផ្អែកតាមមាត្រា ១៤ ពោលការិយាល័យទទួល ក៏និងត្រូវពិនិត្យលើភាពខ្វះខាតចន្លោះលើសំណុំលិខិតស្នើសុំអន្តរជាតិដូចខាងក្រោម៖

- មិនមានចុះហត្ថលេខា
- មិនមានការបញ្ជាក់ដូចបានកំណត់ពាក់ព័ន្ធអ្នកដាក់ពាក្យសុំ
- មិនមានចំណងជើងតក្កកម្ម
- មិនមានខ្លឹមសារសង្ខេប
- មិនបានបំពេញតាមការកំណត់ក្នុងបទបញ្ជា ព្រមទាំងការតម្រូវផ្នែករូបសាស្ត្រ។

ក្នុងករណីដែលសំណុំលិខិតស្នើសុំអន្តរជាតិមិនបានបំពេញតាមលក្ខខណ្ឌខាងលើ ការិយាល័យទទួលនឹងអញ្ជើញអ្នកដាក់ពាក្យសុំមកកែតម្រូវក្នុងរយៈកំណត់ តែការឱ្យមកកែតម្រូវនេះនឹងមិនប៉ះពាល់ដល់កាលបរិច្ឆេទនៃការចុះបញ្ជីអន្តរជាតិនោះទេ ។ ក៏ប៉ុន្តែក្នុងករណីមានការខកខានមិនបានកែតម្រូវក្នុងរយៈពេលកំណត់នោះទេ សំណុំលិខិតស្នើសុំអន្តរជាតិនោះត្រូវចាត់ទុកថាបានដកចេញពីនីតិវិធីចុះបញ្ជីតាមសន្ធិសញ្ញា PCT។

ជាចុងក្រោយនៅពេលទទួលបានកាលបរិច្ឆេទចុះបញ្ជីអន្តរជាតិ ការិយាល័យទទួលនឹងធ្វើសេចក្តីជូនដំណឹងអំពីកាលបរិច្ឆេទនៃការចុះបញ្ជីអន្តរជាតិ និង លេខសំណុំលិខិតស្នើសុំអន្តរជាតិទៅឱ្យអ្នកដាក់ពាក្យសុំបានដឹង។

❖ <u>**ការទាមទារ និងលក្ខខណ្ឌសិទ្ធិអាទិភាព**</u>

សំណុំលិខិតស្នើសុំអន្តរជាតិអាចមានការទាមទារអាទិភាព ចំពោះតក្កកម្មរបស់ខ្លួនដែលទទួលបានការការពារកន្លងមក។ ដូច្នេះអ្នកដាក់ពាក្យសុំត្រូវដាក់ពាក្យទាមទារអាទិភាពដោយបញ្ជាក់ឱ្យច្បាស់អំពីប្រទេសដែលបានចុះបញ្ជីអំពីកាលបរិច្ឆេទ និងលេខនៃសំណុំលិខិត និងអំពីការិយាល័យទទួល។

អ្នកដាក់ពាក្យសុំត្រូវដាក់ពាក្យទាមទារអាទិភាពក្នុងរយៈពេល ១២ខែ គិតចាប់ពីកាលបរិច្ឆេទនៃការចុះលេខលើសំណុំលិខិតលើកដំបូង។ ករណីដែលអ្នកដាក់ពាក្យសុំមិនដាក់សំណុំលិខិតស្នើសុំអន្តរជាតិ ក្នុងរយៈពេល ១២ខែទេអ្នកដាក់ពាក្យសុំអាចស្នើសុំទាមទារឱ្យផ្តល់អាទិភាពម្តងទៀត ក្នុងរយៈពេល ២ខែគិតចាប់ពីកាលបរិច្ឆេទនៃការផុតកំណត់រយៈពេលទាមទារអាទិភាព។ ដូច្នេះអ្នកដាក់ពាក្យសុំតម្រូវឱ្យធ្វើសេចក្តីថ្លែងការណ៍ ឬភស្តុតាងដើម្បីបញ្ជាក់ពីមូលហេតុដែលមិនបានដាក់សំណុំលិខិតស្នើសុំអន្តរជាតិទាន់ពេលវេលាកំណត់។[55]

លក្ខខណ្ឌដែលទទួលបានសិទ្ធិអាទិភាពអ្នកដាក់ពាក្យសុំត្រូវ ប្រគល់សំណុំឯកសារស្នើសុំដំបូងទៅការិយាល័យទទួលក្នុងរយៈពេល ១៦ខែគិតចាប់ពីថ្ងៃទទួលបានសិទ្ធិអាទិភាពដំបូង។ ប្រសិនបើឯកសារទាមទារសិទ្ធិអាទិភាពចេញដោយការិយាល័យ ដូច្នេះអ្នកដាក់ពាក្យសុំត្រូវស្នើសុំការិយាល័យទទួលរៀបចំឯកសារទាមទារសិទ្ធិអាទិភាព និងបញ្ជូនឯកសារទាំងនោះទៅការិយាល័យអន្តរជាតិ ក្នុងរយៈពេល ១៦ខែ និងមុនការបោះផ្សាយជាអន្តរជាតិ។

❖ <u>**ភាសារប្រើប្រាស់ក្នុងសំណុំលិខិតស្នើសុំអន្តរជាតិ**</u>

ភាសាដែលប្រើប្រាស់ជាផ្លូវការសម្រាប់សំណុំលិខិតស្នើសុំអន្តរជាតិ ត្រូវតែជា៖

- ភាសាដែលទទួលស្គាល់ដោយអាជ្ញាធរស្រាវជ្រាវអន្តរជាតិ
- ភាសាសម្រាប់បោះពុម្ពផ្សាយ មានដូចជា ភាសាអារ៉ាប់ ចិន អង់គ្លេស បារាំង អាល្លឺម៉ង់ ជប៉ុន កូរ៉េ ព័រទុយហ្គាល ឬអេស្ប៉ាញ ឬ
- ភាសាដែលទទួលស្គាល់ដោយ ការិយាល័យទទួល។

ករណីដែលសំណុំលិខិតស្នើសុំអន្តរជាតិ មិនបានប្រើប្រាស់ភាសា ដែលបានកំណត់តាមលក្ខខណ្ឌ ខាងលើ អ្នកដាក់ពាក្យសុំត្រូវតែបកប្រែសំណុំលិខិតស្នើសុំអន្តរជាតិជាភាសារដែលបានកំណត់ក្នុងរយៈពេល ០១ខែ បន្ទាប់ពីការិយាល័យទទួលបានទទួលនូវសំណុំលិខិតស្នើសុំអន្តរជាតិនោះ ។ ប្រសិនមិនបកប្រែទាន់ពេលវេលាកំណត់នោះទេការិយាល័យទទួល នឹងប្រកាសថាសំណុំលិខិតស្នើសុំអន្តរជាតិនោះ នឹងដកចេញពីនីតិវិធីចុះបញ្ជីតាមសន្ធិសញ្ញា PCT។

### ៣.១.៣. ការស្រាវជ្រាវអន្តរជាតិ និងរបាយការណ៍ស្រាវជ្រាវអន្តរជាតិ

ដើម្បីបញ្ជាក់ថា តក្កកម្មដែលបានដាក់ពាក្យសុំនោះ មានភាពថ្មី មានជំហាននៃការរកឃើញ អាចអនុវត្តន៍ក្នុងវិស័យឧស្សាហកម្ម និងសិប្បកម្ម ដូច្នេះទាមទារឱ្យការស្រាវជ្រាវ និងពិនិត្យមើលរបាយការណ៍អន្តរជាតិ។

---

[55] សន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម មាត្រា៨ (២ខ) ។

### ៣.១.៣.១. ការស្រាវជ្រាវអន្តរជាតិ

គោលបំណងនៃការស្រាវជ្រាវអន្តរជាតិ គឺដើម្បីស្វែងរកស្នាដៃមុន ដែលធ្លាប់បានចុះបញ្ជីពីមុនមកទេ ដើម្បីធានាថាតក្កកម្មកំពុងស្នើសុំឱ្យមានការការពារគឺថ្មីមានជំហាននៃការរកឃើញថ្មី។ ដូច្នេះអាជ្ញាធរស្រាវជ្រាវអន្តរជាតិត្រូវខំប្រឹងប្រែងស្វែងរកស្នាដៃមុន ដែលពាក់ព័ន្ធឱ្យបានច្រើនតាមលទ្ធភាពខ្លួន ។[56]

ការស្រាវជ្រាវអន្តរជាតិ គឺផ្អែកលើឯកសារសំខាន់មួយដែលមានឈ្មោះថា "PCT minimum documentation" ដែលជាប្រភេទឯកសារចងក្រងការបោះពុម្ពផ្សាយអំពីតក្កកម្មដែលចេញដោយប្រទេសចិន ចាប់ពីឆ្នាំ១៩២០ ប្រទេសបារាំង ប្រទេសអាឡឺម៉ង់ ចាប់ពីឆ្នាំ១៩៤៥ ប្រទេសជប៉ុន ប្រទេសកូរ៉េខាងត្បូង ប្រទេសរុស្ស៊ី ប្រទេសស្វីស ចក្រភពអង់គ្លេស សហរដ្ឋអាមេរិក អង្គការកម្មសិទ្ធិ បញ្ញាទ្វីបអាហ្រ្វិក អង្គការកម្មសិទ្ធិឧស្សាហកម្មតំបន់អាហ្រ្វិក និងការិយាល័យចុះបញ្ជីតក្កកម្មអឺរ៉ុប អាស៊ី និងអឺរ៉ុប។ "PCT minimum documentation" ក៏មានចងក្រងនូវសៀវភៅផ្សព្វផ្សាយអំពី ពាក្យសុំចុះបញ្ជីតក្កកម្ម ដែលចេញដោយការិយាល័យអន្តរជាតិ និងដោយប្រទេសដទៃទៀតចាប់ពី ឆ្នាំ១៩២០ មកផងដែរ ។

- <u>**កម្មវត្ថុមិនសត្ថិក្នុងការស្រាវជ្រាវ**</u>

អាជ្ញាធរស្រាវជ្រាវអន្តរជាតិ នឹងមិនស្រាវជ្រាវនោះទេករណីតក្កកម្ម ដែលបានស្នើសុំនោះសត្ថិក្នុងប្រភេទទាំង ៦ ដូចខាងក្រោម៖

- ទ្រឹស្តីវិទ្យាសាស្ត្រគណិតវិទ្យា
- រុក្ខជាតិ ឬសត្វដែលមិនមែនជាមីក្រូសរីរាង្គ និងដំណើរការកកើតតាមលក្ខណៈជីវសាស្ត្រសំខាន់ៗ សម្រាប់លផលិតកម្មរុក្ខជាតិ ឬសត្វ
- គម្រោងការ ក្បួន ឬវិធីសាស្ត្រសម្រាប់ធ្វើជំនួញ សម្រាប់ធ្វើសកម្មភាពហ្វឹកហ្វឺនខាងប្រាជ្ញាសុទ្ធសាធ ឬសម្រាប់លេងល្បែងកំសាន្ត
- វិធីសាស្ត្រសម្រាប់ព្យាបាលរាងកាយ មនុស្ស ឬសត្វ ដោយវះកាត់ ឬដោយការព្យាបាល ក៏ដូចជាវិធីសាស្ត្រវិនិច្ឆ័យរោគ ដែលបានអនុវត្តលើរាងកាយមនុស្ស សត្វ
- បទបង្ហាញនៃព័ត៌មានដ៏កម្រ និង
- កម្មវិធីកុំព្យូទ័រ

[56] សិទ្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម មាត្រា ១៥ ។

- **ការរួមបញ្ចូលនៃតក្កកម្ម**

អាជ្ញាធរស្រាវជ្រាវអន្តរជាតិ នឹងពិនិត្យលើសំណុំលិខិតស្នើសុំអន្តរជាតិ ថាតើបានបំពេញតាមលក្ខខណ្ឌនៃការរួមបញ្ចូលនៃតក្កកម្ម (Unity of Invention)។ ការរួមបញ្ចូលគ្នានៃតក្កកម្ម គឺសំដៅថាតើ សំណុំលិខិតស្នើសុំអន្តរជាតិនោះមានតក្កកម្ម ឬ ក្រុមនៃតក្កកម្មដែលមានបច្ចេកទេសប្រហាក់ប្រហែលគ្នាដើម្បីបង្ហាញមានជំហានបង្កើតថ្មី ។ ករណីដែលអាជ្ញាធរស្រាវជ្រាវអន្តរជាតិរកឃើញថាខ្វះការរួមបញ្ចូលនៃតក្កកម្ម អាជ្ញាធរស្រាវជ្រាវអន្តរជាតិ ត្រូវអញ្ជើញអ្នកដាក់ពាក្យសុំឱ្យបង់ប្រាក់កម្រៃបន្ថែមចំពោះ ការស្រាវជ្រាវបន្ថែម តក្កកម្មនោះក្នុងរយៈ ០១ខែ គិតចាប់ពីកាលបរិច្ឆេទនៃការចេញអញ្ជើញ ។ របាយការណ៍ស្រាវជ្រាវអន្តរជាតិ នឹងមិនត្រូវបានរៀបចំ បុគ្គលណាការបង់ប្រាក់កម្រៃស្រាវជ្រាវ និងកម្រៃស្រាវជ្រាវបន្ថែមមិនត្រូវបានបង់ចប់សព្វគ្រប់។[57]

### ៣.២.៣.២. របាយការណ៍ស្រាវជ្រាវអន្តរជាតិ

អាជ្ញាធរស្រាវជ្រាវអន្តរជាតិនឹងចេញរបាយការណ៍ស្រាវជ្រាវអន្តរជាតិ ក្នុងរយៈពេល ០៣ខែ គិតចាប់ពីកាលបរិច្ឆេទបានទទួលបានច្បាប់ចម្លងសម្រាប់ស្រាវជ្រាវពីការិយាល័យទទួល ឬនៅក្នុងរយៈពេល ០៩ខែ គិតចាប់ពីកាលបរិច្ឆេទទាមទារអាទិភាព ។ របាយការណ៍នេះ នឹងបង្ហាញអំពីឯកសារគាំទ្រតក្កកម្មពាក់ព័ន្ធ ចំណាត់ថ្នាក់ តក្កកម្មស្របតាមចំណាត់ថ្នាក់តក្កម្មអន្តរជាតិ (International Patent Classification) និង ការបញ្ជាក់អំពីប្រភេទនៃការស្រាវជ្រាវ (Field of Search) និងប្រព័ន្ធទិន្នន័យដែលអាចស្រាវជ្រាវ (Electronic Data) ។ គួរបញ្ជាក់ថា នៅក្នុងរបាយការណ៍ស្រាវជ្រាវអន្តរជាតិមិនបង្ហាញទស្សនៈហេតុផល ឬការពន្យល់ណាមួយទៅលើលទ្ធផលនៃការស្រាវជ្រាវនោះទេ។[58]

- **ការផ្ដល់យោបល់ជាលាយលក្ខណ៍អក្សរ**

នៅក្នុងរបាយការណ៍ស្រាវជ្រាវអន្តរជាតិនោះ អាជ្ញាធរស្រាវជ្រាវអន្តរជាតិនឹងផ្ដល់យោបល់ជាលាយលក្ខណ៍អក្សរជាបឋម ក៏ប៉ុន្តែមិនចងកាតព្វកិច្ច ដោយវាយតម្លៃលើលក្ខខណ្ឌចំនួន ៣ គឺ៖

- អំពីភាពថ្មី
- អំពីជំហាននៃការរកឃើញថ្មី
- អាចយកទៅអនុវត្តបានក្នុងវិស័យឧស្សាហកម្ម ឬសិប្បកម្មនៃតក្កកម្មនោះ។

[57] សិទ្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម មាត្រា ១៧ និង ស្ដីពី វិធានក្រោមសិទ្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម ប្រការ ១៣ និង ប្រការ ៤០ ។

[58] សិទ្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម មាត្រា ១៨ និង ស្ដីពី វិធានក្រោមសិទ្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម ប្រការ ៤២ និង ប្រការ ៤៣ ។

ការផ្តល់យោបល់ជាលាយលក្ខណ៍អក្សរនេះត្រូវសរសេរភាសាដូច នឹងភាសារបស់របាយការណ៍ស្រាវជ្រាវអន្តរជាតិ ហើយត្រូវផ្ញើរទៅអ្នកដាក់ពាក្យសុំ និងការិយាល័យទទួល ព្រមជាមួយនឹងរបាយការណ៍ស្រាវជ្រាវអន្តរជាតិទាំងរបាយការណ៍ស្រាវជ្រាវអន្តរជាតិ និងការផ្តល់យោបល់ជាលាយលក្ខណ៍អក្សរ ត្រូវធ្វើក្នុងរយៈពេល ៣ខែ គិតចាប់ពីកាលបរិច្ឆេទទទួលច្បាប់ចម្លងសម្រាប់ស្រាវជ្រាវ ឬក្នុងរយៈ៩ខែ គិតចាប់ពីកាលបរិច្ឆេទទាមអាទិភាព។

❖ **ការកែសម្រួលការអះអាងនៅចំពោះមុខការិយាល័យអន្តរជាតិ**

ពាក្យសុំអាចកែសម្រួលការអះអាងរបស់ខ្លួនបាន ផ្អែកតាមនីតិវិធីនៃសន្ធិសញ្ញា PCT។ ក៏ប៉ុន្តែករណីដែលអ្នកដាក់ពាក្យសុំបានដាក់ការទាមទារការពិនិត្យជំហានដំបូងអន្តរជាតិអ្នកដាក់ពាក្យសុំមានឱកាសកែសម្រួលការអះអាងរបស់ខ្លួនម្តងទៀតបាន ។ ជាមួយគ្នានោះ អ្នកដាក់ពាក្យសុំអាចដាក់សេចក្តីថ្លែងបញ្ជាក់សង្ខេប ដែលមាននៅក្នុងលើសេចក្តីអត្ថាធិប្បាយនិង គំនូសបង្ហាញ ។ ការកែសម្រួលនោះ មិនត្រូវឱ្យហួសពីការបញ្ចេញឱ្យដឹងក្នុងសំណុំលិខិតស្នើសុំអន្តរជាតិដែលបានដាក់ពីដំបូងនោះទេ។ ផ្អែកតាមមាត្រា ១៩នៃសន្ធិសញ្ញា PCT រយៈពេលនៃការកែសម្រួលជាធម្មតាមិនលើសពី ០២ខែគិតចាប់ពីកាលបរិច្ឆេទនៃបញ្ជូនរបាយការណ៍ និងផ្តល់យោបល់ជាលាយលក្ខណ៍ពីអាជ្ញាធរស្រាវជ្រាវអន្តរជាតិនោះទេ ឬក្នុងរយៈពេល ១៦ខែគិតចាប់ពីកាលបរិច្ឆេទនៃការទាមទារអាទិភាព។ ករណីចង់មានការកែសម្រួលនេះត្រូវដាក់ដោយផ្ទាល់នៅការិយាល័យអន្តរជាតិមិនមែននៅអាជ្ញាធរស្រាវជ្រាវអន្តរជាតិនោះទេ ។

❖ **ទំនាក់ទំនងរវាងការផ្តល់យោបល់ជាលាយលក្ខណ៍អក្សរនិងរបាយការណ៍ពិនិត្យជំហានដំបូងអន្តរជាតិ**

ករណីអ្នកដាក់ពាក្យសុំមិនដាក់ការទាមទារការពិនិត្យជំហានដំបូងអន្តរជាតិ នោះការផ្តល់យោបល់ជាលាយលក្ខណ៍អក្សររបស់អាជ្ញាធរស្រាវជ្រាវអន្តរជាតិ នឹងប្រែក្លាយជារបាយការណ៍ជំហានដំបូងអន្តរជាតិ ស្តីអំពីភាពទទួលបានប្រកាសនីយបត្រ ដែលនឹងចេញដោយការិយាល័យអន្តរជាតិ ហើយនឹងត្រូវផ្ញើរទៅគ្រប់ការិយាល័យជ្រើសរើសតាំង។ របាយការណ៍ការត្រួតពិនិត្យជំហានដំបូងអន្តរជាតិស្តីអំពី ភាពទទួលបានប្រកាសនីយ បត្រតក្កកម្ម នឹងផ្សព្វផ្សាយនៅប្រពន្ធ័ PATENTSCOPE ដល់សារធារណៈជន ។

### ៣.១.៤. ការពិនិត្យជំហានដំបូងអន្តរជាតិ និងរបាយការណ៍ពិនិត្យ ជំហានដំបូងអន្តរជាតិ

ក្នុងដំណាក់កាលនីតិវិធីចុះបញ្ជី ប្រសិនបើតក្កករមានការមិនពេញចិត្តចំពោះការផ្តល់យោបល់ ឬកែសម្រួលទៅលើតក្កកម្មនោះតក្កករអាចស្នើសុំទៅអាជ្ញាធរ ស្រាវជ្រាវឡើងវិញ ដើម្បីត្រួតពិនិត្យលើជំហានដំបូង និងរបាយការណ៍អន្តរជាតិដែលបាន ដាក់រួចហើយ។

### ៣.១.៤.១. ការពិនិត្យជំហានដំបូងអន្តរជាតិ

ក្នុងករណីដែលអ្នកដាក់ពាក្យសុំមិនពេញចិត្ត នឹងការផ្តល់យោបល់ជាលាយលក្ខណ៍អក្សរដែលចេញដោយអាជ្ញាធរស្រាវជ្រាវអន្តរជាតិ អ្នកដាក់ពាក្យសុំអាចបន្តពិនិត្យលក្ខណវិនិច្ឆ័យនៃតក្កកម្មរបស់ខ្លួនក្រោមនីតិវិធីការពិនិត្យជំហានដំបូងអន្តរជាតិ ។ ការពិនិត្យជំហានដំបូងអន្តរជាតិ គឺជានីតិវិធីដែលអ្នកដាក់ពាក្យសុំអាចជ្រើសរើស និងដាក់ពាក្យទាមទារដាច់ដោយឡែកពីសំណុំលិខិតស្នើសុំអន្តរជាតិទៅ អាជ្ញាធរត្រួតពិនិត្យជំហានដំបូងអន្តរជាតិហៅកាត់ថា International Preliminary Examining Authority (IPEA)ដោយផ្ទាល់។ ការិយាល័យទទួលត្រូវតែជ្រើសតាំងអាជ្ញាធរត្រួតពិនិត្យជំហាន ដំបូងអន្តរជាតិ ដែលអាចជា International Preliminary Examining Authority (IPEA)ដោយផ្ទាល់ ។ ការិយាល័យទទួលត្រូវតែជ្រើសតាំងអាជ្ញាធរត្រួតពិនិត្យជំហានដំបូងអន្តរជាតិ ដែលអាចជាការិយាល័យជាតិនៃប្រទេសហត្ថលេខី ឬការិយាល័យថ្នាក់តំបន់ដែលមានសមត្ថភាពក្នុងការអនុវត្តន៍ការពិនិត្យជំហានដំបូងអន្តរជាតិជាមុនសិន ។ ករណីដែលការិយាល័យទទួលមានអាជ្ញាធរត្រួតពិនិត្យជំហានដំបូងអន្តរជាតិច្រើនជាងមួយអ្នកដាក់ពាក្យសុំអាចជ្រើសតាំងអាជ្ញាធរមួយក្នុងចំណោមអាជ្ញាធរទាំងនោះ ។ សូមបញ្ជាក់ថា រាល់ការទាមទារការពិនិត្យជំហានដំបូងអន្តរជាតិដែលបានដាក់នៅ ឬក្រោមថ្ងៃទី០១ ខែមករា ឆ្នាំ២០០៤ គ្រប់ការិយាល័យជាតិនៃការប្រទេសហត្ថលេខី គឺអាចជាការិយាល័យជ្រើសជ្រើសតាំងឱ្យអាជ្ញាធរពិនិត្យជំហានដំបូងអន្តរជាតិបាន។[59]

កម្មវត្ថុនៃការពិនិត្យជំហានដំបូងអន្តរជាតិគឺ ចងក្រងយោបល់ជាជំហានដំបូង និងឱ្យយោបល់លើលក្ខណៈវិនិច្ឆ័យ ថាតើតក្កកម្មដែលស្នើសុំនោះមានភាពថ្មី មានជំហានរកឃើញថ្មី និងអាចយកមកអនុវត្តក្នុងឧស្សាកម្មដែរ ឬទេ ដើម្បីពិនិត្យឱ្យដឹងថា តក្កម្មនោះដែលបានអះអាងអាចទទួលបានប្រកាសនីយបត្រតក្កកម្មបានដែរ ឬទេ ។ អ្នកដាក់ពាក្យសុំអាចពិចារណាជ្រើសរើសនីតិវិធីពិនិត្យជំហានដំបូងជាអន្តរជាតិ ព្រោះនីតិវិធីនេះ នឹងនាំឱ្យអ្នកដាក់ពាក្យស្នើសុំដឹងជាមុន ដើម្បីធ្វើការសម្រួលសេចក្តីអត្ថាធិប្បាយ ការអះអាង និងគំនូសបង្ហាញនៃសំណុំឯកសារស្នើសុំរបស់ខ្លួនជៀសវាងការទំនាស់ក្នុងការចុះបញ្ជីនៅការិយាល័យជាតិ ឬនាំឱ្យខូចខាតពេលវេលានៅក្នុងដំណាក់ការជាតិ ។

- **ការទាមទារ**

ការទាមទារ គឺជាពាក្យបច្ចេទេសនៅក្នុងសន្ធិសញ្ញា PCT ដើម្បីសំដៅការស្នើសុំការពិនិត្យជំហានដំបូងអន្តជាតិ ។ ការទាមទារការពនិត្យជំហានដំបូងអន្តរជាតិ ត្រូវដាក់ទៅអាជ្ញាធរត្រួតពិនិត្យជំហានដំបូងអន្តរជាតិ

[59] សិន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម មាត្រា ៣១(៤) និងស្តីពី វិធានក្រោមសិន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម ប្រការ ៥៣.៧ និង ប្រការ ៥០.៨ ។

ដែលមានសមត្ថភាពក្នុងរយៈពេល ០៣ខែ គិតចាប់ពីថ្ងៃបញ្ជូនរបាយការណ៍ស្រាវជ្រាវអន្តរជាតិ និងផ្តល់យោបល់ជាលាយលក្ខណ៍អក្សរទៅអ្នកដាក់ពាក្យសុំ ឬក្នុងរយៈពេល ២២ខែ គិតចាប់ពីកាលបរិច្ឆេទទាមទារអាទិភាព ។[60] ពោលគឺការទាមទារការពិនិត្យជំហានដំបូងអន្តរជាតិមិនទាន់អាចចាប់ផ្តើមបានឡើយ រហូតដល់អាជ្ញាធរស្រាវជ្រាវអន្តរជាតិបានចាប់ផ្តើមនីតិវិធីសរសេររបាយការណ៍ស្រាវជ្រាវអន្តរជាតិ និងការផ្តល់យោបល់ជាលាយលក្ខណ៍អក្សររបស់ខ្លួន ។ អ្នកដាក់ពាក្យសុំត្រូវរងចាំឯកសារទាំងពីរខាងលើសិន មុននឹងសម្រេចដាក់ពាក្យ ទាមទារការពិនិត្យជំហានដំបូងអន្តរជាតិបាន។

ដើម្បីអាចដាក់ការទាមទារការពិនិត្យជំហានដំបូងអន្តរជាតិបានលុះត្រាតែគោរព តាមលក្ខខណ្ឌចំនួន ០២ ដូចខាងក្រោម៖

- លក្ខខណ្ឌទី ១ អ្នកដាក់ពាក្យសុំត្រូវមានអាស័យដ្ឋាន ឬសញ្ជាតិនៃប្រទេសសមាជិកដែលព្រមទទួលការអនុវត្តន៍ក្នុងជំពូក២ នៃសន្ធិសញ្ញា PCT
- លក្ខខណ្ឌទី ២ សំណុំលិខិតស្នើសុំអន្តរជាតិត្រូវតែដាក់នៅការិយាល័យទទួលនៃប្រទេសសមាជិកដែលព្រមទទួលការអនុវត្តន៍ក្នុងជំពូកទី២ នៃសន្ធិសញ្ញា PCT។[61]

- **ការកែសម្រួលសេចក្តីអត្ថាធិប្បាយអំពីតក្កកម្ម សេចក្តីអះអាង និងគំនូសបង្ហាញ**

មុននឹងចេញរបាយការណ៍ពិនិត្យជំហានដំបូងអន្តរជាតិ អ្នកដាក់ពាក្យសុំមានឱកាសក្នុងការកែសម្រួលសំណុំលិខិតស្នើសុំជាអន្តរជាតិបាន នៅក្នុងលក្ខខណ្ឌតម្រូវ និងមានពេលវេលាកំណត់ (សំដៅដល់ការកែសម្រួលសេច ក្តីអត្ថាធិប្បាយអំពីតក្កកម្ម សេចក្តីអះអាង និងគំនូសបង្ហាញបាន) តែការកែសម្រួលនោះមិនត្រូវប្រាប់ពីការបង្ហាញឱ្យដឹង នៅក្នុងសំណុំលិខិតស្នើសុំអន្តរជាតិដែលបានដាក់នោះឡើយ។[62]

- ការផ្តល់យោបល់ជាលាយលក្ខណ៍អក្សរ

អាជ្ញាធរពិនិត្យជំហានដំបូងអន្តរជាតិ នឹងផ្តល់យោបល់ជាលាយលក្ខណ៍អក្សរទៅដល់អ្នកដាក់ពាក្យសុំដោយបញ្ជាក់អំពីមូលហេតុបានច្បាស់លាស់។

ការទាមទារពិនិត្យជំហានដំបូងអន្តរជាតិដែលបានដាក់នៅថ្ងៃ ឬក្រោយថ្ងៃទី០១ កក្កដា ឆ្នាំ២០០៤ អាជ្ញាធរ

---

[60] សន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម មាត្រា ៣៩(១) និង ស្តីពី វិធានក្រោមសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម ប្រការ ៥៤ ១(ក)(៣)និង ប្រការ ៦៩.២ ។

[61] សន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម មាត្រា ៣១(២)(ក) និង ស្តីពី វិធានក្រោមសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម ប្រការ ១៨.១និង ប្រការ ៥៤ ។

[62] សន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម មាត្រា ៣៤ ។

ពិនិត្យជំហានដំបូងអន្តរជាតិ នឹងប្រើយន្តការស្វែងរកដែលមានឈ្មោះថា top up យន្តការស្វែងរកនេះមានសមត្ថភាពបញ្ជាក់អំពីឯកសារពាក់ព័ន្ធបន្ថែមអំពីឯកសារតក្កកម្មពីមុនឱ្យអ្នកដាក់ពាក្យសុំដឹង និងមានឱកាសកែសម្រួលពាក្យសុំរបស់ខ្លួន ដើម្បីធានាកុំឱ្យមានការបដិសេធថា តក្កកម្មកំពុងស្នើសុំនេះមិនមានភាពថ្មី ឬមិនមានជំហាននៃការរកឃើញមុនចាប់ផ្តើមនីតិវិធីកម្រិតថ្នាក់ជាតិ។[63]

ការចេញយោបល់ជាលាយលក្ខណ៍អក្សរអាចចេញជាលើកទី២ដែលផ្តល់ឱកាសឱ្យអ្នកដាក់ពាក្យសុំអាចកែសម្រួលសំណុំលិខិតស្នើសុំរបស់ខ្លួនបានម្តងទៀត។ ចំនួននៃផ្តល់ឱកាសឱ្យកែសម្រួលសំណុំលិខិតស្នើសុំ គឺអាស្រ័យទៅលើពេលវេលានៃការពិនិត្យជំហានដំបូង។ របាយការណ៍ស្តីការពិនិត្យជំហានដំបូងអន្តរជាតិ ត្រូវផ្តល់ឱ្យអ្នកដាក់ពាក្យសុំក្នុងអំឡុងពេល ២៨ខែគិតចាប់ពីកាលបរិច្ឆេទទាមទារអាទិភាព ។ រាល់ការកែសម្រួលណាដែលធ្វើក្រោយការប្រគល់របាយការណ៍ នឹងមិនត្រូវយកមកពិចារណានោះទេ ។

- **ការឆ្លើយតបនឹងការផ្តល់យោបល់ជាលាយលក្ខណ៍អក្សរជាទូទៅ**

អ្នកដាក់ពាក្យសុំនឹងទទួលបានការផ្តល់យោបល់ និងការអនុញ្ញាតឱ្យឆ្លើយតបទៅអាជ្ញាធរពិនិត្យជំហានដំបូង នៅមុនពេលប្រគល់របាយការណ៍ស្តីអំពីការពិនិត្យជំហានដំបូងអន្តរជាតិ ។ នៅក្នុងករណីនេះអ្នកដាក់ពាក្យសុំអាចឱ្យកែសម្រួល និងផ្តល់អំណះអំណាងរបស់ខ្លួនបាន។

អ្នកពាក្យសុំមានសិទ្ធិទាក់ទងផ្ទាល់មាត់ និងជាលាយលក្ខណ៍អក្សរជាមួយអាជ្ញាធរពិនិត្យជំហានដំបូងអន្តរជាតិបានដែលមានទំនាក់ទំនងក្រៅផ្លូវការ និងមិនចងកាតព្វកិច្ចលើកលែងតែការតវ៉ាដែលពាក់ព័ន្ធនឹងការរួមបញ្ចូលគ្នាតែមួយនៃតក្កកម្ម។[64]

### ៣.១.៤.២. របាយការណ៍ពិនិត្យ ជំហានដំបូងអន្តរជាតិ

នីតិវិធីពិនិត្យជំហានដំបូងអន្តរជាតិ នឹងបញ្ចប់នៅពេលរបាយការណ៍ពិនិត្យជំហានដំបូងអន្តរជាតិបានរៀបចំរួចរាល់ ដែលត្រូវធ្វើក្នុងរយៈពេល ២៨ខែគិតចាប់ពីកាលបរិច្ឆេទទាមទារអាទិភាព ឬរយៈពេល ០៦ខែគិតចាប់ពីកាលបរិច្ឆេទទទួលបានការទាមទារដោយអាជ្ញាធរពិនិត្យជំហានដំបូងអន្តរជាតិ ។ របាយការណ៍ស្តីពីការពិនិត្យជំហានដំបូងអន្តរជាតិមិនចងកាតព្វកិច្ចនោះទេ តែរបាយការណ៍នេះនឹងផ្តល់យោបល់ដោយពិចារណាលើលក្ខខណ្ឌវិនិច្ឆ័យដែលត្រូវបំពេញថា តើតក្កកម្មនោះមានភាពថ្មី មានជំហាននៃការរកឃើញថ្មី និងអាចយកទៅអនុវត្តក្នុងវិស័យឧស្សាហកម្មបានបានឬទេ។ ជាទូទៅរបាយការណ៍ការពិនិត្យជំហានដំបូងអន្តរជាតិ ត្រូវរៀបចំចប់សព្វគ្រប់ និងបញ្ជូនមកអ្នកដាក់ពាក្យសុំ ០២ខែ មិនចាប់ផ្តើមអនុវត្តនីតិវិធីថ្នាក់ជាតិ ដូច្នេះក្នុងរយៈពេលនេះ

[63] ស្តីពី វិធានក្រោម សិទ្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម ប្រការ ៦៦ ។

[64] ស្តីពី វិធានក្រោម សិទ្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម ប្រការ ៦៦ ។

អ្នកដាក់ពាក្យសុំអាច នឹងពិចារណាថាគួរបន្តនីតិវិធីថ្នាក់ជាតិ ឬយ៉ាងណា។[65]

បន្ទាប់ពីរៀបចំរួច អាជ្ញាធរពិនិត្យជំហានដំបូងអន្តរជាតិត្រូវបញ្ជូនរបាយការណ៍នេះទៅអ្នកដាក់ពាក្យសុំ និងទៅការិយាល័យអន្តរជាតិ ដែលរបាយការណ៍ត្រូវសរសេរដូចនឹងភាសានៃសំណុំលិខិតស្នើសុំអន្តរជាតិ និងភាសាដែលនឹងត្រូវបោះពុម្ពផ្សាយជាអន្តរជាតិ។ ការិយាល័យអន្តរជាតិ ត្រូវតែធ្វើការបកប្រែភាសានោះទៅជាភាសាអង់គ្លេស ក្នុងករណីភាសាប្រើប្រាស់ មិនមែនជាភាសាអង់គ្លេស។[66]

របាយការណ៍ការពិនិត្យជំហានដំបូងអន្តរជាតិនឹងមិនអនុញ្ញាតឱ្យនរណាម្នាក់ដឹង ក្រៅពីដាក់ពាក្យសុំ និងមន្ត្រីជ្រើសតាំងក្នុងដំណាក់កាលថ្នាក់អន្តរជាតិឡើយ ។ ការិយាល័យអន្តរជាតិ និងអាជ្ញាធរពិនិត្យជំហានដំបូងអន្តរជាតិមិនត្រូវផ្តល់ព័ត៌មានស្តីអំពីការចេញរបាយការណ៍ការពិនិត្យជំហានដំបូងអន្តរជាតិ ឬការដកការទាមទារ ឬ ការមិនដកការទាមទារទៅអ្នកផ្សេងដោយគ្មានការអនុញ្ញាត ឬការស្នើសុំពីអ្នកដាក់ពាក្យសុំ។

នៅពេលទទួលបានរបាយការណ៍ពិនិត្យជំហានដំបូងអន្តរជាតិ ហើយអ្នកដាក់ពាក្យសុំសម្រេចថាតើបន្តនីតិវិធីថ្នាក់ជាតិ ឬ កម្រិតតំបន់នៅចំពោះមុខមន្ត្រីដែលបានជ្រើសតាំងក្នុងរយៈពេល ៣០ខែ គិតចាប់ពីកាលបរិច្ឆេទទាមទារអាទិភាព។ របាយការណ៍នេះនឹងជាមូលដ្ឋានដ៏សំខាន់សម្រាប់ការិយាល័យជ្រើសតាំងក្នុងការពិចារណាចំពោះការផ្តល់ប្រកាសនីយបត្រតក្កកម្មថ្នាក់ជាតិ ដល់សំណុំលិខិតស្នើសុំអន្តរជាតិណាដែលក្រោយពីបានពិនិត្យ ឃើញថាបំពេញតាមលក្ខខណ្ឌវិនិច្ឆ័យសំខាន់ៗទាំង ៣ នៃតក្កកម្មត្រូវបានបំពេញ។

### ៣.១.៥. ការចុះផ្សាយអន្តរជាតិ

ការិយាល័យអន្តរជាតិនៃអង្គការកម្មសិទ្ធិបញ្ញាពិភពលោក គឺជាអង្គភាពដែលទទួលខុសត្រូវ ក្នុងការចុះផ្សាយជាអន្តរជាតិនូវរាល់ការចុះបញ្ជីប្រកាសនីយបត្រតក្កកម្មតាមសន្ធិសញ្ញា PCT ហើយការចុះផ្សាយជាអន្តរជាតិ

ការិយាល័យអន្តរជាតិនៃអង្គការកម្មសិទ្ធិបញ្ញាពិភពលោក គឺជាអង្គភាពដែលទទួលខុសត្រូវ ក្នុងការចុះផ្សាយជាអន្តរជាតិនូវរាល់ការចុះបញ្ជីប្រកាសនីយបត្រតក្កកម្មតាមសន្ធិសញ្ញា PCT ហើយការចុះផ្សាយជាអន្តរជាតិនេះ ត្រូវធ្វើភ្លាមៗបន្ទាប់ពីកាលបរិច្ឆេទផុតកំណត់រយៈពេល ១៨ខែ គិតចាប់ពីកាលបរិច្ឆេទទាមទារអាទិភាព។

- <u>**អានុភាពនៃការចុះផ្សាយអន្តរជាតិ**</u>

ការចុះផ្សាយជាអន្តរជាតិនឹងតម្រូវឱ្យមានការការពារនៅតាមបណ្តាលប្រទេសសមាជិក PCT ក្នុងករណីដែលសំណុំលិខិតស្នើសុំអន្តរជាតិនោះទទួលបាននូវការការពារ ។ ការការពារអាចនឹងមានអនុភាពនៅពេលៈ

---

[65] ស្តីពី វិធានក្រោមសិទ្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម ប្រការ ៦៩.២ ។

[66] ស្តីពី វិធានក្រោមសិទ្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម ប្រការ ៧០ ប្រការ ៧២ និង ប្រការ ៧៤ ។

- បានផ្តល់ការបកប្រែជាភាសាអង់គ្លេស ដោយការិយាល័យអន្តរជាតិ ករណីសំណុំលិខិតស្នើសុំអន្តរជាតិ មិនដាក់ជាភាសាអង់គ្លេស ។ ករណីដែលសំណុំលិខិតដាក់មកភាសា ដែលមិនទទួលស្គាល់ អ្នកដាក់ពាក្យសុំត្រូវមកជាភាសាដែលទទួលស្គាល់ផ្លូវការ។
- បានទទួលដោយការិយាល័យចុះបញ្ជីនៃប្រទេសជ្រើសរើសនូវច្បាប់ចតចម្លងនៃការបោះពុម្ពផ្សាយតក្កកម្មដែលចុះបញ្ជីតាមនីតិវិធីសន្ធិសញ្ញា PCT និង
- បានបោះពុម្ពផ្សាយបន្ទាប់ពីការផុតកំណត់នៃរយៈពេល ១៨ខែគិតចាប់ពីកាលបរិច្ឆេទទាមទារអាទិភាព។

រាល់ការចុះផ្សាយសំណុំឯកសារស្នើចុះបញ្ជីតាមសន្ធិសញ្ញា PCT នឹងត្រូវចុះផ្សាយក្នុងប្រព័ន្ធ PATENTSCOPE ដើម្បីឱ្យតតិយជនអាចពិនិត្យ។

- <u>ភាសានៃការចុះផ្សាយអន្តរជាតិ</u>

ករណីដែលសំណុំលិខិតស្នើសុំអន្តរជាតិដាក់ជាភាសាអារ៉ាប់ ចិន អង់គ្លេស បារាំង ជប៉ុន អាឡឺម៉ង់ កូរ៉េ ព័រទុយហ្គាល់ រុស្សី ឬ អេស្បាញ នោះការចុះផ្សាយអន្តរជាតិ ក៏ជាភាសាដូចនឹងសំណុំលិខិតស្នើសុំអន្តរជាតិដែរ ក៏ប៉ុន្តែផ្នែកខ្លះនៃសំណុំលិខិតស្នើសុំអន្តរជាតិនោះដូចជា ចំណងជើងតក្កកម្ម សេចក្តីសង្ខេប និង របាយការណ៍ស្រាវជ្រាវអន្តរជាតិ ត្រូវបកប្រែជាភាសាអង់គ្លេសដោយការិយាល័យអន្តរជាតិ។

### ៣.១.៦. ការត្រួតពិនិត្យថ្នាក់ជាតិ

បន្ទាប់ពីបញ្ចប់ដំណាក់ការនីតិវិធីថ្នាក់អន្តរជាតិ នីតិវិធីនេះនឹងត្រូវបន្តពិនិត្យនៅកម្រិតជាតិដែលជាដំណាក់កាលបញ្ចប់នៃនីតិវិធីចុះបញ្ជីប្រកាសនីយបត្រតក្កកម្មតាម PCT។ ទោះបីយ៉ាងណា ការពិនិត្យថ្នាក់ជាតិនឹងចាប់ផ្តើមហើយអ្នកដាក់ពាក្យសុំត្រូវអនុវត្តសកម្មភាព មួយចំនួនដែលបានកំណត់ឱ្យបានមុនការផុតកំណត់នៃកាលបរិច្ឆេទ ។ គួរបញ្ជាក់ផងដែរថា អ្នកដាក់ពាក្យសុំត្រូវមានទំនួលខុសត្រូវខ្លួនឯងក្នុងការចាប់ផ្តើម ការពិនិត្យថ្នាក់ជាតិឱ្យបានទាន់ពេលកំណត់របស់ច្បាប់។ រយៈពេលដើម្បីទទួលការពិនិត្យកម្រិតជាតិត្រូវចាប់ផ្តើមពិនិត្យសំណុំលិខិតស្នើសុំអន្តរជាតិមិនឱ្យយឺតជាងការផុតកំណត់នៃរយៈពេល០៣ខែ ចាប់ពីកាលបរិច្ឆេទអាទិភាព។[67]

- <u>សំណុំឯកសារចាំបាច់</u>

មុនការចាប់ផ្តើមនីតិវិធីត្រួតពិនិត្យបន្តនៅថ្នាក់ជាតិ អ្នកដាក់ពាក្យសុំត្រូវផ្តល់ច្បាប់ចម្លងនៃសំណុំលិខិតស្នើសុំអន្តរជាតិ ព្រមជាមួយរបាយការណ៍ស្រាវជ្រាវអន្តរជាតិ ការបកប្រែសំណុំលិខិតស្នើសុំអន្តរជាតិ និងបង់កម្រៃថ្នាក់ជាតិជូនដល់ការិយាល័យជ្រើសរើសនីមួយៗដោយមិនឱ្យយឺតជាងការផុតកំណត់នៃរយៈពេល ៣០ខែ

[67] សិន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម មាត្រា ២២ ។

ចាប់ពីកាលបរិច្ឆេទអាទិភាព។[68] ទន្ទឹមនិងនេះការិយាល័យជ្រើសរើសនឹងតម្រូវឱ្យមានអ្នកតំណាងដែលមានសញ្ជាតិមិនដូចនឹងអ្នកដាក់ពាក្យសុំនិងមានការិយាល័យបម្រើការងារនៅប្រទេសជ្រើសរើស។[69]

❖ <u>ការត្រួតពិនិត្យ</u>

ក្នុងដំណាក់កាលនីតិវិធីអន្តរជាតិ ជាទូទៅសំណុំលិខិតស្នើសុំអន្តរជាតិ ត្រូវបានស្រាវជ្រាវ និងត្រួតពិនិត្យដោយអាជ្ញាធរស្រាវជ្រាវ និងអាជ្ញាធរត្រួតពិនិត្យជំហានដំបូងអន្តរជាតិ ដែលអនុញ្ញាតឱ្យអ្នកដាក់ពាក្យសុំអាចកែសម្រួលពាក្យសុំរបស់ខ្លួនបាន។ របាយការណ៍ទាំងនោះនឹងបង្កភាពងាយស្រួលដល់អ្នកដាក់ពាក្យសុំបានដឹងជាមុនអំពីភាពដែលទទួលបានប្រកាសនីយបត្រតក្កកម្មជាតិ។

ទោះបីជាយ៉ាងណា របាយការណ៍ដែលចេញដោយអាជ្ញាធរស្រាវជ្រាវអន្តរជាតិ ឬអាជ្ញាធរត្រួតពិនិត្យជំហានដំបូងអន្តរជាតិមិនចងកាតព្វកិច្ចដល់ការិយាល័យចុះបញ្ជីជាតិនោះទេពោលរបាយការណ៍ទាំងនោះគ្រាន់ផ្តល់យោបល់ ថាតើសំណុំលិខិតស្នើសុំអន្តរជាតិនោះ បានបំពេញតាមលក្ខខណ្ឌ ភាពថ្មីមានជំហាននៃការរកឃើញថ្មី និងអាចអនុវត្តក្នុងវិស័យឧស្សាហកម្មបានដែរ ឬទេ។

❖ <u>ការកែសម្រួលនៅដំណាក់កាលនីតិវិធីកម្រិតជាតិ</u>

នៅក្នុងដំណាក់កាលនីតិវិធីថ្នាក់ជាតិ អ្នកដាក់ពាក្យសុំអាចធ្វើការកែសម្រួលបន្ថែមនៅចំពោះមុខការិយាល័យចុះបញ្ជីជាតិបាន លើសេចក្តីអះអាង សេចក្តីអត្ថាធិប្បាយ និងគំនូសបង្ហាញ ហើយការកែសម្រួលនេះ គឺជាការបំពេញបន្ថែមទៅលើការអនុវត្តន៍ដំណាក់កាលនីតិវិធីថ្នាក់អន្តរជាតិ កន្លងមក និងឱ្យសមស្របទៅតាមច្បាប់ជាតិរដ្ឋជ្រើសរើសនីមួយៗ ។ ទោះបីជាយ៉ាងណាការកែសម្រួលនៅដំណាក់កាលនេះមិនត្រូវឱ្យខុសឆ្ងាយពីការបញ្ចេញឱ្យដឹងអំពីតក្កកម្មនៃសំណុំលិខិតស្នើសុំអន្តរជាតិដើមឡើយ។[70]

## ៣.២. ភាពដូច និង ភាពខុសគ្នារវាងប្រកាសនីយបត្រតក្កកម្មជាតិ និង អន្តរជាតិ

ប្រកាសនីយបត្រតក្កកម្មជាតិ និង អន្តរជាតិតាមសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មមានភាពដូចគ្នារវាង **លក្ខខណ្ឌ** នៃការទទួលបានកាការពារពីប្រកាសនីយបត្រតក្កកម្មគឺត្រូវតែ ថ្មី ជំហានការរកឃើញថ្មី និង អាចអនុវត្តបានក្នុងវិស័យឧស្សាហកម្ម និងសិប្បកម្មបានដូចគ្នា ។ រីឯ**នីតិវិធីដាក់ពាក្យស្នើសុំ** ពោលគឺប្រកាសនីយបត្រតក្កកម្មទាំងពីរនេះតម្រូវឱ្យមាន ព្រោះការដាក់ពាក្យស្នើសុំដើម្បីទទួលបានការការពារចំពោះបែបបទនៃការដាក់ពាក្យស្នើសុំប្រកាសនីយបត្រតក្កកម្មទាំងពីរ ត្រូវតែបំពេញបែបបទ ដូចជា ពាក្យសុំ សេចក្តី-

68 សន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម មាត្រា ២២។

69 សន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម មាត្រា ២៧(៧)។

70 សន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម មាត្រា ២៤។

អត្ថាធិប្បាយ សេចក្តីអះអាង និង ខ្លឹមសារសង្ខេប ដូចគ្នាហើយ ។ ម្យ៉ាងទៀត **អានុភាពនៃការការពារ និង សិទ្ធិទទួលបាន** ប្រកាសនីយបត្រតក្កកម្មជាតិ និង អន្តរជាតិ ទទួលបានដូចគ្នា ហើយទទួលបាន **រយៈពេលនៃការពារ ២០ឆ្នាំ** ។ ចំពោះការទាញយក**ផលប្រយោជន៍** ផ្នែកសេដ្ឋកិច្ច ទីផ្សារ ពីតក្កកម្មទទួលបានការការពារបានដូចគ្នា ដោយម្ចាស់ស្នាដៃគាត់អាចប្រើប្រាស់សិទ្ធិដោយស្របច្បាប់របស់ពួកគាត់បាន។

ចំពោះភាពខុសគ្នារវាង ប្រកាសនីយបត្រតក្កកម្មជាតិ និង អន្តរជាតិ ចំពោះ ការដាក់ពាក្យស្នើសុំមិនមានអ្វីខុសគ្នាច្រើនទេ គ្រាន់តែទីកន្លែងទទួលពាក្យខុសគ្នាគឺ ប្រកាសនីយបត្រតក្កកម្មជាតិកន្លែងដាក់ពាក្យស្នើសុំនៅក្រសួងឧស្សាហកម្ម វិទ្យាស្រាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ចំពោះប្រកាសនីយបត្រតក្កកម្មអន្តរជាតិ គឺដាក់នៅតាមការិយាល័យទទួលពាក្យ ពោលគឺ អាចជាការិយាល័យជាតិ ឬការិយាល័យចុះបញ្ជីតាមតំបន់ ឬ ការិយាល័យអន្តរជាតិរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក ។ ក្នុងការដាក់ពាក្យស្នើសុំប្រកាសនីយបត្រតក្កកម្មអន្តរជាតិនេះ ក៏មាន ភ្ជាប់មកជាមួយចំពោះគំនូសបង្ហាញផងដែលក្នុងករណីមាន ។ **អានុភាព ឬ វិសាលភាព** ក្នុងការអនុវត្តន៍ និង ប្រើប្រាស់ របស់ម្ចាស់ប្រកាសនីយបត្រតក្កកម្ម ក៏មានភាពខុសគ្នាផងដែលពោលគឺ ប្រកាសនីយបត្រតក្កកម្មជាតិ មានអានុភាពអនុវត្តក្នុងវង្វង់ដែនដីដែលធ្វើការចុះបញ្ជី និងទទួលបានការការពារប៉ុណ្ណោះ ហើយស្ថិតនៅក្រោមការគ្រប់គ្រង និង ក្រោមអំណាចរបស់រដ្ឋមានសិទ្ធិប្រកបអាជីវកម្មទៅតក្កកម្មនោះបាន(រឹមអូសស្របច្បាប់) ប៉ុន្តែចំពោះប្រកាយនីបត្រតក្កកម្មអន្តរជាតិ មានវិសាលភាព ឬ អានុភាព ប្រើប្រាស់ ទាញយកផលប្រយោជន៍បាន ចំពោះប្រទេសណាដែលខ្លួនទទួលបានការការពារ ពីព្រោះប្រកាសនីយបត្រតក្កកម្មអន្តរជាតិនេះម្ចាស់តក្កកម្មអាច**ជ្រើសរើសចំនួនប្រទេស**ដែលខ្លួនចង់ឱ្យការពារក្នុងការិយាល័យតែមួយ បានច្រើនប្រទេសក្នុងពេលតែមួយបានអាច១០ ឬ ២៥ ឬ ៥០ ប្រទេសតាមតែខ្លួនចង់បាន ក្នុងករណីនេះដែលប្រសិនបើម្ចាស់តក្កកម្មទទួលបានការការពារចំនួន ១០ ប្រទេស ម្ចាស់ប្រកាសនីយបត្រតក្កកម្មត្រូវតែបង់តម្លៃលើ ប្រកាសនីយបត្រតក្កកម្មនោះ ប្រសិនមិនបានបង់ចំពោះប្រទេសណាមួយនោះ ប្រកាសនីយបត្រតក្កកម្មនៅក្នុងប្រទេសនោះត្រូវអស់សុពលភាព ។ ចំពោះប្រកាសនីយបត្រតក្កកម្មអន្តរជាតិនេះ វាមិនស្ថិតនៅក្រោមការគ្រប់គ្រងរបស់នោះទេ រដ្ឋមិនអាចធ្វើអាជីវកម្មលើតក្កកម្មនោះបានទេ ពីព្រោះវាស្ថិតនៅក្រៅវង្វង់ដែនអំណាចសមត្ថកិច្ចរបស់រដ្ឋ។

### ៣.៣. គុណសម្បត្តិ និង គុណវិបត្តិ

ប្រកាសនីយបត្រតក្កកម្ម តាមសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម មានគុណសម្បត្តិ និង ផលប្រយោជន៍ជាច្រើនដល់ប្រទេសដែលជ្រើសរើសយក ការស្នើសុំការការពារលក្ខខណៈអន្តរជាតិតាមរយៈសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម ដែលនីតិវិធីមួយនេះជួយសម្រួលដល់ភាពងាយស្រួលដល់ម្ចាស់ស្នាដៃ លក្ខខណ្ឌមិនស្មុគស្មាញ មួយវិញទៀត ម្ចាស់តក្កកម្មអាចជ្រើសរើសយកប្រទេសដែលខ្លួន

ពេញចិត្ត និងចង់ឱ្យការពារមកលើតក្កកម្មរបស់ខ្លួនច្រើនប្រទេសក្នុងពេលតែមួយបានផងដែរ។ ម្យ៉ាងទៀត សន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម (PCT) នេះជួយដល់ម្ចាស់តក្កកម្ម អាចទាញផលប្រយោជន៍ផ្នែកទីផ្សារ ហិរញ្ញវត្ថុ និង ជួយដល់ការអភិវឌ្ឍន៍ប្រទេសមានការរីកចម្រើនមានតក្កម្ម ឬ សម្ភារៈទំនើប បច្ចេកវិទ្យាជឿនលឿនជាងមុន និងអាចទាក់ទាញអ្នកវិនិយោគទុនច្រើនផងដែរ ហើយតក្កកម្មដែលទទួលបានការការពារតាមរយៈសន្ធិសញ្ញានេះមិនប្រឈមមុខនិងការរំលោភបំពានសិទ្ធិនោះទេពីព្រោះការស្នើសុំតាមនីតិវិធីនេះមានលក្ខណៈច្បាស់លាស់ មានការត្រួតពិនិត្យយ៉ាងលម្អិត។ តក្កកម្មដែលទទួលបានការការពារតាម សន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម (PCT) បានការពារឱ្យតក្កកម្មនេះរួចផុតពីការគ្រប់គ្រងឱ្យនៅក្រោមអំណាចរបស់រដ្ឋ រដ្ឋមិនមានសិទ្ធិប្រកបអាជីវកម្មរបស់ខ្លួនទៅលើតក្កម្មនេះបានទេ ។

ចំពោះប្រកាសនីយបត្រតក្កកម្ម តាមសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម (PCT) ក៏មានគុណវិបត្តិមួយចំនួនផងដែរ ពោលគឺម្ចាស់តក្កកម្មត្រូវទទួលរ៉ាប់រងរាល់ការចំណាយមួយចំនួនដើម្បីចុះបញ្ជី ដូចជាកម្រៃបញ្ជូនឯកសារ កម្រៃចុះបញ្ជីអន្តរជាតិ និងកម្រៃឯកសារមួយចំនួនផ្សេងទៀត មួយវិញទៀតម្ចាស់ប្រកាសនីយបត្រតក្កកម្មត្រូវតែបង់តម្លៃចំពោះប្រកាសនីយបត្រតក្កកម្ម នៅគ្រប់ចំនួនប្រទេសដែលខ្លួនជ្រើសរើសទទួលការការពារបើមិនដូច្នេះទេប្រកាសនីយបត្រតក្កកម្ម ដែលស្ថិតនៅក្នុងប្រទេសណាមួយដែលម្ចាស់ប្រកាសនីយបត្រតក្កកម្មមិនបានបង់ នោះប្រកាសនីយបត្រក្នុងប្រទេសនោះនិងអស់សុពលភាពមិនអាចប្រើប្រាស់ ឬទាញយកផលប្រយោជន៍ពីតក្កកម្មនោះបានទេ ហើយតក្កកកម្មនឹងក្លាយជាទ្រព្យសម្បត្តិសាធារណៈ។ ម្យ៉ាងទៀត នីតិវិធីនេះអាចជួយឱ្យតក្កកម្មអាចទាញផលប្រយោជន៍ក៏ពិតមែន ប៉ុន្តែចំពោះប្រយោជន៍ផ្នែកសេដ្ឋកិច្ច នោះនឹងឆាប់បាត់បង់ទៅវិញទោះបីវាមាន រយៈពេលការពារវែងក៏ដោយប្រសិនបើមានតក្កកម្មថ្មី ទំនើបជាងនោះនឹងធ្វើឱ្យតក្កកម្មនេះឆាប់បាត់បង់តម្លៃ ពោលគឺគេឈប់ប្រើវា។ ម្យ៉ាងតក្កកម្ម តាមសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម(PCT)នេះមិនអាចអនុវត្តបានពេញមួយពិភលោកនោះទេ ពោលតក្កកម្មដែលទទួលបានតាមរយៈសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម (PCT)អាចអនុវត្តបានត្រឹមតែដែនដីប្រទេសដែលផ្តល់ការការពារប៉ុណ្ណោះ។

# សេចក្តីសន្និដ្ឋាន

ឆ្លងតាមស្រាវជ្រាវ និង បកស្រាយប្រធានបទខាងលើនេះ **នីតិវិធីនៃការចុះបញ្ជីប្រកាសនីយបត្រតក្កកម្មជាតិ និង អន្តរជាតិ** យើងសង្កេតឃើញថាមានលក្ខណៈដូចគ្នាមួយចំនួនផងដែរ ពីព្រោះប្រកាសនីយបត្រតក្កកម្មនីមួយៗអាចទទួលបានការការពារបានលុះត្រាតែតក្កកម្មដែល ស្នើសុំទទួលបានការការពារ ថ្មី ជំហាននៃការរកឃើញថ្មី និងអាចអនុវត្តបានក្នុងវិស័យឧស្សាហកម្ម និង សិប្បកម្មបាន។ មួយវិញទៀត ប្រកាសនីយប្រតក្កកម្មជាតិ និងអន្តរជាតិដែលទទួលបានតាមរយៈសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មនេះ មានគោលដៅ និងគោលបំណងជួយលើកទឹកចិត្ត និង ជម្រុញដល់បុគ្គលដែលជាម្ចាស់ស្នាដៃឱ្យមានទឹកចិត្តក្នុងការស្វែងរកស្នាដៃថ្មីៗបន្ថែមទៀតផងដែរ។ លើសពីនេះទៅទៀតប្រកាសនីយបត្រតក្កកម្ម ក៏បានជួយទាញផលប្រយោជន៍ដល់តក្កករ ផ្នែកសេដ្ឋកិច្ចទីផ្សារ ឧស្សាហកម្ម កេរ្តិ៍ឈ្មោះ ភាពល្បីល្បាញ និងជួយដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិផងដែរ

ពិសេសជាងនេះទៅទៀត តក្កករដែលទទួលបានការការពារ ទាំងប្រកាសនីយបត្រតក្កកម្មជាតិ និង អន្តរជាតិ ទទួលបានសិទ្ធិផ្តាច់មុខ សិទ្ធិប្រើប្រាស់ស្របច្បាប់ក្នុងការវិនិយោគជាមួយសហគ្រាស និង ទទួលបានការការពារដោយច្បាប់ក្នុងការរំលោភបំពានចំពោះតក្កកម្មរបស់គាត់។ យ៉ាងណាមិញដើម្បីទទួលបានការការពារទាំងប្រកាសនីយបត្រតក្កកម្មជាតិ និង អន្តរជាតិ តាមរយៈសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម( PCT) ម្ចាស់តក្កករកម្មត្រូវតែគោរពតាមលក្ខខណ្ឌច្បាប់បានកំណត់ តក្កករត្រូវតែបំពេញបែបបទសំណុំលិខិតដាក់ពាក្យស្នើសុំដូចគ្នា ក្នុងនោះរួមមាន ពាក្យសុំ សេចក្តីអត្ថាធិប្បាយ សេចក្តីអះអាង ខ្លឹមសារសង្ខេប និង គំនូសតាងមករួមជាមួយផងដែលប្រសិនបើមាន ដើម្បីឱ្យមន្ត្រីកាន់កាប់ការចុះបញ្ជីត្រួតពិនិត្យ និង ស្រាវជ្រាវ អំពីអត្តសញ្ញាណភាពថ្មី ជំហាននៃការរកឃើញថ្មី និងអាចអនុវត្តបានក្នុងវិស័យឧស្សាហកម្ម និង សិប្បកម្ម ដើម្បីបញ្ជាក់ថាតក្កកម្មដែលបានស្នើសុំចុះបញ្ជីបានបំពេញបានត្រឹមត្រូវតាមលក្ខខណ្ឌច្បាប់កំណត់ មិនធ្វើឱ្យប៉ះពាល់ដល់សណ្តាប់សង្គម ឬ សុខភាពមនុស្សសត្វទេ។

ទោះបីជាយ៉ាងណាក៏ដោយ ក្នុងដំណាក់កាលចុះបញ្ជី យើងក៏សង្កេតឃើញថានូវមានលក្ខណៈខុសគ្នាមួយចំនួនផងដែរ។ ចំណែកឯការចុះបញ្ជីប្រកាសនីយបត្រតក្កកម្មជាតិ សមត្ថកិច្ចដែលទទួលបន្ទុកក្នុងការចុះបញ្ជីគឺ នាយកដ្ឋានឧស្សាហកម្មវិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍ ដែលមានប្រធានមួយរូបដែលមានតួនាទីដឹកនាំក្នុងការស្នើសុំចុះបញ្ជី គឺជាមន្ត្រីកាន់កាប់បញ្ជី។ រីឯការចុះបញ្ជីប្រកាសនីយ បត្រតក្កកម្មអន្តរជាតិ តាមរយៈសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម( PCT) អ្នកមានសមត្ថកិច្ចចុះបញ្ជីមាន សន្និតបាទ គណៈកម្មាការប្រតិបត្តិ ការិយាល័យអន្តរជាតិ និង គណៈកម្មាការសហប្រតិបត្តិការបច្ចេកទេសដែលបានបែងចែកនូវតួនាទីដាច់ដោយឡែកពីគ្នាដើម្បីជួយសម្រួល និងជួយពន្លឿននីតិវិធីឱ្យកាន់តែឆាប់រហ័ស ។ លើសពីនេះទៅទៀត ក៏មានការ

ត្រួតពិនិត្យលើសំណុំស្នើសុំអន្តរជាតិ ការស្រាវជ្រាវចំពោះកម្មវត្ថុដែលមិនស្ថិតក្នុងការស្រាវជ្រាវ ស្រាវជ្រាវពាក់ព័ន្ធនឹងរបាយការណ៍ ស្រាវជ្រាវបន្ថែម និងការផ្សាយជាសាធារណៈ ចំពោះការស្រាវជ្រាវបន្ថែម និង ការផ្សាយជាសាធារណៈ គឺដើម្បីឱ្យមានភាពច្បាស់លាស់ លម្អិត និង បង្ហាញឱ្យឃើងថាប្រកាសនីយបត្រតក្កកម្មនេះមានលក្ខណៈទូលំទូលាយ អំពីតក្កកម្មថ្មីដែលទទួលបានការការពារជាងប្រកាសនីយបត្រតក្កកម្មជាតិ។ ម្យ៉ាងទៀត ការការពារនេះ មានលក្ខណជាសកល និង អន្តរជាតិ រួមជាមួយប្រទេសដែលជា សមាជិកជាច្រើនផ្តល់ការការពារផងដែរ។

សរុបសេចក្តីមក នីតិវិធីនៃការចុះបញ្ជីប្រកាសនីយបត្រតក្កកម្មជាតិ និង អន្តរជាតិសុទ្ធសឹងតែមានផលប្រយោជន៍ និង គុណសម្បត្តិ ដល់តក្កករ ពីព្រោះ ជួយឱ្យតក្កករមានភាពងាយស្រួល ឆាប់រហ័ស ផ្តល់ការការពារមិនឱ្យបុគ្គលដែលមានគំនិតមិនល្អមករំលោភបំពាន ទាញយកនូវប្រាក់ចំណូល ទាក់ទាញអ្នកវិនិយោគទុន ធ្វើឱ្យសេដ្ឋកិច្ចជាតិ និងអន្តរជាតិមានការរីកចម្រើន អភិវឌ្ឍ ក៏ប៉ុន្តែប្រកាសនីយបត្រតក្កកម្ម ក៏មានគុណវិបត្តិផងដែល ពោលគឺតក្កករត្រូវមានកាតព្វកិច្ចបង់កម្រៃចំពោះឯកសារដែលពាក់ នឹង បញ្ហាឆាប់បង់គុណតម្លៃនៃតក្កកម្ម នូវពេលតក្កកម្មមួយទៀតដែលទំនើបជាងបានរកឃើញផងដែរ។

# អនុសាសន៍

បន្ទាប់ពីការធ្វើការស្រាវជ្រាវលើប្រធានបទ "នីតិវិធីការចុះបញ្ជីប្រកាសនីយបត្រតក្កកម្មជាតិ និងអន្តរជាតិ" រួចមក ការផ្តល់អនុសាសន៍មួយចំនួន និងយុទ្ធសាស្ត្រទៅថ្ងៃអនាគតដែលជាលទ្ធផលការស្រាវជ្រាវមួយនេះ។

ជាការពិតណាស់ កម្ពុជាជាប្រទេសដែលកំពុងអភិវឌ្ឍន៍ ដូច្នេះបញ្ហាដែលប្រឈមគឺមានច្រើន និងដើម្បីអនុវត្តនូវនីតិវិធីនៃការចុះបញ្ជីមានប្រសិទ្ធិភាព និងប្រកបទៅដោយរលូន នោះចំបាច់ត្រូវតែះ

- សមត្ថកិច្ចទទួលបន្ទុកគួរយកចិត្តទុកដាក់ ពង្រឹងបណ្តុះនូវធនធាន និងអ្នកជំនាញក្នុងការចុះបញ្ជីប្រកាសនីយបត្រតក្កកម្មឱ្យបានច្បាស់លាស់ ដោយផ្តល់ឱកាសអោយសិក្សាបន្ថែមតាមបណ្តាលប្រទេសផ្សេងៗលើពិភពលោក ដើម្បីយកមកអនុវត្តក្នុងប្រទេសឲ្យមានការជឿនលឿន
- រដ្ឋាភិបាលត្រូវពង្រឹងលើនីតិវិធីចុះបញ្ជី និងយន្តការនៃការពារឱ្យរឹងមាំមានប្រសិទ្ធិភាពខ្ពស់កុំឲ្យមានការរំលោភបំពាន លើការផ្តល់សិទ្ធិនៃប្រកាសនីយបត្រតក្កកម្ម។
- រដ្ឋាភិបាលគួរតែផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីប្រព័ន្ធប្រកាសនីយបត្រតក្កកម្ម ។
- ម្យ៉ាងទៀត គួរលើកទឹកចិត្ត និងធ្វើយ៉ាងពង្រឹងវិស័យកម្មសិទ្ធិបញ្ញាថ្នាក់ជាតិអោយបានរឹងមាំ ដើម្បីការពារកម្មសិទ្ធិបញ្ញាអោយបានល្អប្រសើរទៅតាមការដាក់ពាក្យស្នើសុំ ហើយជៀសវាងការរំលោភបំពានសិទ្ធិលើកម្មសិទ្ធិបញ្ញា ក៏ដូចគ្នាទប់ស្កាត់អំពើពុករលួយ ដែលជាសកម្មភាពដែលយកចិត្តទុកដាក់ពីរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

# ឯកសារយោង

## ក. ច្បាប់ជាតិ

- ច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំរូឧស្សាហកម្ម (២៨ វិច្ឆកា ២០០២)
- កម្រងច្បាប់ពាណិជ្ជកម្ម និងច្បាប់កម្មសិទ្ធិបញ្ញាភាគ I (ថ្ងៃទី២៨ ខែវិច្ឆកា ឆ្នាំ២០០២)
- ប្រកាសលេខ ៧០៦ ស្តីពីនីតិវិធីផ្តល់ប្រកាសនីយបត្រ និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ (ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ ២០០៦)
- ប្រកាសលេខ ២០៣ ស្តីពីការគ្រប់គ្រង និងនីតិវិធីផ្តល់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ (ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ ២០១៩)

## ក. អន្តរជាតិ

- សន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម
- វិធានក្រោយសន្ធិសញ្ញាសហប្រតិបត្តិកាប្រកាសនីយបត្រតក្កកម្ម

## គ.ប្រភពសៀវភៅ

- នីតិកម្មសិទ្ធិបញ្ញា អនុបណ្ឌិ លឹម យូសួ
- នីតិកម្មសិទ្ធិបញ្ញា សាស្រ្តចារ្យ ឃឹម គីរី (ឆ្នាំ២០០៩)
- នីតិកម្មសិទ្ធិបញ្ញា សាស្រ្តចារ្យ ទេព សុខ (ឆ្នាំ២០២០-២០២១)
- នីតិកម្មសិទ្ធិបញ្ញា សាស្រ្តចារ្យ កាន់ សុទ្ធប៉ូលីន (ឆ្នាំ២០១៤)
- នីតិកម្មសិទ្ធិបញ្ញា សាស្រ្តចារ្យ ឥន យឿន (ឆ្នាំ២០១៣)
- នីតិកម្មសិទ្ធិបញ្ញា សាស្រ្តចារ្យ នីវិចិត្រ (ឆ្នាំ២០១៣)
- ប្រកាសនីយបត្រតក្កកម្ម និងម៉ាកស្រាវជ្រាវដោយ នន គីមយុងតាក់ (១១ មករា ២០២១)
- ការប្រៀបធៀបនីតិវិធីចុះបញ្ជីប្រកាសនីយបត្រតក្កកម្មនៅកម្ពុជា និងតាមសន្ធិសញ្ញាសហប្រកាសនីយបត្រតក្កកម្ម សារណាបញ្ចប់ការសិក្សា នួន កន្និកា (១៦ ឧសភា ឆ្នាំ២០១៩)
- នីតិវិធីនៃការចុះបញ្ជីប្រកាសនីយបត្រតក្កកម្មជាតិ និងអន្តរជាតិ របាយការណ៍ស្រាវជ្រាវបញ្ចប់ការសិក្សានិស្សិត រស់ រតនា

## ឃ.ប្រភពពីគេហទំព័រ


- http://www.mcfa.gov.kh/files/2014/10/242/IP%20lesson(2).pdf (កាលបរិច្ឆេទចូលមើលថ្ងៃទី០២ ខែឧសភាព ឆ្នាំ២០២១)
- https://www.elibrary-rule.com/public/images/sarana_file/Thesis2019 (48).pdf (កាលបរិច្ឆេទចូលមើលថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២១)
- http://lac.org.kh/wp-content/uploads/2017/11/2003 (កាលបរិច្ឆេទចូលមើលថ្ងៃទី១៨ ខែឧសភាព ឆ្នាំ២០២១)
- នីតិកម្មសិទ្ធិបញ្ញា.pdf - Google Drive (កាលបរិច្ឆេទចូលមើលថ្ងៃទី០៦ ខែក្កកដា ឆ្នាំ២០២១)
- សេចក្តីផ្តើមកសម្មសិទ្ធិបញ្ញា.pdf - Google Drive (កាលបរិច្ឆេទចូលមើលថ្ងៃទី១៧ ខែក្កកដា ឆ្នាំ២០២១)
- https://www.cambodiaip.gov.kh/TemplateTwo.aspx (កាលបរិច្ឆេទចូលមើលថ្ងៃទី២៨ ខែក្កកដា ២០២១)
- https://wipolex-res.wipo.int/edocs/lexdocs/laws/km/kh/kh043km.pdf (កាលបរិច្ឆេទចូលមើលថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២១)
- https://www.facebook.com/1482208281916621/photos (កាលបរិច្ឆេទចូលមើលថ្ងៃទី០២ ខែ មិថុនា ឆ្នាំ២០២១)
- PCT Application Form ed_request.pdf (កាលបរិច្ឆេទចូលមើលថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២១)
- សន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រ តក្កកម្ម (PCT) - Ponlork Library (ponlork-library.blogspot.com) (កាលបរិច្ឆេទចូលមើលថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២១)

# ឧបសម្ព័ន្ធ